**រាជរដ្ឋាភិបាលកម្ពុជា**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# ផែនការកសាងសមត្ថភាពរបស់
# គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាម
# បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
# ឆ្នាំ២០០៩

**លេខាធិការដ្ឋាន គ.ជ.អ.ប**

# មាតិកា


សេចក្តីផ្តើម ១

**ផ្នែកទី១ : ការកសាងសមត្ថភាពសម្រាប់គាំទ្ររដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

១.១. ប្រធានបទសម្រាប់គាំទ្ររដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៩ ២

១.២. ការបណ្តុះបណ្តាល ៣

១.២.១. វគ្គតម្រង់ទិសអំពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និង វិសហមជ្ឈការ ៣

១.២.២. ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ៥

១.២.៣. ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ៧

១.២.៤. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ៩

១.២.៥. ការអនុវត្តគម្រោងថ្នាក់ស្រុក ខណ្ឌ ១១

១.២.៦. វគ្គបណ្តុះបណ្តាលអង្គភាពគាំទ្រឃុំ សង្កាត់នៅថ្នាក់ស្រុក ១៣

១.៣. សិក្ខាសាលា ១៤

១.៣.១. សិក្ខាសាលាផ្សព្វផ្សាយអំពីច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ១៤

១.៤. ការអប់រំផ្សព្វផ្សាយសាធារណៈ ១៦

១.៤.១. ការបោះពុម្ពសៀវភៅផ្សព្វផ្សាយ ១៦

១.៤.២. ការបោះពុម្ពផ្ទាំងរូបភាពផ្សព្វផ្សាយ ១៧

១.៤.៣. កម្មវិធីផ្សព្វផ្សាយតាមវិទ្យុ ១៨

១.៤.៤. កម្មវិធីផ្សព្វផ្សាយតាមទូរទស្សន៍ ១៩

១.៥. ការបណ្តុះបណ្តាលសម្រាប់ថ្នាក់ជាតិ ២០

១.៥.១. ជំនាញបណ្តុះបណ្តាល ២០

១.៥.២. កិច្ចប្រជុំត្រួតពិនិត្យមុន និងក្រោយការបណ្តុះបណ្តាល ២១

**ផ្នែកទី២ : ការកសាងសមត្ថភាពសម្រាប់គាំទ្ររដ្ឋបាលឃុំ សង្កាត់**

២.១. លទ្ធផលការកសាងសមត្ថភាពឃុំ សង្កាត់ឆ្នាំ២០០៨ ២២

២.២. ប្រធានបទសម្រាប់គាំទ្ររដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០៩ ២៤

២.៣. វគ្គបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់សម្រាប់គ្រប់ឃុំ សង្កាត់ទាំងអស់ ២៥

២.៣.១. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោង កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ ២៥
២.៣.២. ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ២៨
២.៣.៣. ភាពជាអ្នកដឹកនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ៣០
២.៣.៤. ការសរសេរសំណើគម្រោងខ្នាតតូច ៣២
២.៣.៥. រំឭកឡើងវិញអំពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ ៣៤
២.៣.៦. រំឭកឡើងវិញអំពីដំណើរការកសាងកម្មវិធីវិនិយោគឃុំ សង្កាត់ ៣៥
២.៣.៧. រំឭកឡើងវិញអំពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ ៣៦
២.៣.៨. រំឭកឡើងវិញអំពី របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ៣៨
**២.៤. វគ្គបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់សម្រាប់ឃុំ សង្កាត់គោលដៅរបស់គម្រោងនានា** ៤០
២.៤.១. បញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងយុវវ័យ ៤០
២.៤.២. សេចក្តីណែនាំស្តីពីការរៀបចំ និងការគ្រប់គ្រងគម្រោងសេវាកម្ម (គម្រោង ICC) ៤១
២.៤.៣. សេចក្តីណែនាំស្តីពីការរៀបចំ និងការគ្រប់គ្រងគម្រោងសហប្រតិបត្តិការអន្តរឃុំ សង្កាត់ ៤៣
២.៤.៤. ទស្សនៈទានទាក់ទងនឹងគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ ៤៤
២.៤.៥. គោលការណ៍ណែនាំស្តីពីមូលនិធិទ្រទ្រង់ជីវភាពសហគមន៍ ៤៦
២.៤.៦. ការងាររដ្ឋបាល និងហិរញ្ញវត្ថុគម្រោង ៤៧
២.៤.៧. ជំនាញសម្របសម្រួលសម្រាប់បុគ្គលិកគម្រោង ៤៩
២.៤.៨. ការរៀបចំសហគមន៍ ៥០
២.៤.៩. ការធ្វើផែនការតាមគ្រួសារ ៥១
**២.៥. សិក្ខាសាលា ប្រជុំ និងការផ្លាស់ប្តូរបទពិសោធន៍** ៥២
២.៥.១. សិក្ខាសាលាឆ្លុះបញ្ចាំងអំពីការអនុវត្តការងាររបស់ក្រុមការងារគណនេយ្យភាព ៥២
២.៥.២. កម្រងបទឧទ្ទេសនាមសម្រាប់មន្ត្រីរាជការ ៥៣
២.៥.៣. កម្រងបទឧទ្ទេសនាមសម្រាប់សង្គមស៊ីវិល ៥៥
២.៥.៤. ការផ្លាស់ប្តូរបទពិសោធន៍រវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាឃុំ សង្កាត់ ៥៦
២.៥.៥. ការវាយតម្លៃសមត្ថភាពស្មៀនឃុំ សង្កាត់ ៥៩
២.៥.៦. វេទិកាបណ្តាញស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ ៦០
២.៥.៧. វេទិកាសាធារណៈនៅមូលដ្ឋាន ៦១
២.៥.៨. វេទិកាគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ៦៣
៦៤

២.៦. ការបណ្តុះបណ្តាលសម្រាប់គាំទ្រឃុំ សង្កាត់ ៦៤
២.៦.១. យេនឌ័រក្នុងវិមជ្ឈការ ៦៥
២.៦.២. នីតិវិធីស៊ើបអង្កេតពាក្យបណ្តឹង ៦៦
២.៦.៣. ប្រព័ន្ធតាមដាន និងរបាយការណ៍ ៦៧
២.៧. ការអប់រំផ្សព្វផ្សាយសាធារណៈសម្រាប់ឃុំ សង្កាត់ ៦៧
២.៧.១. ការផលិតស្ប៉ូតផ្សព្វផ្សាយតាមទូរទស្សន៍ ៦៧
២.៧.២. ការផលិតស្ប៉ូតផ្សព្វផ្សាយតាមវិទ្យុ ៦៨


**ឧបសម្ព័ន្ធ :**


ឧបសម្ព័ន្ធទី១ : ថវិកាប៉ាន់ស្មានលម្អិត ៧០
ឧបសម្ព័ន្ធទី២ : តារាងសង្ខេបផែនការកសាងសមត្ថភាពឆ្នាំ២០០៩ របស់ គ.ជ.អ.ប ៧៩
ឧបសម្ព័ន្ធទី៣ : កាលវិភាគ ៨៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ**
**តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**
**លេខាធិការដ្ឋាននៃ គ.ជ.អ.ប**

លេខ ..៣.៣......................

រាជធានីភ្នំពេញ ថ្ងៃទី...២៣..ខែ..កុម្ភៈ....ឆ្នាំ២០០៩

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**

**តាមរយៈ** : ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ។

**កម្មវត្ថុ** : សំណើសុំពិនិត្យ និងសម្រេច លើផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប សម្រាប់ឆ្នាំ២០០៩ ។

**យោង** : កំណត់ហេតុកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងផែនការកសាងសមត្ថភាពគ.ជ.អ.ប ឆ្នាំ២០០៩ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបថា លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប សម្រាប់ឆ្នាំ២០០៩ ដោយយោងទៅលើ **ទី១**-ផ្អែកលើប្រធានបទខ្លះ ដែលនៅសល់មិនទាន់បានបណ្តុះបណ្តាលក្នុងឆ្នាំ២០០៨ **ទី២**-ផ្អែកលើលទ្ធផលនៃការចុះសិក្សាវាយតម្លៃតម្រូវការបណ្តុះបណ្តាលឆ្នាំ២០០៨ របស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន **ទី៣**-ផ្អែកលើការប្រមើលមើលពីប្រធានបទចាំបាច់ សម្រាប់មន្ត្រីថ្នាក់ក្រោមជាតិដើម្បីធានាអោយរដ្ឋបាលថ្នាក់ក្រោមជាតិក្រោយការបោះឆ្នោតអាចបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបាន និងផ្អែកលើភាពចាំបាច់ក្នុងការផ្សព្វផ្សាយអំពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ **ទី៤**-ឆ្លងតាមលទ្ធផលនៃការប្រជុំពិភាក្សាលើសេចក្តីព្រាងផែនការកសាងសមត្ថភាពរបស់គ.ជ.អ.ប ឆ្នាំ២០០៩ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៩។

ផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩ នេះរួមមាន :

១- វគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយដែលរៀបចំឡើងដោយ គ.ជ.អ.ប ផ្ទាល់ និង

២- វគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយគម្រោងរបស់ដៃគូអភិវឌ្ឍ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេច ដ៏ខ្ពង់ខ្ពស់ ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។៚

**ប្រធានលេខាធិការដ្ឋានបណ្តោះអាសន្នរបស់ គ.ជ.អ.ប**

02 - 03 - 2009

សក់_សេដ្ឋា

# សេចក្តីផ្តើម

ការអប់រំ និងកសាងសមត្ថភាព គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលរួមមាននៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់។ ទោះបីជាគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ក៏ដូចជាគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានផ្តល់ការកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់កន្លងមកហើយក្តី ក៏សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅមានការខ្វះចន្លោះនៅឡើយ។ លើសពីនេះទៀតសមត្ថភាពរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលនឹងបង្កើតឡើងអំឡុងខែឧសភា ឆ្នាំ២០០៩ ចាំបាច់ត្រូវតែធ្វើការកសាង និងពង្រឹងដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះអាចអនុវត្តមុខងាររបស់ខ្លួនស្របតាមគោលការណ៍ និងក្របខ័ណ្ឌ ច្បាប់ដែលបានកំណត់។

ដោយយល់ឃើញថា ការកសាងសមត្ថភាពមានសារសំខាន់ និងចាំបាច់ ទើបគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រៀបចំ និងចងក្រងឯកសារផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប សម្រាប់ឆ្នាំ២០០៩នេះឡើងក្នុងគោលបំណង ដើម្បីបង្កើតជាផែនការជាក់លាក់សម្រាប់ការកសាងសមត្ថភាពដល់អ្នកអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផ្តល់ជាព័ត៌មានដល់ដៃគូអភិវឌ្ឍន៍នានាអំពីតម្រូវការកសាងសមត្ថភាពទាំងនោះ។

ឯកសារផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ត្រូវបានរៀបរៀងឡើងជាពីរផ្នែកគឺ ផ្នែកគាំទ្រដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ និងមួយផ្នែកទៀតគឺផ្នែកគាំទ្រដល់ការអនុវត្តនៅថ្នាក់ឃុំ សង្កាត់។ ក្នុងផ្នែកនីមួយៗនឹងបរិយាយអំពីប្រធានបទជាក់លាក់ ប្រវត្តិ ខ្លឹមសារសំខាន់ៗ យុទ្ធសាស្ត្របណ្តុះបណ្តាល ពេលវេលា និងការគ្រោងថវិកាគាំទ្រផងដែរ។

ទោះបីជាផែនការកសាងសមត្ថភាពនេះត្រូវបានរៀបចំ និងចងក្រងដោយផ្អែកលើការវិភាគតួនាទី ភារកិច្ច និងផ្អែកលើលទ្ធផលនៃការសិក្សាអំពី តម្រូវការកសាងសមត្ថភាពសម្រាប់ឆ្នាំ២០០៩ ជាមួយ៧៨ក្រុមផ្តល់យោបល់នៅក្នុង១៥ខេត្តក្រុង ជាមួយអង្គការសង្គមស៊ីវិល ជាមួយសម្ព័ន្ធភាពជាតិឃុំសង្កាត់ ព្រមទាំងផ្អែកលើលទ្ធផលនៃការសិក្សាអំពីតម្រូវការកសាងសមត្ថភាពសម្រាប់ឆ្នាំ២០០៨ផងដែរក៏ដោយ ក៏ផែនការកសាងសមត្ថភាពនេះមិនទាន់មានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយនៅឡើយ ដូច្នេះ គ.ជ.អ.ប នឹងរង់ចាំទទួលនូវការផ្តល់យោបល់កែលម្អនានាពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់។

# ផ្នែកទី១

# ការកសាងសមត្ថភាពសម្រាប់គាំទ្រ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ១.១. ប្រធានបទកសាងសមត្ថភាពសម្រាប់គាំទ្ររដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឆ្នាំ២០០៩

ប្រធានបទកសាងសមត្ថភាពសម្រាប់គាំទ្ររដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៩ រួមមានដូចខាងក្រោម :

☞ **វគ្គបណ្តុះបណ្តាល**

១. វគ្គតម្រង់ទិសអំពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ

២. ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

៣. ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

៤. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ

៥. ការអនុវត្តគម្រោងថ្នាក់ស្រុក ខណ្ឌ

៦. វគ្គបណ្តុះបណ្តាលអង្គភាពគាំទ្រឃុំ សង្កាត់នៅថ្នាក់ស្រុក

☞ **សិក្ខាសាលា**

៧. សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

☞ **ការអប់រំផ្សព្វផ្សាយសាធារណៈ**

៨. ការបោះពុម្ពសៀវភៅផ្សព្វផ្សាយ

៩. ការបោះពុម្ពផ្ទាំងរូបភាពផ្សព្វផ្សាយ

១០. ការផលិតកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ

១១. ការផលិតកម្មវិធីផ្សព្វផ្សាយតាមទូរទស្សន៍

☞ **ការបណ្តុះបណ្តាលថ្នាក់ជាតិ**

១២. ជំនាញបណ្តុះបណ្តាល

១៣. សិក្ខាសាលាពង្រឹងគ្រូបណ្តុះបណ្តាលថ្នាក់ជាតិ

## ១.២. ការបណ្តុះបណ្តាល

### ១.២.១. វគ្គតម្រង់ទិសអំពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និង វិសហមជ្ឈការ

ក). ប្រវត្តិ

ដើម្បីអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលបានរៀបចំចងក្រងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលច្បាប់នេះត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨។ តួអង្គសំខាន់ក្នុងការអនុវត្តកំណែទម្រង់នេះគឺរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ ដែលតួអង្គទាំងនេះចាំបាច់ត្រូវមានចំណេះដឹងជាមូលដ្ឋានអំពីច្បាប់នេះ។ ជាមួយគ្នានេះផងដែរ ដោយផ្អែកតាមលទ្ធផលនៃការសិក្សាអំពីតម្រូវការកសាងសមត្ថភាពឃុំ សង្កាត់ ក្រុមអ្នកផ្តល់ព័ត៌មាននៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌភាគច្រើនបានលើកឡើងនូវតម្រូវការកសាងសមត្ថភាពពួកគេអំពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ។ លើសពីនេះទៀតដើម្បីឱ្យក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលត្រូវបានបោះឆ្នោតជ្រើសរើស និងចូលកាន់តំណែងអាចអនុវត្តមុខងារ តួនាទី និងភារកិច្ចរបស់ខ្លួនស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រុមប្រឹក្សាទាំងនោះចាំបាច់ត្រូវដឹងអំពីរបៀបគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ។

ដោយយោងលើភាពចាំបាច់ និងជាតម្រូវការពិតប្រាកដរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គ.ជ.អ.ប បានសម្រេចបញ្ចូលវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នេះទៅក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

ខ). ខ្លឹមសារនៃវគ្គបណ្តុះបណ្តាល

ខ្លឹមសារនៃវគ្គបណ្តុះបណ្តាលតម្រង់ទិសស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ នឹងផ្តោតលើប្រធានបទសំខាន់ៗមួយចំនួនដូចខាងក្រោម :

- ទស្សនទាននៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតបទដ្ឋានគាំទ្រផ្សេងទៀត
- ការរៀបចំផែនការសកម្មភាពរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសម្រាប់ឆ្នាំ២០០៩

ក្រុមការងាររៀបចំមេរៀនមួយនឹងត្រូវបង្កើតឡើង ដែលមានសមាសភាពមន្ត្រីមកពីក្រុមគោលនយោបាយ ការិយាល័យពាក់ព័ន្ធនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងគម្រោងគាំទ្រការអភិវឌ្ឍបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) គម្រោងកែលម្អរដ្ឋបាលមូលដ្ឋាននៅកម្ពុជា (PILAC/JICA) ព្រមទាំងអ្នកពាក់ព័ន្ធដទៃទៀត។ ក្រុមការងារនេះនឹងរៀបចំខ្លឹមសារមេរៀន និងវិធីសាស្ត្របណ្តុះបណ្តាលដោយយោងតាមខ្លឹមសារច្បាប់ស្តីពី

ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឯកសារក្របខ័ណ្ឌច្បាប់ ព្រមទាំងឯកសារបណ្តុះបណ្តាលផ្សេងៗទៀត។ បន្ទាប់ពីរៀបចំសេចក្តីព្រាងរួចរាល់ ក្រុមការងារនឹងដាក់សេចក្តីព្រាងនោះជូនថ្នាក់ដឹកនាំ គ.ជ.អ.ប ដើម្បីពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលបានការឯកភាពពីថ្នាក់ដឹកនាំ គ.ជ.អ.ប ផ្នែកកសាងសមត្ថភាព និងព័ត៌មាននៃក្រុមគោលនយោបាយ និងក្រុមការងាររៀបចំមេរៀននឹងរៀបចំការបណ្តុះបណ្តាលសាកល្បងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

គ). **យុទ្ធសាស្ត្របណ្តុះបណ្តាល**

បន្ទាប់ពីការបណ្តុះបណ្តាលសាកល្បង និងកែសម្រួលរួចរាល់ ផ្នែកកសាងសមត្ថភាពនៃក្រុមគោលនយោបាយសហការជាមួយការិយាល័យអប់រំ និងកសាងសមត្ថភាព និងក្រុមការងាររៀបចំមេរៀននឹងរៀបចំការបណ្តុះបណ្តាលដល់ :

- ***ថ្នាក់រដ្ឋបាលរាជធានី ខេត្ត*** : គ្រូបណ្តុះបណ្តាលថ្នាក់ជាតិនឹងធ្វើការបណ្តុះបណ្តាលតម្រង់ទិសដោយផ្ទាល់ដល់គ្រប់ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តទាំងអស់។ សិក្ខាកាមចូលរួមសរុបក្នុងការបណ្តុះបណ្តាលផ្ទាល់នេះមានចំនួនប្រមាណ៥១១រូប ហើយត្រូវរៀបចំបណ្តុះបណ្តាលជាលក្ខណៈសិក្ខាសាលាផ្សព្វផ្សាយចំនួន៦លើក ដែលមួយលើកៗមានសិក្ខាកាមចូលរួមមកពី៤ខេត្ត។
- ***ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ*** : ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងជាបីដំណាក់កាលដូចខាងក្រោម :
  - **បណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ** : បណ្តុះបណ្តាលគ្រូបង្គោលមកពីរាជធានី និងខេត្តទាំង២៣នៅថ្នាក់ជាតិ។ ដូច្នេះរាជធានី និងខេត្តនីមួយៗត្រូវចាត់បញ្ជូនមន្ត្រីចំនួនពី២ទៅ៦រូបដើម្បីចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលមកពីខេត្ត និងរាជធានីនៅថ្នាក់ជាតិ ដែលមានសិក្ខាកាមសរុប៦២រូប ដោយបែងចែកជា២ថ្នាក់។
  - **បណ្តុះបណ្តាលគ្រូឧទ្ទេសនៅថ្នាក់រាជធានី ខេត្ត** : គ្រូបង្គោលដែលមកពីរាជធានី និងខេត្តនីមួយៗនឹងធ្វើការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ខេត្ត។ សិក្ខាកាមដែលត្រូវចូលរួមបណ្តុះបណ្តាលគ្រូឧទ្ទេសនៅថ្នាក់ខេត្តនេះអាចជាអ្នកសម្របសម្រួលខេត្ត ឬអ្នកដែលមានតួនាទីក្នុងការជួយគាំទ្រក្រុង ស្រុក ខណ្ឌ។ រាជធានី និងខេត្តនីមួយៗនឹងបណ្តុះបណ្តាលគ្រូឧទ្ទេសតែមួយថ្នាក់ប៉ុណ្ណោះ។
  - **ការបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ** : គ្រូឧទ្ទេសថ្នាក់រាចធានី ខេត្ត ត្រូវធ្វើការបណ្តុះបណ្តាលដល់គ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌនៅតាមខេត្ត និងរាជធានីរបស់ខ្លួន។ អ្នកចូលរួមមកពីថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមានគ្រប់សមាជិកក្រុមប្រឹក្សាទាំងអស់ គ្រប់គណៈអភិបាលទាំងអស់ទាំងអស់។ ការបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌត្រូវធ្វើឡើងនៅតាមក្រុង ស្រុក ខណ្ឌនីមួយៗ។

ការបណ្តុះបណ្តាលមួយវគ្គៗមានរយៈពេល : ០៣ថ្ងៃ

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែមករា-មីនា ឆ្នាំ២០០៩ : ការរៀបចំឯកសារ និងការបណ្តុះបណ្តាលសាកល្បង
- ខែមេសា-ឧសភា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលគ្រូបង្គោលមកពីរាជធានី និងខេត្តនៅថ្នាក់ជាតិ
- ខែមិថុនា-កក្កដា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលដល់ក្រុមគោលដៅ

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត : ៩៣.០៥៤ដុល្លារ
- ការបណ្តុះបណ្តាលគ្រូបង្គោលមកពីខេត្ត រាជធានី : ៩,៥៥៦ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសនៅថ្នាក់រាជធានី ខេត្ត : ១,២២៥ ដុល្លារ
- ការបណ្តុះបណ្តាលក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ : ២៣,៥៤១ ដុល្លារ

សរុប : **១២៧,៣៧៧ ដុល្លារ**

### ១.២.២. ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត

ក). ប្រវត្តិ

យោងមាត្រា៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលនីមួយៗត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំតាមរយៈកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ។ ដើម្បីឱ្យក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលនីមួយៗមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទី និងភារកិច្ចដូចមានចែងខាងលើនេះ គ.ជ.អ.ប បានបញ្ចូលប្រធានបទបណ្តុះបណ្តាលស្តីពី ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី និងខេត្ត ទៅក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពី ការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី និងខេត្តនឹងផ្តោតលើប្រធានបទសំខាន់ៗមួយចំនួនដូចខាងក្រោម :

- របៀបបង្កើតចក្ខុវិស័យ គោលដៅ គោលបំណងសម្រាប់អភិវឌ្ឍន៍
- របៀបប៉ាន់ស្មានពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់ និងប៉ាន់ស្មានអំពីតម្រូវការអភិវឌ្ឍន៍សំខាន់ៗ
- របៀបរៀបចំបង្កើតក្របខ័ណ្ឌអភិវឌ្ឍន៍
- របៀបរៀបចំផែនការហិរញ្ញវត្ថុ
- របៀបបង្កើតយុទ្ធសាស្ត្រអនុវត្តផែនការឱ្យមានតម្លាភាព និងគណនេយ្យភាព
- របៀបកំណត់សូចនាករសំខាន់ៗ

ក្រុមការងាររៀបចំមេរៀនមួយនឹងត្រូវបង្កើតឡើង ដែលមានសមាសភាពមន្ត្រីមកពីក្រុមគោលនយោបាយ ការិយាល័យពាក់ព័ន្ធនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងគម្រោងគាំទ្រការអភិវឌ្ឍបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) មន្ត្រីមកពីក្រសួងផែនការ ព្រមទាំងក្រសួង និងអ្នកពាក់ព័ន្ធដទៃទៀត។ ក្រុមការងារនេះនឹងរៀបចំខ្លឹមសារមេរៀន និងវិធីសាស្ត្របណ្តុះបណ្តាលដោយផ្អែកលើខ្លឹមសារច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឯកសារក្របខ័ណ្ឌច្បាប់ផ្សេងៗទៀត ឯកសារណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ព្រមទាំងឯកសារពាក់ព័ន្ធដទៃទៀត។ បន្ទាប់ពីរៀបចំសេចក្តីព្រាងរួច ក្រុមការងារត្រូវដាក់សេចក្តីព្រាងនោះជូនទៅថ្នាក់ដឹកនាំ គ.ជ.អ.ប ពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលបានការឯកភាពពី គ.ជ.អ.ប ផ្នែកកសាងសមត្ថភាព និងព័ត៌មាននៃក្រុមគោលនយោបាយ និងក្រុមការងាររៀបចំមេរៀននឹងរៀបចំការបណ្តុះបណ្តាលសាកល្បងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

## គ). យុទ្ធសាស្ត្របណ្តុះបណ្តាល

បន្ទាប់ពីការបណ្តុះបណ្តាលសាកល្បង និងកែសម្រួលរួចរាល់ ផ្នែកកសាងសមត្ថភាពនៃក្រុមគោលនយោបាយសហការជាមួយការិយាល័យអប់រំ និងកសាងសមត្ថភាព និងក្រុមការងាររៀបចំមេរៀននឹងធ្វើការបណ្តុះបណ្តាល :

- **សម្រាប់ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី និងខេត្ត :** គ្រូបណ្តុះបណ្តាលថ្នាក់ជាតិនឹងបណ្តុះបណ្តាលដោយផ្ទាល់ដល់គ្រប់ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តទាំងអស់។ សិក្ខាកាមចូលរួមសរុបក្នុងការបណ្តុះបណ្តាលផ្ទាល់នេះមានចំនួនប្រមាណ៥១១រូប ហើយត្រូវរៀបចំបណ្តុះបណ្តាលជាលក្ខណៈសិក្ខាសាលាផ្សព្វផ្សាយចំនួន៦លើក ដែលមួយលើកៗមានសិក្ខាកាមចូលរួមមកពី៤ខេត្ត។
- **សម្រាប់អង្គភាពជំនាញ :** គ្រូបណ្តុះបណ្តាលថ្នាក់ជាតិនឹងធ្វើការបណ្តុះបណ្តាលដោយផ្ទាល់ដល់អង្គភាពទទួលបន្ទុកកសាងផែនការ និងថវិកាអភិវឌ្ឍន៍រាជធានី ខេត្ត។ ដូច្នេះរាជធានី និងខេត្តនីមួយៗត្រូវចាត់បញ្ជូនមន្ត្រីទទួលបន្ទុកអនុវត្តការកសាងផែនការ និងថវិកាអភិវឌ្ឍន៍ខេត្តចំនួន៣រូបមកចូលរួមការបណ្តុះបណ្តាលអំពីការកសាងផែនការអភិវឌ្ឍន៍៥ឆ្នាំ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលរាជធានី ខេត្តនៅថ្នាក់ជាតិ។ សិក្ខាកាមចូលរួមសរុបក្នុងការបណ្តុះបណ្តាលផ្ទាល់នេះមានចំនួនប្រមាណ៧២រូប ហើយត្រូវរៀបចំជាការបណ្តុះបណ្តាលលម្អិតចំនួន២ថ្នាក់ ដែលមួយថ្នាក់ៗមានសិក្ខាកាមចូលរួមប្រមាណ៣៦រូប។
  **ការបណ្តុះបណ្តាលមួយវគ្គៗមានរយៈពេល : ០៣ថ្ងៃ**

## ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែមករា-ឧសភា ឆ្នាំ២០០៩ : ការរៀបចំឯកសារ និងការបណ្តុះបណ្តាលសាកល្បង
- ខែសីហា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលដល់ក្រុមគោលដៅ

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត : ៩៣.០៥៤ដុល្លារ
- ការបណ្តុះបណ្តាលអង្គភាពអនុវត្តថ្នាក់រាជធានី ខេត្ត : ១០,៨១៦ ដុល្លារ

សរុប : ១០៣,៨៧០ ដុល្លារ

## ១.២.៣. ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ

ក). ប្រវត្តិ

យោងមាត្រា៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលនីមួយៗត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំតាមរយៈកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ។ ដើម្បីឱ្យក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលនីមួយៗមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទី និងភារកិច្ចដូចមានចែងខាងលើនេះ គ.ជ.អ.ប បានបញ្ចូលប្រធានបទបណ្តុះបណ្តាលស្តីពី ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ទៅក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពី ការកសាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌនឹងផ្តោតលើប្រធានបទសំខាន់ៗមួយចំនួនដូចខាងក្រោម :

- របៀបបង្កើតចក្ខុវិស័យ គោលដៅ គោលបំណងសម្រាប់អភិវឌ្ឍន៍
- របៀបប៉ាន់ស្មានពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់ និងប៉ាន់ស្មានអំពីតម្រូវការអភិវឌ្ឍន៍សំខាន់ៗ
- របៀបរៀបចំបង្កើតក្របខ័ណ្ឌអភិវឌ្ឍន៍
- ជំហាននៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- របៀបរៀបចំផែនការហិរញ្ញវត្ថុ
- របៀបបង្កើតយុទ្ធសាស្ត្រអនុវត្តផែនការឱ្យមានតម្លាភាព និងគណនេយ្យភាព

ក្រុមការងាររៀបចំមេរៀនមួយនឹងត្រូវបង្កើតឡើង ដែលមានសមាសភាពមន្ត្រីមកពីក្រុមគោលនយោបាយ ការិយាល័យពាក់ព័ន្ធនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងគម្រោងគាំទ្រការអភិវឌ្ឍបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) មន្ត្រីមកពីក្រសួងផែនការ ព្រមទាំងក្រសួង និងអ្នកពាក់ព័ន្ធដទៃទៀត។ ក្រុមការងារនេះនឹងរៀបចំខ្លឹមសារមេរៀន និងវិធីសាស្ត្របណ្តុះបណ្តាលដោយផ្អែកលើខ្លឹមសារច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឯកសារក្របខ័ណ្ឌច្បាប់ផ្សេងៗទៀត ឯកសារណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ព្រមទាំងឯកសារពាក់ព័ន្ធដទៃទៀត។ បន្ទាប់ពីរៀបចំសេចក្តីព្រាងរួច ក្រុមការងារត្រូវដាក់សេចក្តីព្រាងនោះជូនទៅថ្នាក់ដឹកនាំ គ.ជ.អ.ប ពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលបានការឯកភាពពី គ.ជ.អ.ប ផ្អែក

កសាងសមត្ថភាព និងព័ត៌មាននៃក្រុមគោលនយោបាយ និងក្រុមការងាររៀបចំមេរៀននឹងរៀបចំការបណ្តុះបណ្តាលសាកល្បងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

**គ). យុទ្ធសាស្រ្តបណ្តុះបណ្តាល**

បន្ទាប់ពីការបណ្តុះបណ្តាលសាកល្បង និងកែសម្រួលរួចរាល់ ផ្នែកកសាងសមត្ថភាពនៃក្រុមគោលនយោបាយសហការជាមួយការិយាល័យអប់រំនិងកសាងសមត្ថភាព និងក្រុមការងាររៀបចំមេរៀននឹង :

- **ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ** : ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងជាបីដំណាក់កាលដូចខាងក្រោម :
  - **បណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ** : បណ្តុះបណ្តាលគ្រូបង្គោលមកពីរាជធានី និងខេត្តទាំង២៣នៅថ្នាក់ជាតិ។ ដូច្នេះរាជធានី និងខេត្តនីមួយៗត្រូវចាត់បញ្ជូនមន្ត្រីចំនួនពី២ទៅ៦រូបដើម្បីចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលមកពីខេត្ត និងរាជធានីនៅថ្នាក់ជាតិ ដែលមានសិក្ខាកាមសរុប៧២រូប ដោយបែងចែកជា២ថ្នាក់។
  - **បណ្តុះបណ្តាលគ្រូឧទ្ទេសនៅថ្នាក់រាជធានី ខេត្ត** : គ្រូបង្គោលដែលមកពីរាជធានី និងខេត្តនីមួយៗនឹងធ្វើការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ខេត្ត។ សិក្ខាកាមដែលត្រូវចូលរួមបណ្តុះបណ្តាលគ្រូឧទ្ទេសនៅថ្នាក់ខេត្តនេះអាចជាអ្នកសម្របសម្រួលខេត្ត ឬអ្នកដែលមានតួនាទីក្នុងការជួយគាំទ្រក្រុង ស្រុក ខណ្ឌ។ រាជធានី និងខេត្តនីមួយៗនឹងបណ្តុះបណ្តាលគ្រូឧទ្ទេសតែមួយថ្នាក់ប៉ុណ្ណោះ។
  - **ការបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ** : គ្រូឧទ្ទេសថ្នាក់រាចធានី ខេត្ត ត្រូវធ្វើការបណ្តុះបណ្តាលដល់គ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌនៅតាមខេត្ត និងរាជធានីរបស់ខ្លួន។ អ្នកចូលរួមមកពីថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមានគ្រប់សមាជិកក្រុមប្រឹក្សាទាំងអស់ គ្រប់គណៈអភិបាលទាំងអស់ទាំងអស់ និង២នាក់មកពីអង្គភាពអនុវត្ត។ ការបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើង នៅតាមក្រុង ស្រុក ខណ្ឌនីមួយៗ។

  **ការបណ្តុះបណ្តាលមួយវគ្គៗមានរយៈពេល : ០៣ថ្ងៃ**

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែមករា-ឧសភា ឆ្នាំ២០០៩ : ការរៀបចំឯកសារ និងការបណ្តុះបណ្តាលសាកល្បង
- ខែកក្កដា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ខេត្ត
- ខែសីហា-កញ្ញា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលដល់ក្រុមគោលដៅ

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលគ្រូបង្គោលមកពីខេត្ត រាជធានី : ១១,៦៥៤ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត រាជធានី : ១,២២៥ ដុល្លារ
- ការបណ្តុះបណ្តាលក្រុមប្រឹក្សា និងគណៈអភិបាលក្រុង ស្រុក ខណ្ឌ : ២៣,១៦២ដុល្លារ

**សរុប : ៣៦,០៤១ ដុល្លារ**

## ១.២.៤. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ

### ក). ប្រវត្តិ

យោងមាត្រា២៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលនីមួយៗត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាល។ ដើម្បីឱ្យក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលរាជធានី និងខេត្ត មានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទី និងភារកិច្ចដូចមានចែងខាងលើនេះ គ.ជ.អ.ប បានបញ្ចូលប្រធានបទបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ទៅក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ នឹងផ្តោតលើប្រធានបទសំខាន់ៗមួយចំនួនដូចខាងក្រោម :

- ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ
- ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រព័ន្ធទូទាត់ និងគណនេយ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- របាយការណ៍ហិរញ្ញវត្ថុ និងការបិទបញ្ជីថវិកា
- តម្លាភាព និងគណនេយ្យភាព ។ល។

ក្រុមការងាររៀបចំមេរៀនមួយ នឹងត្រូវបង្កើតឡើងដែលមានសមាសភាពមន្ត្រីមកពីផ្នែកនានានៃក្រុមគោលនយោបាយ ការិយាល័យនានានៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងគម្រោងគាំទ្រការអភិវឌ្ឍបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) តំណាងមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រតនាគារជាតិ ព្រមទាំងក្រសួង និងអ្នកពាក់ព័ន្ធដទៃទៀត។ ក្រុមការងារនេះនឹងពិនិត្យលើខ្លឹមសារច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឯកសារក្របខណ្ឌច្បាប់ផ្សេងៗទៀត និងឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ព្រមទាំងឯកសារពាក់ព័ន្ធដទៃទៀត ដើម្បីរៀបចំខ្លឹមសារមេរៀន និងវិធីសាស្ត្របណ្តុះបណ្តាល ហើយដាក់ជូន គ.ជ.អ.ប ពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលបានការឯកភាពពី គ.ជ.អ.ប ផ្នែកកសាងសមត្ថភាពនៃក្រុមគោលនយោបាយ និងក្រុមការងាររៀបចំមេរៀននឹងរៀបចំការបណ្តុះបណ្តាលសាកល្បងជាមួយរដ្ឋបាលរាជធានី ឬខេត្ត។

### គ). យុទ្ធសាស្ត្របណ្តុះបណ្តាល

បន្ទាប់ពីការបណ្តុះបណ្តាលសាកល្បង និងកែសម្រួលរួចរាល់ ផ្នែកកសាងសមត្ថភាពនៃក្រុមគោលនយោបាយសហការជាមួយការិយាល័យអប់រំ និងកសាងសមត្ថភាព និងក្រុមការងាររៀបចំមេរៀននឹងបណ្តុះបណ្តាលដល់ :

**គ.១). ថ្នាក់រាជធានី ខេត្ត**

- **សម្រាប់ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី និងខេត្ត :** គ្រូបណ្តុះបណ្តាលថ្នាក់ជាតិនឹងបណ្តុះបណ្តាលដោយផ្ទាល់ដល់គ្រប់ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តទាំងអស់។ សិក្ខាកាមចូលរួមសរុបក្នុងការបណ្តុះបណ្តាលផ្ទាល់នេះមានចំនួនប្រមាណ៥១១រូប ហើយត្រូវរៀបចំបណ្តុះបណ្តាលជាលក្ខណៈសិក្ខាសាលាផ្សព្វផ្សាយចំនួន៦លើក ដែលមួយលើកៗមានសិក្ខាកាមចូលរួមមកពី៤ខេត្ត។
- **សម្រាប់អង្គភាពអនុវត្ត :** គ្រូបណ្តុះបណ្តាលថ្នាក់ជាតិនឹងធ្វើការបណ្តុះបណ្តាលដោយផ្ទាល់ដល់អង្គភាពទទួលបន្ទុករៀបចំ និងអនុវត្តកិច្ចការហិរញ្ញវត្ថុរបស់រាជធានី ខេត្ត។ ដូច្នេះរាជធានី និងខេត្តនីមួយៗត្រូវចាត់បញ្ជូនមន្ត្រីទទួលបន្ទុកអនុវត្តកិច្ចការហិរញ្ញវត្ថុរាជធានី ខេត្ត ចំនួន៣រូបមកចូលរួមការបណ្តុះបណ្តាលអំពី ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិនៅថ្នាក់ជាតិ។ សិក្ខាកាមចូលរួមសរុបក្នុងការបណ្តុះបណ្តាលផ្ទាល់នេះមានចំនួនប្រមាណ៧២រូប ហើយត្រូវរៀបចំជាការបណ្តុះបណ្តាលលម្អិតចំនួន២ថ្នាក់ ដែលមួយថ្នាក់ៗមានសិក្ខាកាមចូលរួមប្រមាណ៣៦រូប។

**គ.២). ថ្នាក់ក្រុង ស្រុក ខណ្ឌ**

- **ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ :** ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងជាបីដំណាក់កាលដូចខាងក្រោម :
  - **បណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ :** បណ្តុះបណ្តាលគ្រូបង្គោលមកពីរាជធានី និងខេត្តទាំង២៣នៅថ្នាក់ជាតិ។ ដូច្នេះរាជធានី និងខេត្តនីមួយៗត្រូវចាត់បញ្ជូនមន្ត្រីចំនួនពី២ទៅ៦រូបដើម្បីចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលមកពីខេត្ត និងរាជធានីនៅថ្នាក់ជាតិ ដែលមានសិក្ខាកាមសរុប៧២រូប ដោយបែងចែកជា២ថ្នាក់។
  - **បណ្តុះបណ្តាលគ្រូឧទ្ទេសនៅថ្នាក់រាជធានី ខេត្ត :** គ្រូបង្គោលដែលមកពីរាជធានី និងខេត្តនីមួយៗនឹងធ្វើការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ខេត្ត។ សិក្ខាកាមដែលត្រូវចូលរួមបណ្តុះបណ្តាលគ្រូឧទ្ទេសនៅថ្នាក់ខេត្តនេះអាចជាអ្នកសម្របសម្រួលខេត្ត ឬអ្នកដែលមានតួនាទីក្នុងការជួយគាំទ្រក្រុង ស្រុក ខណ្ឌ។ រាជធានី និងខេត្តនីមួយៗនឹងបណ្តុះបណ្តាលគ្រូឧទ្ទេសតែមួយថ្នាក់ប៉ុណ្ណោះ។
  - **ការបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ :** គ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត ត្រូវធ្វើការបណ្តុះបណ្តាលដល់គ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌនៅតាមខេត្ត និងរាជធានីរបស់ខ្លួន។ អ្នកចូលរួមមកពីថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមានគ្រប់សមាជិកក្រុមប្រឹក្សាទាំងអស់ គ្រប់គណៈអភិបាលទាំងអស់ទាំងអស់ និង២នាក់មកពីអង្គភាពអនុវត្ត។ ការបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងនៅតាមក្រុង ស្រុក ខណ្ឌនីមួយៗ។

**ការបណ្តុះបណ្តាលមួយវគ្គៗមានរយៈពេល : ០៣ថ្ងៃ**

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែមីនា-កក្កដា ឆ្នាំ២០០៩ : ការរៀបចំឯកសារ និងការបណ្តុះបណ្តាលសាកល្បង
- ខែកញ្ញា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ខេត្ត
- ខែតុលា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលដល់ក្រុមគោលដៅ

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត : ៩៣,០២៨ដុល្លារ
- ការបណ្តុះបណ្តាលអង្គភាពអនុវត្តថ្នាក់រាជធានី ខេត្ត : ១០,៨១៦ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូបង្គោលមកពីខេត្ត រាជធានី : ១១,៦៥៤ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត រាជធានី : ១,២២៥ ដុល្លារ
- ការបណ្តុះបណ្តាលថ្នាក់ក្រុង ស្រុក ខណ្ឌ : ២៣,១៦២ ដុល្លារ

**សរុប : ១៣៩,៨៨២ ដុល្លារ**

## ១.២.៥. ការអនុវត្តគម្រោងថ្នាក់ក្រុង ស្រុក ខណ្ឌ

ក). ប្រវត្តិ

ដោយផ្អែកតាមបទពិសោធន៍នៃការអនុវត្តគម្រោងសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌកន្លងមក ក្រុមប្រឹក្សាស្រុក ខណ្ឌដែលទើបជាប់ឆ្នោតចាំបាច់ត្រូវមានចំណេះដឹងមូលដ្ឋានអំពីរបៀបអនុវត្តគម្រោងនៅថ្នាក់ស្រុក ខណ្ឌ ទើបអាចអនុវត្តសកម្មភាព ឬគម្រោងអភិវឌ្ឍន៍នានានៅក្នុងស្រុក ខណ្ឌរបស់ខ្លួនបានត្រឹមត្រូវ និងទទួលលទ្ធផលល្អ។ ដោយយល់ឃើញពីភាពចាំបាច់នៃការកសាងសមត្ថភាពក្រុមប្រឹក្សាស្រុក ខណ្ឌដែលទើបជាប់ឆ្នោតអំពីរបៀបអនុវត្តគម្រោង ទើប គ.ជ.អ.ប បានបញ្ចូលប្រធានបទបណ្តុះបណ្តាលស្តីពី **ការអនុវត្តគម្រោងថ្នាក់ស្រុកខណ្ឌ** ទៅក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

ខ). **ខ្លឹមសារនៃការបណ្តុះបណ្តាល**

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពីការអនុវត្តគម្រោងថ្នាក់ស្រុក ខណ្ឌ នឹងផ្តោតលើប្រធានបទសំខាន់ៗមួយចំនួនដូចខាងក្រោម :

- ទិដ្ឋភាពទូទៅនៃការអនុវត្តគម្រោង
- ការរៀបចំ និងការពិនិត្យបញ្ជាក់បច្ចេកទេស
- លទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា
- ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ...។ល។

ក្រុមការងាររៀបចំមេរៀនមួយ នឹងត្រូវបង្កើតឡើងដែលមានសមាសភាពមន្ត្រីមកពីផ្នែកកសាងសមត្ថភាព និង

ព័ត៌មាននៃក្រុមគោលនយោបាយ ការិយាល័យនានានៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន មន្ត្រីគម្រោងសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌ និងគម្រោងគាំទ្រការអភិវឌ្ឍបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) ព្រមទាំងអ្នកពាក់ព័ន្ធដទៃទៀត។ ក្រុមការងារនេះនឹងពិនិត្យលើខ្លឹមសារច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជ ធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឯកសារក្របខ័ណ្ឌច្បាប់ផ្សេងៗទៀត និងឯកសារណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ព្រមទាំងឯកសារពាក់ព័ន្ធដទៃទៀតដើម្បីរៀបចំខ្លឹមសារមេរៀន និងវិធីសាស្ត្របណ្តុះបណ្តាល ហើយដាក់ជូន គ.ជ.អ.ប ពិនិត្យ និងអនុម័ត។

គ). **យុទ្ធសាស្ត្របណ្តុះបណ្តាល**

- **ថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ** : ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងជាបីដំណាក់កាលដូចខាងក្រោម :
  - **បណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ** : បណ្តុះបណ្តាលគ្រូបង្គោលមកពីរាជធានី និងខេត្តទាំង២៣នៅថ្នាក់ជាតិ។ ដូច្នេះរាជធានី និងខេត្តនីមួយៗត្រូវចាត់បញ្ជូនមន្ត្រីចំនួនពី២ទៅ៦រូប ដើម្បីចូលរួមការបណ្តុះបណ្តាលគ្រូបង្គោលមកពីខេត្ត និងរាជធានីនៅថ្នាក់ជាតិ ដែលមានសិក្ខាកាមសរុប៧២រូប ដោយបែងចែកជា២ថ្នាក់។
  - **បណ្តុះបណ្តាលគ្រូឧទ្ទេសនៅថ្នាក់រាជធានី ខេត្ត** : គ្រូបង្គោលដែលមកពីរាជធានី និងខេត្តនីមួយៗនឹងធ្វើការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ខេត្ត។ សិក្ខាកាមដែលត្រូវចូលរួមបណ្តុះបណ្តាលគ្រូឧទ្ទេសនៅថ្នាក់ខេត្តនេះអាចជាអ្នកសម្របសម្រួលខេត្ត ឬអ្នកដែលមានតួនាទីក្នុងការជួយគាំទ្រ ក្រុង ស្រុក ខណ្ឌ។ រាជធានី និងខេត្តនីមួយៗនឹងបណ្តុះបណ្តាលគ្រូឧទ្ទេសតែមួយថ្នាក់ប៉ុណ្ណោះ។
  - **ការបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ** : គ្រូឧទ្ទេសថ្នាក់រាចធានី ខេត្ត ត្រូវធ្វើការបណ្តុះបណ្តាលដល់គ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌនៅតាមខេត្ត និងរាជធានីរបស់ខ្លួន។ អ្នកចូលរួមមកពីថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមានគ្រប់សមាជិកក្រុមប្រឹក្សាទាំងអស់ គ្រប់គណៈអភិបាលទាំងអស់ទាំងអស់ និង២នាក់មកពីអង្គភាពអនុវត្ត។ ការបណ្តុះបណ្តាលនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើង នៅតាមក្រុង ស្រុក ខណ្ឌនីមួយៗ។

    **ការបណ្តុះបណ្តាលមួយវគ្គៗមានរយៈពេល : ០៣ថ្ងៃ**

ឃ). **ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែឧសភា-សីហា ឆ្នាំ២០០៩ : ការរៀបចំឯកសារ
- ខែ តុលា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ
- ខែ វិច្ឆិកា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលដល់ក្រុមគោលដៅ

ង). **ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល : ៦,៩៥០ដុល្លារ**

### ១.២.៦. វគ្គបណ្តុះបណ្តាលអង្គភាពគាំទ្រឃុំ សង្កាត់ នៅថ្នាក់ស្រុក

ក). ប្រវត្តិ

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា ១៨១ បានចែងថា "ក្រុមប្រឹក្សាស្រុកខណ្ឌត្រូវមានអង្គភាពមួយសម្រាប់គាំទ្រឃុំសង្កាត់..." នេះបានសេចក្តីថា ថ្នាក់ស្រុកខណ្ឌមានតួនាទីក្នុងការគាំទ្រឃុំ សង្កាត់ ដែលចាំបាច់អង្គភាពនេះត្រូវមានលទ្ធភាព និងសមត្ថភាពបច្ចេកទេសគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចនេះ។ នៅក្នុងឆ្នាំ២០០៩ ខាងមុខនេះ រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចនៅថ្នាក់ស្រុក ខណ្ឌ នឹងត្រូវបានរៀបចំឡើងយោងតាមច្បាប់ និងលិខិតបទដ្ឋាននានា។ គម្រោង DDLG នឹងពិភាក្សាជាមួយនឹងលេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធនានាក្នុងការគាំទ្រ និងកសាងសមត្ថភាពដល់អង្គភាពគាំទ្រឃុំ សង្កាត់ នៅថ្នាក់ស្រុកខណ្ឌនេះ។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ប្រធានបទសំខាន់ៗសម្រាប់ការកសាងសមត្ថភាពនឹងត្រូវពិភាក្សា នឹងរៀបចំជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ។

គ). យុទ្ធសាស្រ្តនៃការបណ្តុះបណ្តាល

ក្រុមការងារសហប្រតិបត្តការអន្តរឃុំ សង្កាត់ នឹងពិភាក្សាជាមួយការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និង អ្នកជាប់ពាក់ព័ន្ធនានា អំពីយុទ្ធសាស្រ្តដែលត្រូវអនុវត្ត។

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

ក្រុមការងារសហប្រតិបត្តការអន្តរឃុំ សង្កាត់ នឹងពិភាក្សាជាមួយការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងអ្នកជាប់ពាក់ព័ន្ធនានា អំពីពេលវេលាសម្រាប់ការបណ្តុះបណ្តាល នៅគ្រប់លំដាប់ថ្នាក់។

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

ជារួម គម្រោង DDLG បានត្រៀមថវិកាប្រមាណជា**៥៤.០០០**ដុល្លារអាមេរិក ដើម្បីរួមចំណែកដល់ការកសាងសមត្ថភាពអង្គភាពគាំទ្រឃុំ សង្កាត់នៅថ្នាក់ស្រុក ខណ្ឌ។

## ១.៣. សិក្ខាសាលា

### ១.៣.១. សិក្ខាសាលាផ្សព្វផ្សាយអំពីច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ក). ប្រវត្តិ

សិក្ខាសាលាផ្សព្វផ្សាយអំពីច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទៅគ្រប់អ្នកពាក់ព័ន្ធទាំងអស់ដោយរួមបញ្ចូលទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ព្រមទាំងអង្គការសង្គមស៊ីវិលផងដែរ។ តាមរយៈបទពិសោធន៍កន្លងមក សិក្ខាសាលានេះបានជួយដល់ការកសាងសមត្ថភាពដល់មន្ត្រីរបស់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ដែលអ្នកទាំងនោះ គឺជាតួអង្គសំខាន់ក្នុងការជួយគាំទ្រ និងអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា។

ដោយយល់ឃើញពីភាពចាំបាច់នៃការកសាងសមត្ថភាពដល់មន្ត្រីជាន់ខ្ពស់ គ.ជ.អ.ប បានសម្រេចដាក់សិក្ខាសាលាផ្សព្វផ្សាយអំពីច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទៅក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

ខ). ខ្លឹមសារ

ប្រធានបទសំខាន់ៗនៃសិក្ខាសាលានេះ ផ្តោតជាចម្បងលើទស្សនៈទាននៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

គ). យុទ្ធសាស្ត្រ

- **សម្រាប់សមាជិករាជរដ្ឋាភិបាល** : សិក្ខាសាលានឹងត្រូវធ្វើឡើងសម្រាប់សមាជិករាជរដ្ឋាភិបាលដែលមានតួនាទីចាប់ពីរដ្ឋលេខាធិការរហូតដល់រដ្ឋមន្ត្រី ព្រមទាំងអនុរដ្ឋលេខាធិការនៃក្រសួងទាំងអស់របស់រដ្ឋាភិបាល ដែលមានសិក្ខាកាមសរុបចំនួន៤៤៦រូប។ សិក្ខាសាលាត្រូវរៀបចំជាពីរលើកនៅទីស្តីការក្រសួងមហាផ្ទៃ ដែលត្រូវធ្វើបទបង្ហាញដោយថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ។ សិក្ខាសាលាមួយលើកៗមានរយៈពេលកន្លះថ្ងៃ (១ព្រឹក)។
- **សម្រាប់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល** : សិក្ខាសាលានឹងត្រូវធ្វើឡើងសម្រាប់មន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដែលមានតួនាទីចាប់ពីប្រធាននាយកដ្ឋានដល់អគ្គនាយកគ្រប់ក្រសួងទាំងអស់ ដែលមានចំនួនសរុបប្រមាណ៧៧៩រូប។ សិក្ខាសាលានេះអាចរៀបចំឡើងចំនួន៧លើក ដែលមួយលើកៗមានរយៈពេល១ថ្ងៃ និងមានសិក្ខាកាមចូលរួមប្រមាណ១០០រូប។ ក្នុងដំណើរការនៃអង្គសិក្ខាសាលា វាគ្មិនដែលជាថ្នាក់ដឹកនាំរបស់ គ.ជ.អ.ប ឬក្រសួងមហាផ្ទៃនឹងធ្វើបទឧទ្ទេសនាមអំពីខ្លឹមសារនៃទស្សនៈទានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការពិភាក្សា និងមានកម្មវិធីសំណួរ-ចម្លើយ។
- **សម្រាប់មន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ** : សិក្ខាសាលាផ្សព្វផ្សាយនឹងគ្រោងធ្វើឡើងសម្រាប់មន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃចំនួន១០០រូបផងដែរ។ សិក្ខាសាលា

នេះអាចរៀបចំឡើងចំនួន១លើក ដែលមានរយៈពេល១ថ្ងៃ។ ក្នុងដំណើរការនៃអង្គសិក្ខាសាលានេះ វាគ្មិនដែលជាថ្នាក់ដឹកនាំរបស់ គ.ជ.អ.ប ឬក្រសួងមហាផ្ទៃនឹងធ្វើបទឧទ្ទេសនាមអំពីខ្លឹមសារនៃទស្សនៈទានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការពិភាក្សា និងមានកម្មវិធីសំណួរ-ចម្លើយ។

- **សម្រាប់ថ្នាក់ក្រោមជាតិ** : សិក្ខាសាលានឹងត្រូវធ្វើឡើងសម្រាប់មន្ត្រីរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលទាំង :
    - មន្ត្រីនៃផ្នែកទាំង៥របស់សាលាខេត្ត (១ផ្នែក២រូប) សរុប២៤០រូប
    - ប្រធាន និងអនុប្រធាន១រូបមកពីគ្រប់មន្ទីរនៅក្នុងខេត្ត សរុប១១៥២រូប
    - គ្រប់អភិបាល និងអភិបាលរងស្រុក សរុប១១០៥រូប

  សិក្ខាសាលានេះអាចរៀបចំឡើងនៅតាមរាជធានី ខេត្តនីមួយៗ ដែលមានចំនួនពី១ទៅ២វគ្គក្នុងមួយខេត្ត។ មួយវគ្គៗមានសិក្ខាកាមប្រមាណចំនួន១០០រូប និងមានរយៈពេល១ថ្ងៃ។ ក្នុងដំណើរការនៃអង្គសិក្ខាសាលា វាគ្មិនដែលជាថ្នាក់ដឹកនាំរបស់ គ.ជ.អ.ប ឬក្រសួងមហាផ្ទៃនឹងធ្វើបទឧទ្ទេសនាមអំពីខ្លឹមសារនៃទស្សនៈទានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការពិភាក្សា និងមានកម្មវិធីសំណួរ-ចម្លើយ។

- **សម្រាប់សង្គមស៊ីវិល** : គ.ជ.អ.ប នឹងធ្វើការបណ្តុះបណ្តាលអំពីច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដល់គ្រូបង្គោលមកពីអង្គការសង្គមស៊ីវិល។ សិក្ខាកាមចំនួន៣០រូបមកពីអង្គការសង្គមស៊ីវិលនឹងត្រូវបានអញ្ជើញតាមរយៈការិយាល័យទំនាក់ទំនងជាមួយអង្គការសង្គមស៊ីវិល (NLO) ឱ្យចូលរួមវគ្គបណ្តុះបណ្តាលគ្រូឧទ្ទេស។ ការបណ្តុះបណ្តាលគ្រូឧទ្ទេសមានរយៈពេល២ថ្ងៃ ហើយត្រូវសម្របសម្រួលដោយគ្រូបណ្តុះបណ្តាលដែលជាថ្នាក់ដឹកនាំមកពីក្រសួងមហាផ្ទៃ ឬ គ.ជ.អ.ប។

**ឃ). ពេលវេលានៃការរៀបចំវគ្គសិក្ខាសាលា**

- ខែ កុម្ភៈ-តុលា ឆ្នាំ២០០៩ : សិក្ខាសាលា

**ង). ថវិកាគ្រោងសម្រាប់វគ្គសិក្ខាសាលា**

- សម្រាប់សមាជិករាជរដ្ឋាភិបាល : ៣,៨៩២ដុល្លារ
- សម្រាប់មន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាល : ១៧,៥០០ ដុល្លារ
- សម្រាប់មន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន : ២,៧១០ ដុល្លារ
- សម្រាប់មន្ត្រីថ្នាក់ក្រោមជាតិ : ២២,៥៧៥ ដុល្លារ
- សម្រាប់សង្គមស៊ីវិល : ១,៣៣០ ដុល្លារ

**សរុប : ៤៨,០០៧ដុល្លារ**

## ១.៤. ការអប់រំផ្សព្វផ្សាយសាធារណៈ

### ១.៤.១. ការបោះពុម្ពសៀវភៅផ្សព្វផ្សាយ

ក). ប្រវត្តិ

ដោយសារការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជារបត់មួយថ្មីសម្រាប់កម្ពុជា ហើយប្រជាពលរដ្ឋមួយចំនួនធំនៅមូលដ្ឋានអាចនឹងមិនទាន់បានទទួលព័ត៌មានច្បាស់អំពីរបៀបអនុវត្ត និងសារៈប្រយោជន៍នៃកំណែទម្រង់នេះ ទើប គ.ជ.អ.ប ដាក់ **ការបោះពុម្ពសៀវភៅផ្សព្វផ្សាយ** ចូលក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

ខ). ខ្លឹមសារ

ដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សៀវភៅផ្សព្វផ្សាយនឹងផ្តោតលើខ្លឹមសារចំនួនដូចខាងក្រោម :

- ទស្សនៈទាននៃច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ទស្សនៈទាននៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ
- ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តកំណែទម្រង់

គ). យុទ្ធសាស្ត្រ

ផ្អែកកសាងសមត្ថភាព និងព័ត៌មានរបស់ក្រុមគោលនយោបាយនឹងរៀបចំសេចក្តីព្រាងអំពីខ្លឹមសារសៀវភៅផ្សព្វផ្សាយ។ សៀវភៅផ្សព្វផ្សាយត្រូវមានលក្ខណៈសាមញ្ញ ខ្លឹមសារងាយយល់ និងមានបញ្ចូលរូបភាពទាក់ទាញ។ បន្ទាប់ពីរៀបចំសេចក្តីព្រាងរួច ក្រុមការងារនឹងដាក់ជូនសេចក្តីព្រាងនេះទៅថ្នាក់ដឹកនាំ គ.ជ.អ.ប ពិនិត្យ និងផ្តល់យោបល់។ ផ្អែកលើអនុសាសន៍របស់ថ្នាក់ដឹកនាំ ក្រុមការងារនឹងធ្វើការកែសម្រួលខ្លឹមសារឡើងវិញ ហើយដាក់ជូនថ្នាក់ដឹកនាំ គ.ជ.អ.ប ពិនិត្យ និងអនុម័ត។ តាមរយៈការអនុម័តយល់ព្រមពីថ្នាក់ដឹកនាំ គ.ជ.អ.ប ក្រុមការងារនឹងរៀបចំបោះពុម្ពសៀវភៅចំនួន២៨៧៧០ក្បាល ដោយបែងចែកទៅគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ រួមទាំងថ្នាក់ឃុំ សង្កាត់ និងបែងចែកទៅដល់ក្រសួង មន្ទីរ អង្គការសង្គមស៊ីវិល ស្ថាប័នរដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាកំណែទម្រង់ ព្រមទាំងអ្នកពាក់ព័ន្ធដទៃទៀតផងដែរ។

**ឃ). ពេលវេលានៃការរៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន**

- ខែកុម្ភៈ ឆ្នាំ២០០៩ : ការរៀបចំខ្លឹមសារ
- ខែកុម្ភៈ ឆ្នាំ២០០៩ : បោះពុម្ព និងបែងចែក

**ង). ថវិកាគ្រោងសម្រាប់រៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន**

- **ការរៀបចំ និងបោះពុម្ព : ២៩,៥៧០ ដុល្លារ**

### ១.៤.២. ការបោះពុម្ពផ្ទាំងរូបភាពផ្សព្វផ្សាយ

ក). ប្រវត្តិ

ដោយសារការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការគឺជារបត់មួយថ្មីសម្រាប់កម្ពុជា ហើយប្រជាពលរដ្ឋមួយចំនួនធំនៅមូលដ្ឋានអាចនឹងមិនទាន់បានទទួលព័ត៌មានច្បាស់អំពីរបៀបអនុវត្ត និងសារៈប្រយោជន៍នៃកំណែទម្រង់នេះ។ ទន្ទឹមនោះ ដោយផ្អែកតាមការសិក្សាអំពីតម្រូវការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩ ក្រុមអ្នកផ្តល់ព័ត៌មានភាគច្រើនបានផ្តល់យោបល់ថា មធ្យោបាយផ្សព្វផ្សាយព័ត៌មានដែលល្អសមស្រប និងងាយយល់ សម្រាប់សហគមន៍គឺផ្ទាំងរូបភាពផ្សព្វផ្សាយព័ត៌មាន ហេតុនេះហើយទើប គ.ជ.អ.ប បញ្ចូល **ការបោះពុម្ពផ្ទាំងរូបភាពផ្សព្វផ្សាយ** ចូលក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

ខ). ខ្លឹមសារ

ដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ផ្ទាំងរូបភាពផ្សព្វផ្សាយនឹងផ្តោតលើខ្លឹមសារចំនួនដូចខាងក្រោម :

- ទស្សនៈទាននៃច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ទស្សនៈទាននៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ
- ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តកំណែទម្រង់

គ). យុទ្ធសាស្ត្រ

ផ្នែកកសាងសមត្ថភាព និងព័ត៌មានរបស់ក្រុមគោលនយោបាយនឹងរៀបចំសេចក្តីព្រាងអំពីខ្លឹមសារផ្ទាំងរូបភាពផ្សព្វផ្សាយចំនួនបីប្រធានបទ។ ផ្ទាំងរូបភាពផ្សព្វផ្សាយត្រូវមានលក្ខណៈសាមញ្ញ ខ្លឹមសារងាយយល់ និងមានបញ្ចូលរូបភាពទាក់ទាញ។ បន្ទាប់ពីរៀបចំសេចក្តីព្រាងរួច ក្រុមការងារនឹងដាក់ជូនសេចក្តីព្រាងនេះទៅថ្នាក់ដឹកនាំ គ.ជ.អ.ប ពិនិត្យ និងផ្តល់យោបល់។ ផ្អែកលើអនុសាសន៍របស់ថ្នាក់ដឹកនាំ ក្រុមការងារនឹងធ្វើការកែសម្រួលខ្លឹមសារឡើងវិញ ហើយដាក់ជូនថ្នាក់ដឹកនាំ គ.ជ.អ.ប ម្តងទៀតដើម្បីពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលការអនុម័តយល់ព្រមពីថ្នាក់ដឹកនាំ គ.ជ.អ.ប ក្រុមការងារនឹងរៀបចំបោះពុម្ពផ្ទាំងរូបភាពចំនួន១៧១៦៥សន្លឹក/មួយប្រធានបទ ហើយបែងចែកទៅគ្រប់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិទាំងអស់ដោយរួមទាំងថ្នាក់ឃុំ សង្កាត់ អង្គការសង្គមស៊ីវិល មន្ទីរ និងអ្នកពាក់ព័ន្ធដទៃទៀត។

ឃ). ពេលវេលានៃការរៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន

- ខែមីនា ឆ្នាំ២០០៩ : ការរៀបចំខ្លឹមសារ
- ខែមេសា ឆ្នាំ២០០៩ : បោះពុម្ព និងបែងចែក

ង). ថវិកាគ្រោងសម្រាប់រៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន

- **ការរៀបចំ និងបោះពុម្ព : ២៦,៦៤៧ ដុល្លារ**

### ១.៤.៣. កម្មវិធីផ្សព្វផ្សាយតាមវិទ្យុ

**ក). ប្រវត្តិ**

ក្រៅពីធ្វើការបណ្តុះបណ្តាល ប្រជុំ សិក្ខាសាលា វេទិកាសាធារណៈ និងការបោះពុម្ពសៀវភៅផ្សព្វផ្សាយ គ.ជ.អ.ប បានដាក់បញ្ចូលការផ្សព្វផ្សាយព័ត៌មានអំពីការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមវិទ្យុ។ គោលបំណងនៃការផ្សព្វផ្សាយព័ត៌មានតាមវិទ្យុ គឺដើម្បីឱ្យសាធារណជនទូទៅយល់ជ្រួតជ្រាបអំពីការអនុវត្តកំណែទម្រង់ និងចូលរួមក្នុងដំណើរការនៃការអនុវត្ត។

**ខ). ខ្លឹមសារ**

ការផ្សព្វផ្សាយផ្តោតលើខ្លឹមសារមួយចំនួនដូចខាងក្រោម :

- ទស្សនៈទាននៃច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- តួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ( ក្រុមប្រឹក្សា គណៈអភិបាល....)
- ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តគម្រោងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ល។

**គ). យុទ្ធសាស្ត្រ**

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ គ.ជ.អ.ប គ្រោងរៀបចំបង្កើតកម្មវិធីផ្សព្វផ្សាយតាមវិទ្យុដោយធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនផលិតរឿងខ្លី និងផ្សព្វផ្សាយ។ កម្មវិធីដែលគ្រោងរៀបចំក្នុងឆ្នាំ២០០៩ រួមមាន :

- រឿងអប់រំខ្លីចំនួន៩រឿង ដែលរឿងអប់រំខ្លីនីមួយៗមានរយៈពេល៣នាទី ហើយត្រូវផ្សព្វផ្សាយតាមស្ថានីយវិទ្យុនៅថ្នាក់រាជធានីចំនួន២ស្ថានីយ និងវិទ្យុនៅតាមខេត្តក្រុងចំនួន២៣ (១ខេត្តផ្សាយមួយស្ថានីយ)។
- កម្មវិធីសម្ភាសន៍ និងពិភាក្សាតាមវិទ្យុ (Calling in show) ចំនួន១២ដង ជាមួយស្ថានីយវិទ្យុចំនួន១នៅរាជធានី ដែលមួយដងៗមានរយៈពេល៣០នាទី។ វាគ្មិននឹងត្រូវបានអញ្ជើញពីថ្នាក់ដឹកនាំរបស់ គ.ជ.អ.ប ឬថ្នាក់ដឹកនាំរបស់ក្រសួងមហាផ្ទៃ។

**ឃ). ពេលវេលា**

ការផ្សព្វផ្សាយតាមវិទ្យុត្រូវធ្វើឡើងនៅក្នុងខែ កុម្ភៈ ដល់ខែធ្នូ ឆ្នាំ២០០៩។

**ង). ថវិកា**

**ថវិកាគ្រោងសម្រាប់ការផ្សព្វផ្សាយមានចំនួន : ១៥,០០០ ដុល្លារ**

### ១.៤.៤. កម្មវិធីផ្សព្វផ្សាយតាមទូរទស្សន៍

ក). ប្រវត្តិ

ក្រៅពីធ្វើការបណ្តុះបណ្តាល ប្រជុំ សិក្ខាសាលា វេទិកាសាធារណៈ ការបោះពុម្ពសៀវភៅផ្សព្វផ្សាយ និង ការផ្សព្វផ្សាយតាមវិទ្យុ គ.ជ.អ.ប ក៏បានដាក់បញ្ចូលការផ្សព្វផ្សាយព័ត៌មានអំពីការអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការតាមទូរទស្សន៍។ គោលបំណងនៃការផ្សព្វផ្សាយព័ត៌មានតាមទូរទស្សន៍ គឺដើម្បីឱ្យសាធារណៈជនទូទៅ យល់ជ្រួតជ្រាបអំពីការអនុវត្តកំណែទម្រង់ និងចូលរួមក្នុងដំណើរការនៃការអនុវត្ត។

ខ). ខ្លឹមសារ

ការផ្សព្វផ្សាយដោយផ្តោតលើខ្លឹមសារមួយចំនួនដូចខាងក្រោម :

- ទស្សនៈទាននៃច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- តួនាទី និងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ( ក្រុមប្រឹក្សា គណៈអភិបាល....)
- ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តគម្រោងថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

គ). យុទ្ធសាស្ត្រ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ គ.ជ.អ.ប គ្រោងរៀបចំបង្កើតកម្មវិធីផ្សព្វផ្សាយតាមទូរទស្សន៍ ដោយធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនផលិតរឿងខ្លី និងផ្សព្វផ្សាយ។ កម្មវិធីដែលគ្រោងរៀបចំក្នុងឆ្នាំ២០០៩ រួម មាន :

- រឿងអប់រំខ្លីចំនួន៣រឿង ដែលរឿងអប់រំខ្លីនីមួយៗមានរយៈពេល១នាទី ហើយត្រូវផ្សព្វផ្សាយតាម ទូរទស្សន៍ចំនួន៣ស្ថានីយ។
- កម្មវិធីសម្ភាសន៍ និងពិភាក្សាតាមទូរស្សន៍ (Calling in show) ចំនួន៦ដង/ស្ថានីយ (២ខែម្តង) ធ្វើឡើងជាមួយ១ស្ថានីយ ដែលមួយដងៗមានរយៈពេល៣០នាទី។

ឃ). ពេលវេលា

ការផ្សព្វផ្សាយតាមវិទ្យុត្រូវធ្វើឡើងនៅក្នុងខែ មីនា ដល់ខែធ្នូ ឆ្នាំ២០០៩។

ង). ថវិកា

**ថវិកាគ្រោងសម្រាប់ការផ្សព្វផ្សាយមានចំនួន : ៣០,០០០ ដុល្លារ**

## ១.៥. ការបណ្តុះបណ្តាលសម្រាប់ថ្នាក់ជាតិ

### ១.៥.១. ជំនាញបណ្តុះបណ្តាល

ក). ប្រវត្តិ

វគ្គបណ្តុះបណ្តាលស្តីពីជំនាញបណ្តុះបណ្តាលត្រូវបានរៀបចំ និងបណ្តុះបណ្តាលដល់គ្រប់អ្នកសម្របសម្រួល ខេត្ត ក្រុង ស្រុកខណ្ឌទូទាំងប្រទេសកាលពីឆ្នាំ២០០៨។ ដោយយោងតាមផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៨ ប្រធានបទនេះក៏ត្រូវធ្វើការបណ្តុះបណ្តាលដល់មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងមន្ត្រីអគ្គនាយករដ្ឋបាល មូលដ្ឋាន ក្រសួងមហាផ្ទៃផងដែរ។ ប៉ុន្តែដោយពេលវេលាមានកំណត់ និងមានសកម្មភាពសំខាន់ៗ និងបន្ទាន់មួយចំនួន ជាហេតុធ្វើឱ្យអាក់ខានក្នុងការផ្តល់ការបណ្តុះបណ្តាលប្រធានបទនេះដល់ មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងមន្ត្រី អគ្គនាយករដ្ឋបាលមូលដ្ឋាន។ ហេតុនេះហើយទើប គ.ជ.អ.ប សម្រេចដាក់ប្រធានបទស្តីពី ជំនាញបណ្តុះបណ្តាលនេះ ទៅក្នុងផែនការកសាងសមត្ថភាព គ.ជ.អ.ប សម្រាប់ឆ្នាំ២០០៩។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពីជំនាញបណ្តុះបណ្តាល នឹងផ្តោតលើប្រធានបទសំខាន់ៗមួយចំនួនដូចខាងក្រោម :

- ទិដ្ឋភាពទូទៅ
- វិធីសាស្ត្របណ្តុះបណ្តាល
- សម្ភារៈ និងឧបករណ៍សម្រាប់ការបណ្តុះបណ្តាល
- ការរៀបចំវគ្គបណ្តុះបណ្តាល

គ). យុទ្ធសាស្ត្របណ្តុះបណ្តាល

ក្រុមគ្រូបណ្តុះបណ្តាលថ្នាក់ជាតិនឹងបណ្តុះបណ្តាលដល់មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងមន្ត្រីអគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន និងមន្ត្រីក្រុមគោលនយោបាយដែលពាក់ព័ន្ធនឹងការបណ្តុះបណ្តាល៤០រូប។

**ការបណ្តុះបណ្តាលមួយវគ្គមានរយៈពេល : ០៥ថ្ងៃ**

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែកុម្ភៈ ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលផ្ទាល់

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលផ្ទាល់ដល់ក្រុមសិក្ខាកាមគោលដៅ : ៤,០៥៥ ដុល្លារ

សរុប : ៤,០៥៥ ដុល្លារ

## ១.៥.២. កិច្ចប្រជុំត្រួតពិនិត្យមុន និងក្រោយការបណ្តុះបណ្តាល

ក). **ប្រវត្តិ**

កសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាកិច្ចការមួយសំខាន់ និងចាំបាច់បំផុតក្នុងការជំរុញការអនុវត្ត កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា។ ដើម្បីឱ្យការកសាងសមត្ថភាពមានប្រសិទ្ធភាព និងឆ្លើយតប ទៅនឹងគោលបំណង គឺត្រូវពង្រឹងសមត្ថភាពរបស់អ្នកផ្តល់ការកសាងសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិជាមុនសិន ដូច្នេះ គ.ជ.អ.ប ដាក់បញ្ចូលសិក្ខាសាលាស្តីពីការពង្រឹងក្រុមគ្រូបណ្តុះបណ្តាលថ្នាក់ជាតិ ទៅក្នុងផែនការកសាងសមត្ថភាព របស់ គ.ជ.អ.ប ឆ្នាំ២០០៩។

ខ). **ខ្លឹមសារ**

សិក្ខាសាលានឹងផ្តោតជាចម្បងលើ :

- ការពិនិត្យលើផែនការបណ្តុះបណ្តាល
- ការឆ្លុះបញ្ចាំងអំពីបទពិសោធន៍នៃការផ្តល់ការបណ្តុះបណ្តាល
- ការកំណត់មេរៀនល្អៗដែលទទួលបានពីការអនុវត្ត
- បញ្ហា និងការលំបាកនានា
- ការពិភាក្សារកដំណោះស្រាយ
- ...។ល។

គ). **យុទ្ធសាស្ត្រ**

សិក្ខាសាលាត្រូវរៀបចំឡើងចំនួនពីរលើក ដោយលើកទី១សម្រាប់ការពិនិត្យផែនការកសាងសមត្ថភាព និង ការរៀបចំផែនការសកម្មភាព ដោយឡែកសិក្ខាសាលាលើកទី២ត្រូវធ្វើឡើងដើម្បីធ្វើការពិនិត្យលើដំណើការ បទពិសោធន៍ បញ្ហា ការលំបាក និងពិភាក្សារកដំណោះស្រាយនានា ក្នុងទិសដៅដើម្បីពង្រឹងក្រុមគ្រូបណ្តុះបណ្តាលឱ្យមាន សមត្ថភាពគ្រប់គ្រាន់។

ឃ). **ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែកុម្ភៈ ឆ្នាំ២០០៩ : សិក្ខាសាលាលើកទី១
- ខែធ្នូ ឆ្នាំ២០០៩ : សិក្ខាសាលាលើកទី២

ង). **ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការចំណាយសម្រាប់កិច្ចប្រជុំទាំងពីរ : ៣,០១៦ ដុល្លារ

**សរុប : ៣,០១៦ ដុល្លារ**

# ផ្នែកទី២

# ការកសាងសមត្ថភាពសម្រាប់
# គាំទ្ររដ្ឋបាលឃុំ សង្កាត់

## ២.១. លទ្ធផលការកសាងសមត្ថភាពឃុំ សង្កាត់ឆ្នាំ២០០៨

ផែនការកសាងសមត្ថភាពឆ្នាំ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ (គ.ជ.វ.វ) បានគ្រោងវគ្គបណ្តុះបណ្តាលចំនួន២៤ប្រធានបទ សម្រាប់ក្រុមគោលដៅផ្សេងៗគ្នា ការប្រជុំសិក្ខាសាលាចំនួន៩ប្រធានបទ និងការអប់រំផ្សព្វផ្សាយចំនួន២ប្រធានបទ។ ការបណ្តុះបណ្តាលលើប្រធានបទនីមួយៗបានប្រើយុទ្ធសាស្ត្រខុសៗគ្នា អាស្រ័យលើប្រភេទប្រធានបទនីមួយៗ។ ក្នុងឆ្នាំ២០០៨ គ.ជ.វ.វ បានអនុវត្តសកម្មភាពបណ្តុះបណ្តាលដែលគ្រោងក្នុងផែនការចំនួន១៩ប្រធានបទ ការប្រជុំសិក្ខាសាលាចំនួន៦ប្រធានបទ ការអប់រំផ្សព្វផ្សាយ១ប្រធានបទ។

### ២.១.១. ប្រធានបទដែលបានអនុវត្តក្នុងឆ្នាំ២០០៨ រួមមានដូចខាងក្រោម :

☞ **ការបណ្តុះបណ្តាល**

១. ជំនាញបណ្តុះបណ្តាល
២. ការកែតម្រូវទិន្នន័យសៀវភៅអត្រានុកូលដ្ឋាន
៣. ការសម្រុះសម្រួលទំនាស់នៅថ្នាក់ឃុំ សង្កាត់
៤. បញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងយុវវ័យ
៥. វឌ្ឍនភាពគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា
៦. នីតិវិធីជ្រើសរើស និងអនុវត្តគម្រោងសហប្រតិបត្តិការអន្តរឃុំ សង្កាត់ ឆ្លងស្រុកខណ្ឌ
៧. នីតិវិធីជ្រើសរើស និងអនុវត្តគម្រោងសហប្រតិបត្តិការអន្តរឃុំ សង្កាត់
៨. ការធ្វើឱ្យកុមារមានសិទ្ធិពិតប្រាកដ
៩. សកម្មភាពឃុំ សង្កាត់ក្នុងកិច្ចការពារកុមារ
១០. យេនឌ័រនៅក្នុងវិមជ្ឈការ
១១. យេនឌ័រនៅក្នុងការធ្វើផែនការ
១២. រំឭកឡើងវិញអំពីកិច្ចការរដ្ឋបាលឃុំ សង្កាត់
១៣. រំឭកឡើងវិញអំពីកម្មវិធីវិនិយោគឃុំ សង្កាត់
១៤. ការបង្កើតសមាគមក្រុមប្រឹក្សាឃុំ សង្កាត់
១៥. រំឭកឡើងវិញអំពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
១៦. រំឭកឡើងវិញអំពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់
១៧. រំឭកឡើងវិញអំពីជំនាញសម្របសម្រួល
១៨. វិស័យទាក់ទងនឹងកិច្ចការសង្គមនៅក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ
១៩. កំណែទម្រង់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

☞ **សិក្ខាសាលា ប្រជុំ និងការផ្លាស់ប្តូរបទពិសោធន៍**

២០. សិក្ខាសាលាផ្សព្វផ្សាយអំពីការពង្រឹងក្រុមការងារគណនេយ្យភាពមូលនិធិឃុំសង្កាត់នៅថ្នាក់ខេត្ត ក្រុង

២១. សិក្ខាសាលាវាយតម្លៃការអនុវត្តកម្មវិធីពង្រឹងតួនាទីថ្នាក់ស្រុកខណ្ឌប្រចាំឆ្នាំ

២២. បទឧទ្ទេសនាមអំពីក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់សង្គមស៊ីវិល

២៣. បទឧទ្ទេសនាមអំពីក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការសម្រាប់មន្ត្រីរាជការ

២៤. វេទិកាស្ត្រីក្រុមប្រឹក្សាឃុំ

២៥. សិក្ខាសាលាមន្ត្រីជាន់ខ្ពស់

☞ **ការផ្សព្វផ្សាយអប់រំសាធារណៈ**

២៦. វេទិកាសាធារណៈនៅមូលដ្ឋាន

**២.១.២. សកម្មភាព/ប្រធានបទស្ថិតក្នុងការរៀបចំ :**

**១. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុឃុំ សង្កាត់**

ឯកសារបណ្តុះបណ្តាលមេរៀននេះ ស្ថិតនៅក្នុងដំណើរការរៀបចំសេចក្តីព្រាងដែលគ្រោងនឹងបញ្ចប់។ មេរៀននេះត្រូវបានបញ្ចូលក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

**២. ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់**

សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ត្រូវបានពិនិត្យ និងកែសម្រួលឡើងវិញ និងបានបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិក្នុងឆ្នាំ២០០៨ ហើយ ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិនឹងត្រូវអនុវត្តនៅក្នុងឆ្នាំ២០០៩ ដូច្នេះ គ.ជ.អ.ប បញ្ចូលប្រធានបទនេះទៅក្នុងផែនការកសាងសមត្ថភាពឆ្នាំ២០០៩។

ការរៀបចំផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩នេះ ពឹងផ្អែកផងដែរទៅលើលទ្ធផលនៃការសិក្សាវាយតម្លៃតម្រូវការកសាងសមត្ថភាពជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ ជំនួយការឃុំ សង្កាត់ចំនួន ៥៨ឃុំសង្កាត់គោលដៅ និងអ្នកសម្របសម្រួលស្រុកខណ្ឌ ខេត្តក្រុង មន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង និងទីប្រឹក្សារដ្ឋបាលមូលដ្ឋាន នៅខេត្តក្រុងចំនួន១៥គឺ ខេត្តបាត់ដំបង ក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី ស្វាយរៀង ព្រៃវែង កំពង់ចាម កណ្តាល តាកែវ កំពត កំពង់ឆ្នាំង ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ។ លើសពីនេះទៀតផែនការកសាងសមត្ថភាពនេះក៏អាស្រ័យលើលទ្ធផលនៃការសិក្សាតម្រូវការកសាងសមត្ថភាពឃុំសង្កាត់សម្រាប់ឆ្នាំ២០០៨ផងដែរ។

លើសពីនេះទៀត ផែនការកសាងសមត្ថភាពនេះ ក៏បានមកពីការពិភាក្សាជាមួយអង្គភាព ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានារបស់ គ.ជ.អ.ប ផងដែរ។

ថ្វីត្បិតសមត្ថភាពរបស់មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្នុងការរៀបចំចងក្រង និងផ្តល់ការបណ្តុះបណ្តាលបានកើនឡើងគួរឱ្យកត់សម្គាល់ក៏ពិតមែន ប៉ុន្តែទំហំការងារក្នុងការរៀបចំឯកសារបណ្តុះបណ្តាល ការរៀបចំបណ្តុះបណ្តាលថ្នាក់ជាតិ និងការចុះជួយគាំទ្រនៅពេលបណ្តុះបណ្តាលថ្នាក់ខេត្តក្រុង និងថ្នាក់ឃុំសង្កាត់ មានសភាពធំធេង ដូចនេះទាមទារឱ្យមានកិច្ចសហការ និងការចូលរួមចំណែកពីបណ្តាក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានាផងដែរ ។

## ២.២. ប្រធានបទសម្រាប់គាំទ្ររដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០៩

### ២.២.១. វគ្គបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់សម្រាប់គ្រប់ឃុំ សង្កាត់ទាំងអស់

១. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោង កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

២. ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

៣. ភាពជាអ្នកដឹកនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់

៤. ការសរសេរសំណើគម្រោងខ្នាតតូច

៥. រំឭកឡើងវិញអំពីកិច្ចការរដ្ឋបាលឃុំ សង្កាត់

៦. រំឭកឡើងវិញអំពីដំណើរការកសាងកម្មវិធីវិនិយោគឃុំ សង្កាត់

៧. រំឭកឡើងវិញអំពីប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់

៨. រំឭកឡើងវិញអំពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន

### ២.២.២. វគ្គបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់សម្រាប់ឃុំ សង្កាត់គោលដៅរបស់គម្រោងនានា

១. បញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងយុវវ័យ

២. សេចក្តីណែនាំស្តីពីការរៀបចំ និងការគ្រប់គ្រងគម្រោងសេវាកម្ម (គម្រោង ICC)

៣. សេចក្តីណែនាំស្តីពីការរៀបចំ និងការគ្រប់គ្រងគម្រោងសហប្រតិបត្តិការអន្តរឃុំ សង្កាត់

៤. ទស្សនទានទាក់ទងនឹងការអនុវត្តគម្រោងធនធានធម្មជាតិ និងជីវភាពរស់នៅ

៥. គោលការណ៍ណែនាំស្តីពីមូលនិធិទ្រទ្រង់សហគមន៍

៦. ការងាររដ្ឋបាល និងហិរញ្ញវត្ថុគម្រោង

៧. ជំនាញសម្របសម្រួលសម្រាប់បុគ្គលិកគម្រោង

៨. ការរៀបចំសហគមន៍

៩. ការធ្វើផែនការតាមគ្រួសារ

### ២.២.៣. សិក្ខាសាលា ប្រជុំ និងការផ្លាស់ប្តូរបទពិសោធន៍

១. សិក្ខាសាលាស្តីពីការពង្រឹងគណនេយ្យភាពឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុង

២. កម្រងបទឧទ្ទេសនាមសម្រាប់មន្ត្រីរាជការ

៣. កម្រងបទឧទ្ទេសនាមសម្រាប់សង្គមស៊ីវិល

៤. ការផ្លាស់ប្តូរបទពិសោធន៍រវាងក្រុមប្រឹក្សាឃុំ សង្កាត់

៥. ការវាយតម្លៃស្វ័យឃុំ សង្កាត់

៦. វេទិកាបណ្តាញស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

៧. វេទិកាសាធារណៈនៅមូលដ្ឋាន

៨. វេទិកាគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

### ២.២.៤. ការបណ្តុះបណ្តាលថ្នាក់ខេត្ត ក្រុងសម្រាប់គាំទ្រឃុំ សង្កាត់

១. យេនឌ័រក្នុងវិមជ្ឈការ

២. នីតិវិធីស៊ើបអង្កេតពាក្យបណ្តឹង

៣. ប្រព័ន្ធតាមដានត្រួតពិនិត្យ និងរបាយការណ៍

### ២.២.៥. ការផ្សព្វផ្សាយអប់រំសាធារណជន

១. ការផលិតស្ប៉តផ្សព្វផ្សាយតាមទូរទស្សន៍

២. ការផលិតស្ប៉តផ្សព្វផ្សាយតាមវិទ្យុ

## ២.៣. វគ្គបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់សម្រាប់គ្រប់ឃុំ សង្កាត់ទាំងអស់

### ២.៣.១. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោង កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

ក). ប្រវត្តិ

នៅក្នុងឆ្នាំ២០០៣ គ្រប់ឃុំ សង្កាត់ទាំង១.៦២១ បានជ្រើសរើសជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃចំនួន០២រូប (ស្ត្រី១រូប បុរស១រូប) ដោយជ្រើសរើសចេញពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ឬសមាជិកគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់។ ជនបង្គោលទាំងពីររូបនោះបានចូលរួមវគ្គបណ្តុះបណ្តាលមួយមានរយៈពេល២ថ្ងៃក្នុងឆ្នាំ២០០៤។ ខ្លឹមសារនៃវគ្គបណ្តុះបណ្តាលលើកដំបូងនេះផ្តោតទៅលើតួនាទីនិងការទទួលខុសត្រូវរបស់ជនបង្គោលតាមដានត្រួតពិនិត្យនិងវាយតម្លៃ គោលបំណងនិងគោលការណ៍ទូទៅ ឧបករណ៍និងប្រព័ន្ធត្រួតពិនិត្យ របាយការណ៍ត្រួតពិនិត្យនិងលំហូរនៃរបាយការណ៍ និងការកំណត់ពេលវេលាសម្រាប់អនុវត្តសកម្មភាព។ ដើម្បីឱ្យមានលក្ខណៈសាមញ្ញ និងអាចគ្រប់គ្រងបានសម្រាប់គ្រប់ឃុំ សង្កាត់ទាំងអស់ ការបណ្តុះបណ្តាលបានផ្តោតជាសំខាន់តែទៅលើការ

តាមដានត្រួតពិនិត្យលើការអនុវត្តគម្រោងប៉ុណ្ណោះ ដោយមិនរួមបញ្ចូលការវាយតម្លៃគម្រោងទេ។ លើសពីនេះទៀត ការបណ្តុះបណ្តាលនោះ ក៏មិនបានផ្តោតលើផ្នែកពាក់ព័ន្ធផ្សេងៗ ដូចជា ការផ្តល់សេវាកម្ម ការគ្រប់គ្រងរដ្ឋបាល និង ការគ្រប់គ្រងហិរញ្ញវត្ថុនោះទេ។ ហេតុនេះហើយទើប គ.ជ.អ.ប សម្រេចដាក់បញ្ចូលវគ្គបណ្តុះបណ្តាលស្តីពី**ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោង កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុឃុំ សង្កាត់** ទៅក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៨។ ដោយសារមានសកម្មភាពច្រើនដែលសំខាន់ និងបន្ទាន់ត្រូវអនុវត្ត ហេតុនេះហើយទើប មេរៀននេះត្រូវបានពន្យារពេលមកអនុវត្តក្នុងឆ្នាំ២០០៩វិញ។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពី**ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ** សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ មានបីផ្នែកសំខាន់ៗ គឺ**ការអនុវត្តគម្រោង កិច្ចការរដ្ឋបាលឃុំ សង្កាត់ និងប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់**។

☞ ការតាមដានត្រួតពិនិត្យលើការអនុវត្តគម្រោងឃុំ សង្កាត់នឹងផ្តោតទៅលើប្រធានបទមួយចំនួន :

- ទស្សនៈទានទូទៅនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃ : និយមន័យ គោលបំណង ពេលវេលានៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ...។
- គម្រោង និងសមាសភាគ : ប្រភេទគម្រោង ធនធាន សកម្មភាព លទ្ធផល ផលប៉ះពាល់ ...។
- អ្នកពាក់ព័ន្ធ : ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃ គណៈកម្មការ និងគណៈកម្មាធិការនានា ប្រជាពលរដ្ឋ...។
- ដំណើរការនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃ : ការរៀបចំ ការប្រមូលព័ត៌មាន ការវិភាគព័ត៌មាន ការប្រើប្រាស់សេចក្តីសន្និដ្ឋាន...។
- ការប្រើប្រាស់លទ្ធផលនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

☞ ការតាមដានត្រួតពិនិត្យលើកិច្ចការរដ្ឋបាលឃុំ សង្កាត់ នឹងផ្តោតទៅលើប្រធានបទតូចៗមួយចំនួន :

- លិខិតរដ្ឋបាលឃុំ សង្កាត់ : ការតាមដានត្រួតពិនិត្យលើនីតិវិធីនៃការរៀបចំដីកាឃុំ សង្កាត់ ការចេញសេចក្តីសម្រេចឃុំ សង្កាត់ និងលិខិតរដ្ឋបាលធម្មតារបស់ឃុំ សង្កាត់ ការចរាចរលិខិតរបស់ឃុំ សង្កាត់ . ..
- បញ្ហាបុគ្គលិក : ការតាមដានត្រួតពិនិត្យលើការបរិយាយមុខងារលម្អិត ដំណើរការនៃការជ្រើសរើសបុគ្គលិក ការរៀបចំកិច្ចសន្យា ការគ្រប់គ្រងបុគ្គលិក ការវាយតម្លៃបុគ្គលិក . . . ។ល។
- ការគ្រប់គ្រងឯកសារ : ការតាមដានត្រួតពិនិត្យលើការគ្រប់គ្រង និងទុកដាក់ឯកសាររបស់ឃុំ សង្កាត់។
- ការគ្រប់គ្រងសាលាឃុំ សង្កាត់ : ការតាមដានត្រួតពិនិត្យលើការគ្រប់គ្រងនិងប្រើប្រាស់សម្ភារៈបរិក្ខារឃុំ សង្កាត់ ការគ្រប់គ្រងសម្ភារៈការិយាល័យ សំណុំឯកសារសម្រាប់ការធ្វើដំណើរ . . . ។ល។
- កិច្ចប្រជុំរបស់ឃុំ សង្កាត់ : ការតាមដានត្រួតពិនិត្យលើការធ្វើសេចក្តីសម្រេចចិត្ត ការរៀបចំកិច្ចប្រជុំ . . . ។ល។

☞ ការតាមដានត្រួតពិនិត្យលើកិច្ចការហិរញ្ញវត្ថុឃុំ សង្កាត់ នឹងផ្តោតទៅលើប្រធានបទតូចៗមួយចំនួន :

- ការតាមដានត្រួតពិនិត្យលើការងារប្រមូលចំណូលនិងការកត់ត្រា
- ការតាមដានត្រួតពិនិត្យលើការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ និងការប្រើប្រាស់ថវិកា
- ការតាមដានត្រួតពិនិត្យលើវិសោធនកម្មគម្រោងថវិកាឃុំ សង្កាត់
- ការតាមដានត្រួតពិនិត្យថវិកាប្រចាំឆ្នាំ
- ការតាមដានត្រួតពិនិត្យលើការប្រើប្រាស់បេឡាបុរេប្រទាន ឬការស្នើសុំបន្ថែម និងការទូទាត់ផ្ទាល់
- ការតាមដានត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែនិងប្រចាំឆ្នាំ និងការបែងចែកព័ត៌មាន

ការតាមដានត្រួតពិនិត្យ ក៏គួរផ្តោតលើការផ្តល់សេវាកម្មរបស់អ្នកសម្របសម្រួល ការផ្តល់ជំនួយបច្ចេកទេស សេវាកម្មរបស់រតនាគារ អ្នកទទួលការ និងអ្នកផ្តល់សេវា ឬអ្នកផ្គត់ផ្គង់ផងដែរ ។

នៅក្នុងការបណ្តុះបណ្តាលនេះ ក៏ត្រូវកំណត់អំពីរបៀបតាមដានត្រួតពិនិត្យឱ្យបានច្បាស់លាស់ ប្រភេទរបាយការណ៍អ្វីខ្លះដែលត្រូវរៀបចំ សម្រាប់អ្នកណា ញឹកញាប់ប៉ុណ្ណា និងព័ត៌មានដែលបានមកពីការតាមដានត្រួតពិនិត្យទាំងនោះត្រូវប្រើប្រាស់យ៉ាងដូចម្តេច ។

ក្រុមការងាររៀបចំមេរៀនមួយ នឹងត្រូវបង្កើតឡើងដែលមានសមាសភាពមន្ត្រីមកពីអង្គភាពរដ្ឋបាលមូលដ្ឋាន ខេត្តក្រុង ការិយាល័យនានារបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងគម្រោងPSDD ។ ក្រុមការងារនេះនឹងរៀបចំខ្លឹមសារមេរៀនដែលរួមបញ្ចូលទាំងនីតិវិធីនិងការទទួលខុសត្រូវ វិធីសាស្ត្របណ្តុះបណ្តាល និងឯកសារពាក់ព័ន្ធដទៃទៀត ហើយដាក់ជូន គ.ជ.អ.ប ដើម្បីពិនិត្យ និងអនុម័ត ។ បន្ទាប់ពីទទួលបានការឯកភាពពី គ.ជ.អ.ប ការិយាល័យអប់រំ និងកសាងសមត្ថភាព និងក្រុមការងាររៀបចំមេរៀន នឹងរៀបចំការបណ្តុះបណ្តាលសាកល្បងនៅឃុំ សង្កាត់ ។

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

បន្ទាប់ពីការបណ្តុះបណ្តាលសាកល្បង និងកែសម្រួលមេរៀនរួចរាល់ ការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន សហការជាមួយក្រុមការងាររៀបចំមេរៀននេះ នឹងបណ្តុះបណ្តាលដល់គ្រូបង្គោលថ្នាក់ជាតិដែលជាមន្ត្រីមកពីខេត្ត ក្រុងទាំង២៤ ។ ខេត្ត ក្រុងនីមួយៗ នឹងចាត់បញ្ជូនមន្ត្រីចំនួនពី២ទៅ៦នាក់ ដែលមកពីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង និងទីប្រឹក្សារដ្ឋបាលមូលដ្ឋាននៃគម្រោង PSDD ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ។ ក្រុមគ្រូបង្គោលនឹងបណ្តុះបណ្តាលដល់គ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុងរបស់ខ្លួន (អ្នកសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌទាំងអស់) ហើយគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុងនឹងបណ្តុះបណ្តាលដល់គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ ជនបង្គោលតាមដានត្រួតពិនិត្យនិងវាយតម្លៃឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ទាំងអស់ ។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ : ០៤ថ្ងៃ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ០៤ថ្ងៃ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ០៤ថ្ងៃ

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែមករា-កុម្ភៈ ឆ្នាំ២០០៩ : ការរៀបចំឯកសារ និងការបណ្តុះបណ្តាលសាកល្បង
- ខែកុម្ភៈ-មីនា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង
- ខែមិនា-មេសា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការរៀបចំខ្លឹមសារ និងការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ : ១៦.២៩២ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ១៩.១៧២ ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ១២០.៦២៦ ដុល្លារ

សរុប : **១៥៦.០៩០ ដុល្លារ**

## ២.៣.២. ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

ក). ប្រវត្តិ

ប្រធានបទស្តីពី**ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់** ត្រូវបានបណ្តុះបណ្តាលចំនួន២លើក នៅឆ្នាំ២០០៣ និងឆ្នាំ២០០៥ និងបានប្រជុំពិភាក្សាឆ្លុះបញ្ចាំងចំនួន២លើកជាមួយថ្នាក់ខេត្ត ក្រុងនៅឆ្នាំ២០០៦។ ថ្វីត្បិតតែប្រធានបទនេះត្រូវបានបណ្តុះបណ្តាល និងពិភាក្សាជាច្រើនលើកហើយក៏ដោយ ក៏ក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកសម្របសម្រួលខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីគាំទ្របច្ចេកទេស នៅតែជួបការលំបាកនៅក្នុងការអនុវត្ត ជាពិសេស នីតិវិធីអនុវត្តគម្រោងសេវាកម្ម និងថែទាំ ការសិក្សាផលប៉ះពាល់បរិស្ថាន និងលទ្ធកម្មជីធ្លី ជាដើម។ នៅឆ្នាំ២០០៦ និងឆ្នាំ២០០៧ ខេត្ត ក្រុងនីមួយៗ បានពិភាក្សាគ្នា និងផ្ញើមតិយោបល់ អនុសាសន៍ និងបញ្ហាលំបាកនានាដែលខេត្ត ក្រុងបានជួបប្រទះ ដើម្បីកែលម្អ និងបញ្ចូលនីតិវិធីបន្ថែមនៅក្នុងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។ គ.ជ.អ.ប នឹងពិនិត្យមតិយោបល់ អនុសាសន៍ និងបញ្ហាលំបាកទាំងនេះ ហើយធ្វើការកែសម្រួលសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ និងធ្វើការបណ្តុះបណ្តាល។ ដោយសារតែមានបញ្ហាស្មុគស្មាញច្រើនដែលតម្រូវឱ្យមានការពិភាក្សា និងឯកភាពពីគ្រប់អ្នកពាក់ព័ន្ធ ហេតុនេះហើយទើបក្នុងការងារមិនអាចកែសម្រួលសៀវភៅណែនាំនេះឱ្យចប់សព្វគ្រប់ និងផ្តល់ការបណ្តុះបណ្តាលក្នុងឆ្នាំ២០០៨បាន ហើយត្រូវលើកប្រធានបទនេះមកបញ្ចូលក្នុងផែនការសម្រាប់ឆ្នាំ២០០៩។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពី**ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់** នឹងផ្តោតជាសំខាន់ទៅលើប្រធានបទមួយចំនួន :

- នីតិវិធីរៀបចំគម្រោង ពិសេសគម្រោងសេវាកម្ម និងគម្រោងថែទាំ
- ការសិក្សាផលប៉ះពាល់បរិស្ថាន និងលទ្ធកម្មដីធ្លី

- ការចុះបញ្ជី និងវាយតម្លៃអ្នកទទួលការ
- កិច្ចលទ្ធកម្មគម្រោង ឬកិច្ចសន្យា
- ការត្រួតពិនិត្យគម្រោង

## គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

ក្រុមការងារអន្តរក្រសួងនឹងត្រូវរៀបចំឡើង ដែលក្នុងនោះរួមមាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអភិវឌ្ឍន៍ជនបទ។ ក្រុមការងារនេះនឹងពិនិត្យមតិយោបល់ អនុសាសន៍ និង ការលំបាកនានារបស់ខេត្ត ក្រុង ហើយធ្វើការកែសម្រួលសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។ បន្ទាប់មកក្រុមការងារកែសម្រួលបញ្ចប់សេចក្តីព្រាង ហើយដាក់ជូន លេខាធិការដ្ឋាន គ.ជ.អ.ប ពិនិត្យ និងសម្រេច។ បន្ទាប់ពីទទួលបានការអនុម័តពីលេខាធិការដ្ឋាន គ.ជ.អ.ប ការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋាន រដ្ឋបាលមូលដ្ឋានសហការជាមួយក្រុមការងារដើម្បីរៀបចំប្លង់មេរៀន និងបណ្តុះបណ្តាលសាកល្បងជាមួយក្រុម ប្រឹក្សាឃុំ សង្កាត់។

បន្ទាប់ពីការបណ្តុះបណ្តាលសាកល្បង និងកែសម្រួលចប់សព្វគ្រប់ ការិយាល័យអប់រំ និងកសាងសមត្ថភាពនៃ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន សហការជាមួយក្រុមការងាររៀបចំមេរៀននេះ នឹងបណ្តុះបណ្តាលដល់គ្រូបង្គោលថ្នាក់ជាតិ ដែលជាមន្ត្រីមកពីខេត្ត ក្រុងទាំង២៤។ ខេត្ត ក្រុងនីមួយៗ នឹងចាត់បញ្ជូនមន្ត្រីចំនួនពី៤ទៅ៨នាក់ ដែលមកពីអង្គភាព រដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ផ្នែកគាំទ្របច្ចេកទេស ទីប្រឹក្សារដ្ឋបាលមូលដ្ឋាន និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធនៃគម្រោង PSDD ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ។ ក្រុមគ្រូបង្គោលនឹងបណ្តុះបណ្តាលដល់គ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុងរបស់ខ្លួន (អ្នកសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌទាំងអស់) ហើយគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង នឹង បណ្តុះបណ្តាលដល់គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ទាំងអស់។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ : ០៣ថ្ងៃ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ០៣ថ្ងៃ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ០៣ថ្ងៃ

## ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែមករា ឆ្នាំ២០០៩ : ការរៀបចំឯកសារ និង ការបណ្តុះបណ្តាលសាកល្បង
- ខែមករា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង
- ខែកុម្ភៈ ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការរៀបចំខ្លឹមសារ និងការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ : ១៩.៦៥៥ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ១៧.៣៩៤ ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ១០៨.៦៦៥ ដុល្លារ

**សរុប : ១៤៥.៧១៤ ដុល្លារ**

## ២.៣.៣. ភាពជាអ្នកដឹកនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់

ក). ប្រវត្តិ

ផ្អែកតាមលទ្ធផលនៃការសិក្សាអំពីតម្រូវការកសាងសមត្ថភាពរបស់ឃុំសង្កាត់នៅឆ្នាំ២០០៨ និងលទ្ធផលក្នុងឆ្នាំ២០០៩ ឃើញថាអ្នកផ្តល់ព័ត៌មានភាគច្រើនបានលើកឡើងនូវតម្រូវការកសាងសមត្ថភាពអំពីភាពជាអ្នកដឹកនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

ដោយយល់ឃើញថា ភាពជាអ្នកដឹកនាំ មានសារៈសំខាន់ផងដែរក្នុងការជួយឱ្យឃុំ សង្កាត់បំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបានកាន់តែប្រសើរ ទើប គ.ជ.អ.ប សម្រេចដាក់វគ្គបណ្តុះបណ្តាលស្តីពី ភាពជាអ្នកដឹកនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ បញ្ចូលក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពី **ភាពជាអ្នកដឹកនាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់** នឹងផ្តោតជាសំខាន់ទៅលើ :

- របៀបដឹកនាំ
- របៀបគ្រប់គ្រង និងចាត់ចែង
- ការធ្វើការជាក្រុម
- របៀបសម្របសម្រួល និងចាត់ចែងសេវា ឬសកម្មភាពការងារ
- របៀបទំនាក់ទំនង និងសហប្រតិបត្តិការ
- គោលការណ៍អភិបាលកិច្ចល្អ
- ការបង្កើនភាពជាម្ចាស់
- របៀបបញ្ចុះបញ្ចូលសុំការគាំទ្រ
- ... ។ល ។

ក្រុមការងាររៀបចំមេរៀនមួយ នឹងត្រូវបង្កើតឡើងដែលមានសមាសភាពមន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន មន្ត្រីក្រុមគោលនយោបាយ មន្ត្រីគម្រោងPSDD និងអ្នកពាក់ព័ន្ធដែលមានបទពិសោធន៍ដទៃទៀត ។ ក្រុមការងារនេះ

នឹងរៀបចំខ្លឹមសារមេរៀន ដែលរួមបញ្ចូលទាំងវិធីសាស្រ្តបណ្តុះបណ្តាល និងឯកសារពាក់ព័ន្ធដទៃទៀត ហើយដាក់ជូន គ.ជ.អ.ប ដើម្បីពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលបានការឯកភាពពី គ.ជ.អ.ប ការិយាល័យអប់រំ និងកសាងសមត្ថភាព និងក្រុមការងាររៀបចំមេរៀននឹងរៀបចំការបណ្តុះបណ្តាលសាកល្បងនៅឃុំ សង្កាត់។

## គ). យុទ្ធសាស្រ្តនៃការបណ្តុះបណ្តាល

បន្ទាប់ពីការបណ្តុះបណ្តាលសាកល្បង និងកែសម្រួលមេរៀនរួចរាល់ ការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋានសហការជាមួយក្រុមការងាររៀបចំមេរៀននេះ នឹងបណ្តុះបណ្តាលដល់គ្រូបង្គោលថ្នាក់ជាតិ ដែលជាមន្ត្រីមកពីខេត្ត ក្រុងទាំង២៤។ ខេត្ត ក្រុងនីមួយៗ នឹងចាត់បញ្ជូនមន្ត្រីចំនួនពី២ទៅ៦នាក់ ដែលមកពីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង និងទីប្រឹក្សារដ្ឋបាលមូលដ្ឋាននៃគម្រោង PSDD ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ។ ក្រុមគ្រូបង្គោលនឹងបណ្តុះបណ្តាលដល់អ្នកសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌទាំងអស់ ហើយអ្នកសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌនឹងបណ្តុះបណ្តាលដល់គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ទាំងអស់។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ : ០៣ថ្ងៃ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ០៣ថ្ងៃ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ០៣ថ្ងៃ

## ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែមីនា-មេសា ឆ្នាំ២០០៩ : ការរៀបចំឯកសារ និងការបណ្តុះបណ្តាលសាកល្បង
- ខែមេសា-ឧសភា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង
- ខែឧសភា-មិថុនា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់

## ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការរៀបចំខ្លឹមសារ និងការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ : ១៣.៧៧៧ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ១៦.០៣៤ ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ៨៤.៣៤១ ដុល្លារ

**សរុប : ១១៤.១៥២ ដុល្លារ**

### ២.៣.៤. ការសរសេរសំណើគម្រោងខ្នាតតូច

ក). ប្រវត្តិ

ផ្អែកតាមលទ្ធផលនៃការសិក្សាអំពីតម្រូវការកសាងសមត្ថភាពរបស់ឃុំ សង្កាត់នៅឆ្នាំ២០០៨ និងលទ្ធផលក្នុងឆ្នាំ២០០៩ ឃើញថាអ្នកផ្តល់ព័ត៌មានភាគច្រើនបានលើកនូវតម្រូវការកសាងសមត្ថភាពអំពី ការសរសេរគម្រោងស្នើសុំខ្នាតតូចសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់។ កន្លងមកអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់ភាគច្រើនស្នើឱ្យឃុំ សង្កាត់រៀបចំសរសេរគម្រោងស្នើសុំខ្នាតតូចៗដើម្បីសុំការគាំទ្រថវិកា និងបច្ចេកទេសពីពួកគេ កិច្ចការនេះបានធ្វើឱ្យឃុំ សង្កាត់មានការលំបាកយ៉ាងខ្លាំង ព្រោះមិនមានមូលដ្ឋានអំពីការសរសេរគម្រោងស្នើសុំខ្នាតតូចនេះ។

ដោយយល់ឃើញថា ការសរសេរគម្រោងស្នើសុំខ្នាតតូច មានសារៈសំខាន់ផងដែរក្នុងការជួយឱ្យឃុំ សង្កាត់បំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ពិសេសក្នុងការកៀរគរធនធានពីអង្គការសង្គមកស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ទើប គ.ជ.អ.ប សម្រេចដាក់វគ្គបណ្តុះបណ្តាលស្តីពី ការសរសេរសំណើគម្រោងសុំខ្នាតតូច សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់បញ្ចូលក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពី **ការសរសេរគម្រោងស្នើសុំខ្នាតតូច** នឹងផ្តោតជាសំខាន់ទៅលើ :

- របៀបសរសេរសេចក្តីផ្តើម
- របៀបបរិយាយអំពីបញ្ហា ឧបសគ្គ ឱកាស និងដំណោះស្រាយ
- របៀបកំណត់គោលដៅ គោលបំណង
- របៀបកំណត់សកម្មភាពនានាដើម្បីឆ្លើយតបទៅនឹងគោលបំណង
- ការរៀបចំផែនការសកម្មភាព និងលទ្ធផលរំពឹងទុក
- របៀបប៉ាន់ស្មានថវិកាចំណាយ ការសន្មត់សំខាន់ និងហានិភ័យ
- ការកំណត់អ្នកទទួលផល និងនិរន្តរភាពគម្រោង
- ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ...។ល។

ក្រុមការងាររៀបចំមេរៀនមួយនឹងត្រូវបង្កើតឡើង ដែលមានសមាសភាពមន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន មន្ត្រីក្រុមគោលនយោបាយ មន្ត្រីគម្រោងPSDD និងអ្នកពាក់ព័ន្ធដែលមានបទពិសោធន៍ដទៃទៀត។ ក្រុមការងារនេះនឹងរៀបចំខ្លឹមសារមេរៀន ដែលរួមបញ្ចូលទាំងវិធីសាស្ត្របណ្តុះបណ្តាល និងឯកសារពាក់ព័ន្ធដទៃទៀត ហើយដាក់ជូន គ.ជ.អ.ប ដើម្បីពិនិត្យ និងអនុម័ត។ បន្ទាប់ពីទទួលបានការឯកភាពពី គ.ជ.អ.ប ការិយាល័យអប់រំ និងកសាងសមត្ថភាព និងក្រុមការងាររៀបចំមេរៀននឹងរៀបចំការបណ្តុះបណ្តាលសាកល្បងនៅឃុំ សង្កាត់។

## គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

បន្ទាប់ពីការបណ្តុះបណ្តាលសាកល្បង និងកែសម្រួលមេរៀនរួចរាល់ ការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋានសហការជាមួយក្រុមការងាររៀបចំមេរៀននេះ នឹងបណ្តុះបណ្តាលដល់គ្រូបង្គោលថ្នាក់ជាតិ ដែលជាមន្ត្រីមកពីខេត្ត ក្រុងទាំង២៤។ ខេត្ត ក្រុងនីមួយៗ នឹងចាត់បញ្ជូនមន្ត្រីចំនួនពី២ទៅ៦នាក់ ដែលមកពីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង និងទីប្រឹក្សារដ្ឋបាលមូលដ្ឋាននៃគម្រោង PSDD ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ។ ក្រុមគ្រូបង្គោលនឹងបណ្តុះបណ្តាលដល់អ្នកសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌទាំងអស់ ហើយអ្នកសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌនឹងបណ្តុះបណ្តាលដល់មេឃុំ ចៅសង្កាត់ និងស្មៀនឃុំ សង្កាត់ទាំងអស់។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ : ០៣ថ្ងៃ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ០៣ថ្ងៃ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ០៣ថ្ងៃ

## ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែសីហា-កញ្ញា ឆ្នាំ២០០៩ : ការរៀបចំឯកសារ និងការបណ្តុះបណ្តាលសាកល្បង
- ខែកញ្ញា-តុលា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ និងគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង
- ខែតុលា-វិច្ឆិកា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់

## ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការរៀបចំខ្លឹមសារ និងការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ : ១៣.៧៧៧ ដុល្លារ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ១៦.០៣៤ ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ២២.១២១ ដុល្លារ

**សរុប : ៥១.៩៣២ ដុល្លារ**

## ២.៣.៥. កិច្ចការរដ្ឋបាលឃុំ សង្កាត់

### ក). ប្រវត្តិ

ប្រធានបទស្តីពី**កិច្ចការរដ្ឋបាលឃុំ សង្កាត់** បានបណ្តុះបណ្តាលដល់គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ ទាំង១.៦២១ឃុំ សង្កាត់កាលពីឆ្នាំ២០០៥។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ បានប្រព្រឹត្តទៅនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ នៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស។ ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ សរុប ១១.៣៥៣រូប (ស្រី១.៦៦២រូប) ក្នុងនោះមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ ចំនួនប្រមាណ ៤០.៤៤%។ ទោះបីជាខេត្តក្រុងមួយចំនួនបានបណ្តុះបណ្តាលមេរៀននេះឡើងវិញក្នុងឆ្នាំ២០០៨ក៏ដោយ ក៏ផ្អែកលើលទ្ធផលនៃការសិក្សាអំពីតម្រូវការកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ ២០០៩ ប្រធានបទនេះនៅតែជាតម្រូវការអាទិភាពរបស់ឃុំសង្កាត់ភាគច្រើន។

ដូច្នេះដើម្បីឱ្យក្រុមប្រឹក្សាឃុំសង្កាត់អាណត្តិទី២អាចគ្រប់គ្រង និងចាត់ចែងកិច្ចការរដ្ឋបាលឃុំ សង្កាត់បាន គ.ជ.អ.ប នឹងផ្តល់ការបណ្តុះបណ្តាលឡើងវិញបន្ថែមទៀតស្តីពី**កិច្ចការរដ្ឋបាលឃុំ សង្កាត់**។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពី**កិច្ចការរដ្ឋបាលឃុំ សង្កាត់** នឹងផ្តោតជាសំខាន់ទៅលើ :

- លិខិតរដ្ឋបាលឃុំ សង្កាត់
- ការគ្រប់គ្រងបុគ្គលិក
- ការគ្រប់គ្រងសាលាឃុំ សង្កាត់
- ការគ្រប់គ្រងឯកសារ
- ការរៀបចំកិច្ចប្រជុំរបស់ឃុំ សង្កាត់

ខេត្ត ក្រុងនីមួយៗនឹងរៀបចំបោះពុម្ពឯកសារមេរៀននេះ សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយយកតាមសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់នាខែវិច្ឆិកា ឆ្នាំ២០០៥ ដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់។

### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

ខេត្ត ក្រុងនីមួយៗនឹងរៀបចំការបណ្តុះបណ្តាលរំឭកឡើងវិញដល់គ្រប់អ្នកសម្របសម្រួលថ្នាក់ស្រុក ខណ្ឌ និងថ្នាក់ខេត្ត ក្រុងទាំងអស់របស់ខ្លួន បន្ទាប់មកអ្នកសម្របសម្រួលស្រុក ខណ្ឌ ខេត្ត ក្រុងនឹងបណ្តុះបណ្តាលបន្តដល់គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ទាំងអស់។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ០៣ថ្ងៃ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ០៣ថ្ងៃ

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

ខេត្ត ក្រុងនីមួយៗត្រូវកំណត់ពេលវេលាសមស្របសម្រាប់ខេត្ត ក្រុងរបស់ខ្លួន ក្នុងការបណ្តុះបណ្តាលរំឭកឡើងវិញដល់គ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង និងថ្នាក់ឃុំ សង្កាត់។

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ១៦.០៣៤ ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ៨៤.៣៤១ ដុល្លារ

**សរុប : ១០០.៣៧៥ ដុល្លារ**

## ២.៣.៦. ដំណើរការកសាងកម្មវិធីវិនិយោគឃុំ សង្កាត់

ក). ប្រវត្តិ

វគ្គបណ្តុះបណ្តាលស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ត្រូវបានរៀបចំឡើងសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងឆ្នាំ២០០៧។ ផ្អែកលើលទ្ធផលនៃការសិក្សាអំពីតម្រូវការបណ្តុះបណ្តាលបានបង្ហាញឱ្យឃើញថា ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ គណៈកម្មាធិការកសាងផែនការ និងថវិកា និងអ្នកសម្របសម្រួលស្រុក ខណ្ឌ ខេត្ត ក្រុង នៅជួបការលំបាកក្នុងការអនុវត្តដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។

ដើម្បីជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ គណៈកម្មាធិការកសាងផែនការ និងថវិកា និងអ្នកសម្របសម្រួលស្រុក ខណ្ឌ ខេត្ត ក្រុងក្នុងការរៀបចំកម្មវិធីវិនិយោគឆ្នាំ២០០៩ គ.ជ.អ.ប នឹងផ្តល់ការបណ្តុះបណ្តាលឡើងវិញស្តីពីដំណើរការកសាងកម្មវិធីវិនិយោគឃុំ សង្កាត់។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលឡើងវិញស្តីពីដំណើរការកសាងកម្មវិធីវិនិយោគឃុំ សង្កាត់ ផ្តោតទៅលើគ្រប់ប្រធានបទទាំងអស់ដែលបានរៀបចំ អនុម័ត និងបណ្តុះបណ្តាលដោយ គ.ជ.អ.ប កាលពីឆ្នាំ២០០៧កន្លងមក។ ប្រធានបទទាំងនោះរួមមាន :

- ទិដ្ឋភាពទូទៅនៃការកសាងកម្មវិធីវិនិយោគឃុំ សង្កាត់
- ជំហានទី១ : ការពិនិត្យបញ្ហា ឬតម្រូវការជាមួយប្រជាពលរដ្ឋឡើងវិញ
- ជំហានទី២ : ការរៀបចំគម្រោងវិនិយោគឃុំ សង្កាត់
- ជំហានទី៣ : សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ
- ជំហានទី៤ : ការអនុម័តកម្មវិធីវិនិយោគឃុំ សង្កាត់
- ជំហានទី៥ : ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគឃុំ សង្កាត់

លើសពីនេះទៀត ខេត្ត ក្រុងនីមួយៗអាចធ្វើការឆ្លុះបញ្ចាំងជាមួយសិក្ខាកាមអំពីបទពិសោធន៍នានាដែលបាន អនុវត្តក្នុងឆ្នាំកន្លងមក ដើម្បីជាមេរៀនក្នុងការកែលម្អការអនុវត្តសម្រាប់ឆ្នាំបន្ទាប់ ។

ខេត្ត ក្រុងនីមួយៗមិនចាំបាច់ធ្វើការរំឭកឡើងវិញអំពីខ្លឹមសារនៃការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ឡើយ ។

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ខេត្ត ក្រុងនីមួយៗនឹងរៀបចំការបណ្តុះបណ្តាលរំឭកឡើងវិញដល់គ្រប់អ្នកសម្របសម្រួលថ្នាក់ស្រុក ខណ្ឌ និង ថ្នាក់ខេត្ត ក្រុងទាំងអស់របស់ខ្លួន បន្ទាប់មកអ្នកសម្របសម្រួលស្រុក ខណ្ឌ ខេត្ត ក្រុងនឹងបណ្តុះបណ្តាលបន្តដល់ក្រុម ប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ ។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ០២ថ្ងៃ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ០២ថ្ងៃ

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

ខេត្ត ក្រុងនីមួយៗត្រូវកំណត់ពេលវេលាសមស្របសម្រាប់ខេត្ត ក្រុងរបស់ខ្លួន ក្នុងការបណ្តុះបណ្តាលរំឭក ឡើងវិញដល់គ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង និងថ្នាក់ឃុំ សង្កាត់ ។

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ១២.៨៩៥.៥ ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ១៩៨,៧៦៨ ដុល្លារ

**សរុប : ២១១,៦៦៣.៥ ដុល្លារ**

## ២.៣.៧. ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់

**ក). ប្រវត្តិ**

កន្លងមកគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ចំនួនពីរលើករួចមកហើយ ។ ការបណ្តុះបណ្តាលលើកទីមួយត្រូវបានរៀបចំឡើង នៅឆ្នាំ២០០២ សម្រាប់គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់ទាំងអស់ និងលើកទី២ នៅឆ្នាំ២០០៣ សម្រាប់មេឃុំ ចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រងដែលទទួលបន្ទុកផ្នែកហិរញ្ញវត្ថុ និងស្មៀនឃុំ សង្កាត់ ។ បន្ទាប់មក នៅ តាមខេត្ត ក្រុងនីមួយៗបានបណ្តុះបណ្តាលមេរៀននេះឡើងវិញជាបន្តបន្ទាប់ ។ ទោះបីជាមេរៀននេះត្រូវបានបណ្តុះ បណ្តាលឡើងវិញជាបន្តបន្ទាប់ក៏ដោយ ក៏លទ្ធផលនៃការសិក្សាតម្រូវការកសាងសមត្ថភាពឃុំ សង្កាត់បង្ហាញថា ការបណ្តុះបណ្តាលអំពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ គឺជាប្រធានបទដែលមានអាទិភាពជាងគេបំផុត ហើយ តម្រូវឱ្យធ្វើការបណ្តុះបណ្តាលឡើងវិញ ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការដ៏ចាំបាច់នេះ គ.ជ.អ.ប នឹងផ្តល់ការបណ្តុះបណ្តាលឡើងវិញបន្ថែមទៀតស្តីពី **ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់។**

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

ខ្លឹមសារនៃការបណ្តុះបណ្តាលឡើងវិញស្តីពីការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់ផ្តោតទៅលើគ្រប់ប្រធានបទទាំងអស់ដែលមានស្រាប់រួមមាន :

- ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- ថវិការបស់ឃុំ សង្កាត់
- ប្រព័ន្ធទូទាត់ និងគណនេយ្យឃុំ សង្កាត់
- របាយការណ៍ហិរញ្ញវត្ថុ និងការបិទបញ្ជីថវិកា
- តម្លាភាព និងគណនេយ្យភាព
- ។ល។

លើសពីនេះទៀត ខេត្ត ក្រុងនីមួយៗអាចធ្វើការឆ្លុះបញ្ចាំងជាមួយសិក្ខាកាមអំពីបទពិសោធន៍នានាដែលបានអនុវត្តក្នុងឆ្នាំកន្លងមក ដើម្បីជាមេរៀនក្នុងការកែលម្អការអនុវត្តសម្រាប់ឆ្នាំបន្ទាប់។

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ខេត្ត ក្រុងនីមួយៗនឹងរៀបចំការបណ្តុះបណ្តាលរំឭកឡើងវិញដល់គ្រប់អ្នកសម្របសម្រួលថ្នាក់ស្រុក ខណ្ឌ និងថ្នាក់ខេត្ត ក្រុងទាំងអស់របស់ខ្លួន បន្ទាប់មកអ្នកសម្របសម្រួលស្រុក ខណ្ឌ ខេត្ត ក្រុងនឹងបណ្តុះបណ្តាលបន្តដល់គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ០២ថ្ងៃ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ០២ថ្ងៃ

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

ខេត្ត ក្រុងនីមួយៗត្រូវកំណត់ពេលវេលាសមស្របសម្រាប់ខេត្ត ក្រុងរបស់ខ្លួន ក្នុងការបណ្តុះបណ្តាលរំឭកឡើងវិញដល់គ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង និងថ្នាក់ឃុំ សង្កាត់។

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង : ១២.៨៩៥ ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ៧០.៣៦៧ ដុល្លារ

**សរុប : ៨៣.២៦២ ដុល្លារ**

## ២.៣.៨. របៀបកត់ត្រាការងារអត្រានុកូលដ្ឋាន

### ក). ប្រវត្តិដើម :

ការបណ្តុះបណ្តាលអំពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋានដល់ក្រុមប្រឹក្សាឃុំ សង្កាត់លើកទី១បានរៀបចំឡើងនៅឆ្នាំ២០០៤ និងលើកទី២នៅឆ្នាំ២០០៥ ព្រមទាំងមានការបណ្តុះបណ្តាលអំពីការកែតម្រូវទិន្នន័យនៅក្នុងសៀវភៅអត្រានុកូលដ្ឋានក្នុងឆ្នាំ២០០៨។ ទោះបីជាការរៀបចំវគ្គបណ្តុះបណ្តាលនេះរៀបចំឡើងជាច្រើនលើកក៏ដោយក៏ការកត់ត្រាការងារអត្រានុកូលដ្ឋាននៅតែមានកំហុស ដែលតម្រូវឱ្យធ្វើការពង្រឹងសមត្ថភាពបន្ថែម ម្យ៉ាងទៀតបន្ទាប់ពីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០០៧មក មានការផ្លាស់ប្តូរមេឃុំ ចៅសង្កាត់មួយចំនួនផងដែរ ដែលមេឃុំ ចៅសង្កាត់ទាំងនោះ គឺជាមន្ត្រីអត្រានុកូលដ្ឋាន។

### ខ). យុទ្ធសាស្ត្រនៃការរៀបចំវគ្គបណ្តុះបណ្តាល :

ដើម្បីរៀបចំការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេស ជំរើសដែលប្រសើរសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល គឺគួរតែជ្រើសរើសយកយុទ្ធសាស្ត្រដែលធ្លាប់បានអនុវត្តកន្លងមក នោះគឺយុទ្ធសាស្ត្របណ្តុះបណ្តាលបន្តបន្ទាប់តាមលំដាប់ ដូចជាការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ គ្រូបង្គោលផ្តល់ការបណ្តុះបណ្តាលបន្តទៅគ្រូឧទ្ទេសនៅថ្នាក់ខេត្ត ក្រុង បន្ទាប់មកគ្រូឧទ្ទេសបណ្តុះបណ្តាលបន្តដល់ថ្នាក់ឃុំ សង្កាត់។ ក្រៅពីការបណ្តុះបណ្តាល ក្រុមសម្របសម្រួលនឹងត្រូវជួយគាំទ្រដល់ការបំពេញកិច្ចការនេះរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងពេលបំពេញការងារជាក់ស្តែង។ ទោះជាយ៉ាងណាក៏ដោយ ក៏ចំនួនសិក្ខាកាមដែលត្រូវចូលរួមវគ្គបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ គឺដូចទឹងចំនួនសិក្ខាកាមដែលបានទទួលការបណ្តុះបណ្តាលការពីឆ្នាំ២០០៥ដែរ។ ការបណ្តុះបណ្តាលនឹងផ្តោតជាសំខាន់ទៅលើបញ្ហាដែលជួបប្រទះ និងចំនុចទាំងឡាយណាដែលសិក្ខាកាមមិនទាន់យល់ច្បាស់ ឬក៏អនុវត្តមិនទាន់ត្រឹមត្រូវ។

### គ). ប្រធានបទ និងសំភារៈបណ្តុះបណ្តាល :

ក្នុងដំណាក់កាលនេះ វានឹងមានការលំបាកក្នុងការរៀបចំប្រធានបទ សម្រាប់រៀបចំឯកសារបណ្តុះបណ្តាល។ យើងត្រូវរៀបចំឱ្យមានការពិនិត្យឡើងវិញ និងវាយតំលៃលើការអនុវត្តសកម្មភាពចុះបញ្ជីអត្រានុកូលដ្ឋាន។ ការពិនិត្យឡើងវិញ និងការវាយតម្លៃនេះគួរតែរៀបចំឡើងក្នុងអំឡុងខែមេសា ឬខែឧសភា ឆ្នាំ២០០៥។ ការវាយតម្លៃនេះត្រូវប្រមូលអោយបាននូវបញ្ហាដែលជាការលំបាក និងចាំបាច់ត្រូវធ្វើការកែសម្រួល និងចំនុចទាំងឡាយណាដែលអនុវត្តមិនទាន់បានត្រឹមត្រូវ។ លទ្ធផលនៃការត្រួតពិនិត្យឡើងវិញ និងការវាយតម្លៃនេះ គឺជាមូលដ្ឋាននៃការរៀបចំឯកសារ និងខ្លឹមសារបណ្តុះបណ្តាល។ យើងនឹងមានការជឿជាក់ថា ចំពោះមេរៀនខ្លះ នឹងត្រូវបណ្តុះបណ្តាលទាំងស្រុងឡើងវិញ ប៉ុន្តែប្រើវិធីសាស្ត្របណ្តុះបណ្តាលថ្មី។ ទោះជាយ៉ាងណាក៏ យើងមានជំនឿថា នឹងមិនមានការកែប្រែខ្លឹមសារនៃឯកសារបណ្តុះបណ្តាលច្រើនឡើយ ។

បន្ទាប់បានលទ្ធផលនៃការត្រួតពិនិត្យឡើងវិញលើខ្លឹមសារឯកសារមេរៀននេះ មន្ត្រីនៃការិយាល័យពង្រឹងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នឹងសហការជាមួយមន្ត្រីនៃនាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ ដើម្បីរៀបចំឯកសារមេរៀនសម្រាប់ការបណ្តុះបណ្តាលឡើងវិញ ដែលក្នុងនោះរួមមានទាំងប្លង់មេរៀន លំហាត់ និងវិធីសាស្ត្រសម្របសម្រួល។ ឯកសារបណ្តុះបណ្តាលនេះ នឹងត្រូវយកទៅបណ្តុះបណ្តាលសាកល្បង ដើម្បីកែលម្អមុននឹងការរៀបចំបណ្តុះបណ្តាលជាផ្លូវការ ។

**ឃ). ពេលវេលា :**

សកម្មភាពពិនិត្យឡើងវិញ និងវាយតម្លៃលើការអនុវត្តកិច្ចការចុះអត្រានុកូលដ្ឋាន គួររៀបចំឡើងនៅរវាងខែមេសា និងឧសភា ឆ្នាំ២០០៩។ សេចក្តីព្រាងឯកសារមេរៀន ត្រូវរៀបចំឱ្យបានចប់នៅក្នុងអំឡុងខែមិថុនា ឆ្នាំ២០០៩។ ការរៀបចំបណ្តុះបណ្តាលសាកល្បង និងការការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ នឹងរៀបចំនៅខែកក្កដា ឆ្នាំ២០០៩។ ការបណ្តុះបណ្តាលគ្រូឧទ្ទេសនៅថ្នាក់ខេត្ត ក្រុង នឹងត្រូវរៀបចំនៅខែសីហា ឆ្នាំ២០០៩។ ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ នឹងរៀបចំឡើងនៅខែកញ្ញា ឆ្នាំ២០០៩។

**ង). ថវិកាប៉ាន់ស្មាន :**

- ការរៀបចំឯកសារនិងវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ : ១៣,៧៧០ ដុល្លារ
- ការរៀបចំវគ្គបណ្តុះបណ្តាលនៅថ្នាក់ខេត្ត ក្រុង : ១៦,០៣៤ ដុល្លារ
- ការរៀបចំវគ្គបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ២២,១២១ ដុល្លារ

**ចំនួនថវិកាសរុប : ៥១,៩៣២ ដុល្លារ**

## ២.៤. វគ្គបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់សម្រាប់ឃុំ សង្កាត់គោលដៅរបស់គម្រោងនានា

### ២.៤.១. បញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងយុវវ័យ

**ក). ប្រវត្តិ**

អង្គការ UNFPA បានសហការជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃក្នុងការអនុវត្តគម្រោងគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការដោយផ្តោតលើបញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងយុវវ័យ ចាប់តាំងពីឆ្នាំ២០០៦។ រហូតមកដល់ពេលនេះឆ្នាំ២០០៨ គម្រោងបានពង្រីកទៅដល់ចំនួន១០ខេត្តក្រុងគោលដៅ ហើយឆ្នាំ២០០៩ គម្រោងនឹងពង្រីកទៅខេត្តថ្មីចំនួន៤ទៀត គឺខេត្តព្រះវិហារ កំពង់ឆ្នាំង ស្ទឹងត្រែង និងខេត្តរតនគិរី។ ដើម្បីសម្រេចនូវទិសដៅ និងគោលបំណងរបស់គម្រោង ការបណ្តុះបណ្តាល**ស្តីពីបញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងយុវវ័យ** ត្រូវបានចាត់ជាសកម្មភាពអាទិភាពរបស់គម្រោង។

ដោយមើលឃើញពីភាពចាំបាច់ក្នុងការកសាងសមត្ថភាពឃុំ សង្កាត់អំពី**បញ្ហាប្រជាជន សុខភាពបន្តពូជ យេនឌ័រ និងយុវវ័យ** គ.ជ.អ.ប បានសម្រេចបញ្ចូលវគ្គបណ្តុះបណ្តាលនេះទៅក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩ សម្រាប់បណ្តុះបណ្តាលដល់ឃុំនៅក្នុងខេត្តគោលដៅថ្មីទាំងបួន។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

ប្រធានបទសំខាន់៧សម្រាប់មេរៀននេះរួមមាន :

- បញ្ហាប្រជាជន និងការអភិវឌ្ឍ
- បញ្ហាសុខភាពបន្តពូជ
- មេរោគអេដស៍/ជំងឺអេដស៍
- យេនឌ័រ និង
- យុវវ័យ។

ខ្លឹមសារទាំងនេះត្រូវបានរៀបចំ និងចងក្រងដោយអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍ។

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋានសហការជាមួយក្រុមការងារនឹងបណ្តុះបណ្តាលដល់គ្រូបង្គោលថ្នាក់ជាតិដែលមកពីខេត្តគោលដៅចំនួន៤ គឺខេត្តរតនគិរី ព្រះវិហារ ស្ទឹងត្រែង និងខេត្តកំពង់ឆ្នាំង។ ខេត្តគោលដៅនីមួយៗត្រូវចាត់បញ្ជូនមន្ត្រីចំនួន៥នាក់ (២នាក់មកពីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្តក្រុង ១នាក់មកពីមន្ទីរសុខាភិបាល ១នាក់មកពីមន្ទីរកិច្ចការនារី និង១នាក់មកពីមន្ទីរផែនការ) ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ។ ក្រុមគ្រូបង្គោលនឹងបណ្តុះបណ្តាលដល់គ្រូឧទ្ទេសថ្នាក់ខេត្ត (អ្នកសម្របសម្រួលខេត្ត ស្រុកគោលដៅ តំណាងមកពីមន្ទីរសុខាភិបាល មន្ទីរកិច្ចការនារី និងមន្ទីរផែនការ) ហើយគ្រូឧទ្ទេសនឹងបណ្តុះបណ្តាលដល់គ្រប់ក្រុមប្រឹក្សាឃុំ ស្មៀន អ្នកទទួលបន្ទុក

កិច្ចការនារីនិងកុមារចំនួន៥នាក់/ឃុំ ព្រមទាំងតំណាងមណ្ឌលសុខភាព តំណាងមន្ទីរពេទ្យ បង្អែកស្រុក និងតំណាងការិយាល័យពាក់ព័ន្ធជុំវិញស្រុក។

**ចំនួនថ្ងៃបណ្តុះបណ្តាលតាមថ្នាក់នីមួយៗមានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ : ២ថ្ងៃ
- ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត : ២ថ្ងៃ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ១ថ្ងៃ

**ឃ). ពេលវេលានៃការបណ្តុះបណ្តាល**

- ខែ មករា-មីនាឆ្នាំ២០០៩ : ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ
- ខែ មករា-មីនាឆ្នាំ២០០៩ : ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត ក្រុង
- ខែ មករា-មីនាឆ្នាំ២០០៩ : ការបណ្តុះបណ្តាលឃុំ សង្កាត់ (ថ្នាក់ស្រុក)

**ង). គម្រោងថវិកាសម្រាប់ការបណ្តុះបណ្តាល**

- បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ : ២.៤០០ដុល្លារ
- បណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត : ៧.០០០ដុល្លារ
- បណ្តុះបណ្តាលថ្នាក់ឃុំ : ១០.០៧០០ ដុល្លារ

**សរុប : ១១០.១០០ដុល្លារ**

## ២.៤.២. សេចក្តីណែនាំស្តីពីការរៀបចំ និងការគ្រប់គ្រងគម្រោងសេវាកម្ម (គម្រោង ICC)

**ក). ប្រវត្តិ**

សេចក្តីណែនាំស្តីពីការរៀបចំ និងគ្រប់គ្រងគម្រោងសេវាកម្ម (គម្រោង ICC) ដែលបានរៀបចំសេចក្តីព្រាងចាប់តាំងពីខែមិថុនា ឆ្នាំ២០០៨ ហើយមិនទាន់បញ្ចប់សព្វគ្រប់នៅឡើយ ដោយហេតុថា គោលការណ៍នេះនឹងត្រូវរៀបចំយ៉ាងណាឱ្យមានសង្គតិភាពទៅនឹងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដែលបច្ចុប្បន្នស្ថិតក្នុងដំណាក់កាលកែសម្រួល ព្រមជាមួយនឹងការបន្ថែមផ្នែករៀបចំ និងគ្រប់គ្រងគម្រោងមូលនិធិឃុំ សង្កាត់ ផ្នែកសេវាកម្មនេះផងដែរ។ នៅពេលដែលសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ នេះចប់សព្វគ្រប់ជាផ្លូវការហើយនោះ សេចក្តីណែនាំស្តីពីការរៀបចំ និងគ្រប់គ្រងគម្រោងសេវាកម្ម (គម្រោង ICC) ក៏នឹងត្រូវកែតម្រូវឱ្យបានចប់សព្វគ្រប់ឱ្យបានទាន់ពេលវេលា ដើម្បីត្រៀមខ្លួនធ្វើការផ្សព្វផ្សាយដល់ខេត្ត ក្រុងគោលដៅគម្រោងផងដែរ។

ខ). **ខ្លឹមសារនៃការបណ្តុះបណ្តាល**

ប្រធានបទសំខាន់ៗសម្រាប់មេរៀននេះរួមមាន :

- ដំណើរការកំណត់តម្រូវការ និងគម្រោងសេវាកម្ម (គម្រោងICC)
- ដំណើរការជ្រើសរើសគម្រោងសេវាកម្ម (គម្រោងICC)
- ដំណើរការរៀបចំកិច្ចព្រមអនុវត្តគម្រោងICC
- ដំណើរការផ្តល់អនុលោមភាពគម្រោង និងអនុម័តគម្រោង (គម្រោងICC)
- ដំណើរការសិក្សា និងរៀបចំគម្រោងសេវាកម្ម
- ដំណើរការលទ្ធកម្មគម្រោសេវាកម្ម
- ដំណើរការអនុវត្ត តាមដាន និងទូទាត់ដល់ការអនុវត្តគម្រោង

គ). **យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ចំពោះការរៀបចំវគ្គបណ្តុះបណ្តាល គម្រោង DDLG នឹងត្រៀមរៀបចំ រួមគ្នាជាមួយ និងស្របគ្នានឹងពេលដែលត្រូវបណ្តុះបណ្តាលដល់ខេត្ត ក្រុង អំពីសៀវភៅណែនាំ ស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដែលបានកែសម្រួលថ្មីៗនេះ ដើម្បីចៀសវាងការចំណាយពេលវេលាច្រើនក្នុងការធ្វើដំណើររបស់ខេត្ត ក្រុង និងការងាររៀបចំផ្សេងៗរបស់ថ្នាក់ជាតិ ។

ក្រុមការងារសហប្រតិបត្តិការអន្តរឃុំ សង្កាត់នឹងពិភាក្សាជាមួយការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អំពីសមាសភាពពីថ្នាក់ខេត្ត ក្រុង ដែលត្រូវអញ្ជើញចូលរួមក្នុងវគ្គនេះ រួមជាមួយនឹងពេលវេលា ក៏ដូចជាថវិការួមចំណែកផ្សេងៗ។ សិក្ខាកាមដែលបានចូលរួមក្នុងវគ្គនេះ នឹងបណ្តុះបណ្តាលដល់អ្នកសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌគោលដៅទាំងអស់ ហើយអ្នកសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌនឹងបណ្តុះបណ្តាលដល់គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់គោលដៅរបស់គម្រោងទាំងអស់។ ចំពោះការបណ្តុះបណ្តាលដល់ថ្នាក់ឃុំ សង្កាត់ ខ្លឹមសារ នឹងត្រូវបានជ្រើសរើសជាពិសេស ដើម្បីកាត់បន្ថយនូវភាពស្មុគ្រស្មាញ នឹងផ្តោតសំខាន់ដល់ការងារ ដែលឃុំ សង្កាត់ត្រូវអនុវត្តផ្ទាល់។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលថ្នាក់ជាតិ : ១.៥ ថ្ងៃ
- ការបណ្តុះបណ្តាលថ្នាក់ខេត្ត ក្រុង : ១.៥ ថ្ងៃ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ១.៥ ថ្ងៃ

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែ មករា-កុម្ភៈ ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលនៅថ្នាក់ជាតិ
- ខែ កុម្ភៈ ឆ្នាំ២០០៨ : ការបណ្តុះបណ្តាលថ្នាក់ខេត្ត ក្រុង
- ខែ មីនា ឆ្នាំ២០០៨ : ការបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលនៅថ្នាក់ជាតិ : ១២.០០០ ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់ខេត្ត ក្រុង : ១.០០០ ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ : ៥.០០០ ដុល្លារ

**សរុប : ១៨.០០០ ដុល្លារ**

## ២.៤.៣. សេចក្តីណែនាំស្តីពីការរៀបចំ និងការគ្រប់គ្រងគម្រោងសហប្រតិបត្តិការអន្តរឃុំ សង្កាត់

**ក). ប្រវត្តិ**

សេចក្តីណែនាំស្តីពីការរៀបចំ និងការគ្រប់គ្រងគម្រោងសហប្រតិបត្តិការអន្តរឃុំ សង្កាត់ ជារៀងរាល់ឆ្នាំ ត្រូវបានកែសម្រួលស្របទៅតាមសំណូមពរពីបណ្តាខេត្ត ក្រុងដែលបានចូលរួមអនុវត្ត នឹងការវិវឌ្ឍនៃគោលការណ៍នានារបស់ឃុំ សង្កាត់នៅថ្នាក់ជាតិ។ ដូចគ្នានេះដែរ នៅមុនដំណាច់ឆ្នាំ២០០៩ ខាងមុខនេះ សេចក្តីណែនាំស្តីពីការរៀបចំ និងគ្រប់គ្រងគម្រោងសហប្រតិបត្តិការអន្តរឃុំ សង្កាត់ ដែលបានកែសម្រួល និងច្របាច់បញ្ចូលទាំងនីតិវិធីរៀបចំ និងគ្រប់គ្រងគម្រោងសេវាកម្ម នឹងត្រូវបានបណ្តុះបណ្តាពង្រីកឡើងវិញដល់ខេត្ត ក្រុងគោលដៅគម្រោង ។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

ប្រធានបទសំខាន់ៗសម្រាប់មេរៀននេះរួមមាន :

- ដំណើរការកំណត់តម្រូវការ និងគម្រោង (គម្រោងICC)
- ដំណើរការជ្រើសរើសគម្រោង (គម្រោងICC)
- ដំណើរការរៀបចំកិច្ចព្រមព្រៀងអនុវត្តគម្រោងICC
- ដំណើរការផ្តល់អនុលោមភាពគម្រោង និងអនុម័តគម្រោង (គម្រោង ICC)
- ដំណើរការសិក្សា និងរៀបចំគម្រោង ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម
- ដំណើរការលទ្ធកម្មគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម
- ដំណើរការអនុវត្ត តាមដាន និងទូទាត់ដល់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្ម

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ចំពោះការរៀបចំវគ្គបណ្តុះបណ្តាល បើអាចគម្រោង **DDLG** នឹងត្រៀមរៀបចំរួមគ្នាជាមួយ និងស្របគ្នានឹងការបណ្តុះបណ្តាលណាមួយរបស់ការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដើម្បីចៀសវាងការចំណាយពេលវេលាច្រើនក្នុងការធ្វើដំណើររបស់ខេត្ត ក្រុង ការងាររៀបចំផ្សេងៗរបស់ថ្នាក់ជាតិ ។

ក្រុមការងារសហប្រតិបត្តិការអន្តរឃុំ សង្កាត់ នឹងពិភាក្សាជាមួយការិយាល័យអប់រំ និងកសាងសមត្ថភាពនៃ

នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អំពីសមាសភាពពីថ្នាក់ខេត្ត ក្រុង ដែលត្រូវអញ្ជើញចូលរួមក្នុងវគ្គនេះ រួមជាមួយនឹងពេលវេលា ក៏ដូចជាថវិការួមចំណែកផ្សេងៗ។ សិក្ខាកាមដែលបានចូលរួមក្នុងវគ្គនេះ នឹងបណ្តុះបណ្តាលដល់អ្នកសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌគោលដៅទាំងអស់ ហើយអ្នកសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌនឹងបណ្តុះបណ្តាលដល់គ្រប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀនឃុំ សង្កាត់នៅក្នុងឃុំគោលដៅទាំងអស់របស់គម្រោង។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលថ្នាក់ជាតិ : ២ ថ្ងៃ
- ការបណ្តុះបណ្តាលថ្នាក់ខេត្ត ក្រុង : ២ ថ្ងៃ

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែ តុលា-វិច្ឆិកា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលនៅថ្នាក់ជាតិ
- ខែ វិច្ឆកា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលថ្នាក់ខេត្ត ក្រុង

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលនៅថ្នាក់ជាតិ : ២៣.០០០ ដុល្លារ
- ការបណ្តុះបណ្តាលនៅថ្នាក់ខេត្ត ក្រុង : ១.០០០ ដុល្លារ

*សរុប* **: ២៤.០០០ ដុល្លារ**

## ២.៤.៤. ទស្សនៈទានទាក់ទងនៅនឹងគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ

**ក). ប្រវត្តិ**

នៅក្នុងឆ្នាំ២០០៨ ផែនការកសាងសមត្ថភាពដល់អ្នកសម្របសម្រួលថ្នាក់ខេត្ត ស្រុក ត្រូវបានគ្រោងឡើង ដែលផ្តោតលើការបណ្តុះបណ្តាលរំឭកឡើងវិញលើប្រធានបទ ទស្សនៈទានស្តីពីការគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពសំដៅបង្កើនសមត្ថភាពដល់អ្នកសម្របសម្រួលខេត្ត ស្រុក ក្នុងការគាំទ្រ និងសម្របសម្រួលការរៀបចំកម្មវិធីវិនិយោគឃុំ ការជ្រើសរើស និងការអនុវត្តគម្រោងគ្រប់គ្រងធនធានធម្មជាតិនៅមូលដ្ឋាន។ ជាក់ស្តែងការបណ្តុះបណ្តាលត្រូវបានផ្តល់ទៅតាមលក្ខណៈប្រជុំពិភាក្សា និងចែករំលែកបទពិសោធន៍តាមរយៈការប្រជុំបណ្តាញ សិក្ខាសាលា សម្របសម្រួលកិច្ចសហប្រតិបត្តិការ និងការប្រជុំបច្ចេកទេស។ ដោយផ្អែកលើតម្រូវការពង្រឹងសមត្ថភាពនៅថ្នាក់ក្រោមជាតិ វគ្គបណ្តុះបណ្តាលរំឭកឡើងវិញ ស្តីពីប្រធានបទទាក់ទងនឹងគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅត្រូវបានស្នើឡើងដោយផ្តោតលើទស្សនៈទានទាក់ទងនឹងគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ ការតាមដាន និងវាយតម្លៃគម្រោង រួមទាំងការវិភាគទៅលើផលសេដ្ឋកិច្ចត្រឡប់ពីការវិនិយោគគម្រោង និងជំនាញក្នុងការសរសេរករណីសិក្សា ។

ខ).	**ខ្លឹមសារនៃការបណ្តុះបណ្តាល**

**ខ្លឹមសារសំខាន់ៗនៃវគ្គបណ្តុះបណ្តាលរំលឹកនេះមាន :**

- **ទស្សនៈទានទាក់ទងនឹងគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅជនបទ**
  - បញ្ហាបរិស្ថាន
  - បម្រែបម្រួលបរិយាកាស
  - ប្រព័ន្ធជីវភាពរស់នៅ
  - យុទ្ធសាស្ត្រដោះស្រាយបញ្ហា NRM និងជីវភាពរស់នៅ
- **ការតាមដាន និងការវាយតំលៃគម្រោង**
  - ទស្សនៈទានស្តីពីការតាមដាន និងវាយតំលៃ
  - ជំនាញសរសេរករណីសិក្សា
  - ការវិភាគផលសេដ្ឋកិច្ចត្រឡប់ពីការវិនិយោគគម្រោង

គ).	**យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំជាពីរវគ្គ។ វគ្គទី១ ផ្តោតទៅលើទស្សនៈទានទាក់ទងនឹងគម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ និងវគ្គទី២ផ្តោតទៅលើទស្សនៈទាន និងជំនាញក្នុងការតាមដានគម្រោង។

ទីប្រឹក្សា NRM ថ្នាក់ខេត្ត និងអ្នកសម្របសម្រួល NRM ថ្នាក់ខេត្ត២នាក់/ខេត្ត (សរុប២៤នាក់) នឹងត្រូវទទួលបានការបណ្តុះបណ្តាលឱ្យក្លាយជាគ្រូ ដើម្បីផ្តល់ការបណ្តុះបណ្តាលបន្តនៅថ្នាក់ខេត្ត ស្រុក។

ក្រុមគាំទ្រកម្មវិធីនឹងរៀបចំលក្ខខណ្ឌការងារសម្រាប់រៀបចំ និងផ្តល់ការបណ្តុះបណ្តាល ដើម្បីស្វែងរកអ្នកផ្តល់សេវាកម្ម។ វាជាបណ្តុះបណ្តាលបែបការចូលរួម ដើម្បីឱ្យអ្នកចូលរួមចែករំលែកបទពិសោធន៍លើប្រធានបទ ដែលត្រូវពិភាក្សា។ ដោយមានការជួយគាំទ្រ និងតាមដានពីទីប្រឹក្សាNRMថ្នាក់ជាតិ វគ្គបណ្តុះបណ្តាលបន្ត (Follow up training) នឹងត្រូវបានអនុវត្តនៅថ្នាក់ខេត្ត និងស្រុក សម្រាប់អ្នកសម្របសម្រួលខេត្ត ស្រុកទាំងអស់ក្នុង១២ខេត្តក្រុងគោលដៅ (សរុប៤៦១នាក់)។ ឯកសារបណ្តុះបណ្តាលសាមញ្ញនឹងត្រូវបានរៀបចំឡើងវិញនៅថ្នាក់ ខេត្ត ដើម្បីយកទៅបណ្តុះបណ្តាលបន្តនៅថ្នាក់ស្រុក សម្រាប់ក្រុមប្រឹក្សាឃុំ គ.ផ.ថ និងជំនួយការឃុំ ក្នុងឃុំគោលដៅឆ្នាំ២០០៩ ចំនួន៦៣៦ឃុំ (៤នាក់ក្នុង១ឃុំ)។ ចំណាយសម្រាប់ការបណ្តុះបណ្តាលនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក នឹងត្រូវបានគ្រោងដោយអង្គភាពរដ្ឋបាលមូលដ្ឋាន ប្រើប្រាស់ថវិកាប្រតិបត្តិការរបស់ NRML។

ឃ).	**ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែកុម្ភៈ ឆ្នាំ២០០៩	: រៀបចំលក្ខខណ្ឌការងារ និងស្វែងរកអ្នកផ្តល់សេវាកម្ម (វគ្គទី១)
- ខែមីនា ឆ្នាំ២០០៩	: ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត (នៅថ្នាក់ជាតិ)
- ខែមេសា-ឧសភា ឆ្នាំ២០០៩	: ការបណ្តុះបណ្តាលថ្នាក់ខេត្ត និងស្រុក
- ខែកក្កដា ឆ្នាំ២០០៩	: រៀបចំលក្ខខណ្ឌការងារ និងស្វែងរកអ្នកផ្តល់សេវាកម្ម (វគ្គទី២)

- ខែសីហា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត (នៅថ្នាក់ជាតិ)
- ខែកញ្ញា-តុលា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលថ្នាក់ខេត្ត និងស្រុក

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

- ការរៀបចំខ្លឹមសារ និងការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ (វគ្គទី១) : ៥.៧៨១ ដុល្លារ
- ការរៀបចំខ្លឹមសារ និងការបណ្តុះបណ្តាលគ្រូបង្គោលនៅថ្នាក់ជាតិ (វគ្គទី២) : ៥.៧៨១ ដុល្លារ

**សរុប : ១១.៥៦២ ដុល្លារ**

## ២.៤.៥. គោលការណ៍ណែនាំស្តីពីមូលនិធិទ្រទ្រង់ជីវភាពសហគមន៍

**ក). ប្រវត្តិ**

ប្រធានបទស្តីពី **គោលការណ៍ណែនាំស្តីពីមូលនិធិទ្រទ្រង់ជីវភាពសហគមន៍** បានបណ្តុះបណ្តាលដល់អ្នកជំនាញការអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលសហគមន៍ និងអ្នកសម្របសម្រួលឃុំ និងក្រុមប្រឹក្សាឃុំរួចម្តងហើយនៅពេលចាប់ផ្តើមគម្រោង។ ថ្វីត្បិតតែប្រធានបទនេះត្រូវបានបណ្តុះបណ្តាល និងពិភាក្សាក៏ដោយ ក៏អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលសហគមន៍ អ្នកសម្របសម្រួលឃុំ និងក្រុមប្រឹក្សាឃុំនូវតែជួបការលំបាក និងមានភាពមិនច្បាស់លាស់។

ដើម្បីឱ្យអ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលសហគមន៍ និងអ្នកសម្របសម្រួលឃុំ និងក្រុមប្រឹក្សាឃុំអាចអនុវត្តគម្រោងបាន គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប នឹងផ្តល់ការបណ្តុះបណ្តាលឡើងវិញស្តីពី **គោលការណ៍ណែនាំស្តីពីមូលនិធិទ្រទ្រង់ជីវភាពសហគមន៍**។

**ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល**

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពី **គោលការណ៍ណែនាំស្តីពីមូលនិធិទ្រទ្រង់ជីវភាពសហគមន៍** នឹងផ្តោតជាសំខាន់ទៅលើ :

- សេចក្តីណែនាំទូទៅអំពីគោលការណ៍ណែនាំស្តីពីមូលនិធិទ្រទ្រង់ជីវភាពសហគមន៍
- តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ
- ការរៀបចំគម្រោង (និតិវិធីរៀបចំគម្រោងបង្កើតប្រាក់ចំណូល គម្រោងហេដ្ឋារចនាសម្ព័ន្ធសង្គម និងការវិភាគទីផ្សារ)
- ការសិក្សាផលប៉ះពាល់បរិស្ថាន និងការរៀបចំរបាយការណ៍ដីធ្លី
- ការពិនិត្យបញ្ជាក់បច្ចេកទេស និងលទ្ធកម្ម
- ការគ្រប់គ្រងកិច្ចសន្យា
- របាយការណ៍ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

ក្រុមការងារគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាបនៅក្រសួងមហាផ្ទៃនឹងធ្វើការបណ្តុះបណ្តាលដល់អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្របសម្រួលឃុំ នៅតាមខេត្តក្រុងនិមួយៗ លើកលែងខេត្តកំពង់ធំ និងកំពង់ឆ្នាំង នឹងរៀបចំការបណ្តុះបណ្តាលរួមគ្នានៅក្នុងខេត្តកំពង់ធំ ។ បន្ទាប់មកអ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលសហគមន៍ និងអ្នកសម្របសម្រួលឃុំ នឹងរៀបចំការបណ្តុះបណ្តាលបន្តដល់ក្រុមប្រឹក្សាឃុំបន្ត។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាល CDS, CLFT & CF : ៥ថ្ងៃ
- ការបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ និងស្មៀន : ៥ថ្ងៃ

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែ កុម្ភៈ ដល់ មីនា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាល CDS, CLFT & CF
- ខែ មីនា ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ និងស្មៀន

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលថ្នាក់ខេត្ត : ៤០,២២០ ដុល្លារ
- ការបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់ : ៥០,១៥២ ដុល្លារ

**សរុប : ៩០,៣៧២ ដុល្លារ**

## ២.៤.៦. ការងាររដ្ឋបាល និងហិរញ្ញវត្ថុគម្រោង

ក). ប្រវត្តិ

ផ្អែកលើលទ្ធផលនៃការសិក្សាអំពីតម្រូវការបណ្តុះបណ្តាល ការចុះទស្សនកិច្ចសិក្សានៅតាមឃុំ និងសហគមន៍នានា បានបង្ហាញឱ្យឃើញថា អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្របសម្រួលឃុំ ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ជាពិសេសក្រុមអ្នកទទួលផលគម្រោងជួបការលំបាកក្នុងការចុះបញ្ជីលិខិតស្នាម ការរៀបចំទុកដាក់ឯកសារ និងការគ្រប់គ្រងហិរញ្ញវត្ថុ។

ដើម្បីជួយដល់អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្របសម្រួលឃុំ ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ជាពិសេសក្រុមអ្នកទទួលផលគម្រោងលើការងាររដ្ឋបាល និងហិរញ្ញវត្ថុគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប នឹងផ្តល់ការបណ្តុះបណ្តាលស្តីពី **ការងាររដ្ឋបាល និងហិរញ្ញវត្ថុ**។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ប្រធានបទសំខាន់ៗសម្រាប់មេរៀននេះរួមមាន :

- ការគ្រប់គ្រងព័ត៌មានទាក់ទងនឹងការចុះបញ្ជីលិខិតស្នាម

- ការគ្រប់គ្រងឯកសារ
- ការគ្រប់គ្រងថវិកា
- ការគ្រប់គ្រងសម្ភារៈការិយាល័យ និងទិព្វសម្ភារៈ
- តួនាទី និងការទទួលខុសត្រូវ
- ការណាត់ជួប និងការរៀបចំការប្រជុំ

**គ).	យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ក្រុមការងារគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាបនៅក្រសួងមហាផ្ទៃនឹងធ្វើការបណ្តុះបណ្តាលដល់អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្របសម្រួលឃុំនៅតាមបណ្តាខេត្ត ក្រុងនិមួយៗ លើកលែងខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំងនឹងធ្វើការបណ្តុះបណ្តាលរួមគ្នា ដែលនឹងធ្វើនៅខេត្តកំពង់ឆ្នាំង។ បន្ទាប់មក អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្របសម្រួលឃុំ នឹងរៀបចំការបណ្តុះបណ្តាលបន្តដល់ក្រុមអ្នកទទួលផលគម្រោងនៅតាមឃុំគោលដៅរបស់ គម្រោង។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការរៀបចំឯកសារបណ្តុះបណ្តាល : ៣ខែកន្លះ
- ការបណ្តុះបណ្តាល CDS, CLFT & CF : ៣ថ្ងៃ
- ការបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ និងស្មៀន : ៣ថ្ងៃ
- ការបណ្តុះបណ្តាលដល់សហគមន៍ : ៣ថ្ងៃ

**ឃ).	ពេលវេលានៃការបណ្តុះបណ្តាល**

- ខែ មករា-មេសា ឆ្នាំ ២០០៩ : ការរៀបចំឯកសារបណ្តុះបណ្តាល និងខ្លឹមសារមេរៀន
- ខែ មេសា-មិថុនា ឆ្នាំ ២០០៩ : ការបណ្តុះបណ្តាល CDS, CLFT & CF
- ខែ កក្កដា-សីហា ឆ្នាំ ២០០៩ : ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ និងស្មៀន
- ខែ កញ្ញា-វិច្ឆិការ ឆ្នាំ ២០០៩ : ការបណ្តុះបណ្តាលដល់ក្រុមអ្នកទទួលផលគម្រោងបង្កើនប្រាក់ចំណូល និងសមាជិកសហគមន៍នេសាទ

**ង).	ថវិកាបណ្តុះបណ្តាល**

- ការបណ្តុះបណ្តាលថ្នាក់ខេត្ត : ២០,៤៥៧ ដុល្លារ
- ការបណ្តុះបណ្តាលឃុំ សង្កាត់ : ៣០,៣៨៨ ដុល្លារ
- ការបណ្តុះបណ្តាលដល់សហគមន៍: ២០,៣១៣ ដុល្លារ

**សរុប : ៧១,១៥៨ ដុល្លារ**

## ២.៤.៧. ជំនាញសម្របសម្រួលសម្រាប់បុគ្គលិកគម្រោង

ក). ប្រវត្តិ

តាមលទ្ធផលនៃការសិក្សាអំពីតម្រូវការបណ្តុះបណ្តាល បានបង្ហាញឱ្យឃើញថា វគ្គបណ្តុះបណ្តាលអំពី**ជំនាញសម្របសម្រួល** គឺជាតម្រូវការចាំបាច់សម្រាប់ អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្របសម្រួលឃុំ។ ហេតុនេះចាំបាច់ត្រូវទទួលការពង្រឹងសមត្ថភាពជាមុន ពិសេសអំពីជំនាញសម្របសម្រួល។ ដោយមើលឃើញអំពីភាពចាំបាច់នៃការបណ្តុះបណ្តាលអំពីប្រធានបទនេះ ទើបគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប សម្រេចដាក់បញ្ចូលប្រធានបទស្តីពីជំនាញសម្របសម្រួលនេះ។

ខ). **ខ្លឹមសារនៃការបណ្តុះបណ្តាល**

ខ្លឹមសារនៃការបណ្តុះបណ្តាលនេះ ផ្តោតលើប្រធានបទសំខាន់ៗមួយចំនួន ដូចខាងក្រោម :

- បទពិសោធន៍ដែលនាំឱ្យមានការផ្លាស់ប្តូរ
- អាកប្បកិរិយារបស់អ្នកសម្របសម្រួល
- បំណងប្រាថ្នាដើម្បីធ្វើការផ្លាស់ប្តូរ
- ការចូលរួម ពិសេសការចូលរួមរបស់ស្ត្រី
- ជំនាញស្តាប់
- ការនិយាយ ឬការរៀបឃ្លាឡើងវិញ
- របៀបសួរសំណួរ
- ការសម្របសម្រួលការពិភាក្សាក្រុម
- ការដោះស្រាយបញ្ហា
- ឧបករណ៍សម្រាប់ការសម្របសម្រួល
- របៀបសង្កេតដំណើរការ

(តាមឯកសារបណ្តុះបណ្តាលស្តីពីជំនាញសម្របសម្រួល ដែលបោះពុម្ព ខែមីនា ឆ្នាំ២០០៤ របស់ គ.ឃ.ស)។

គ). **យុទ្ធសាស្ត្របណ្តុះបណ្តាល**

ក្រុមការងារគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាបនៅក្រសួងមហាផ្ទៃនឹងធ្វើការបណ្តុះបណ្តាលដល់អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្របសម្រួលឃុំ នៅតាមបណ្តាខេត្ត ក្រុងនិមួយៗ លើកលែងខេត្តកំពង់ធំ និងកំពង់ឆ្នាំងនឹងរៀបចំវគ្គបណ្តុះបណ្តាលរួមគ្នា ដែលនឹងធ្វើនៅខេត្តកំពង់ឆ្នាំង។ **ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាល CDS, CLFT & CF : ៤ថ្ងៃ

ឃ). **ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

- ខែ សីហា-តុលា ឆ្នាំ ២០០៩ : ការរៀបចំឯកសារបណ្តុះបណ្តាល និងខ្លឹមសារមេរៀន
- តុលា-ធ្នូ ឆ្នាំ២០០៩ : បណ្តុះបណ្តាថ្នាក់ខេត្ត
- ខែ វិច្ឆិកា-ធ្នូ ឆ្នាំ ២០០៩ : ការបណ្តុះបណ្តាលថ្នាក់ឃុំ សង្កាត់

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលថ្នាក់ខេត្ត : ២៧,០៤៥ ដុល្លារ
- បណ្តុះបណ្តាលថ្នាក់ឃុំ : ៤០,២៦៤ ដុល្លារ

**សរុប : ៦៧,៣០៩ ដុល្លារ**

## ២.៤.៨. ការរៀបចំសហគមន៍

ក). ប្រវត្តិ

ដើម្បីជួយសម្រួលក្នុងការចងក្រងសហគមន៍អោយកាន់តែមានប្រសិទ្ធភាព ជាពិសេសសម្រាប់គម្រោងបង្កើនប្រាក់ចំណូល គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាបនឹងផ្តល់ការបណ្តុះបណ្តាលស្តីពី**ការរៀបចំសហគមន៍** ដល់អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ អ្នកសម្របសម្រួលឃុំ ក្រុមអ្នកទទួលផលគម្រោងបង្កើតប្រាក់ចំណូល និងសហគមន៍នេសាទ។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលស្តីពីការរៀបចំសហគមន៍ នឹងផ្តោតទៅលើប្រធានបទដូចខាងក្រោម :

- ទស្សនៈទានការអភិវឌ្ឍសហគមន៍
- វដ្តការរៀបចំសហគមន៍
- សមាសធាតុក្នុងដំណើរការរៀបចំសហគមន៍
- គោលការណ៏អភិវឌ្ឍ
- យុទ្ធសាស្ត្រជំរុញការចូលរួមនៅកម្រិតភូមិ
- ជំហាននៃការជំរុញអោយមានការចូលរួម

គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

ក្រុមការងារ LLEE នឹងធ្វើការបណ្តុះបណ្តាលដល់ អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្របសម្រួលឃុំនៅតាមបណ្តារខេត្ត ក្រុងនិមួយៗ លើកលែងខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំងនឹងធ្វើការបណ្តុះបណ្តាលរួមគ្នា ដែលនឹងធ្វើនៅខេត្តកំពង់ធំ។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលដល់ CDS, CLFT & CF : ៤ថ្ងៃ

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែ កុម្ភៈ-មិនា ឆ្នាំ២០០៩ : ការរៀបចំឯកសារបណ្តុះបណ្តាល
- ខែ មេសា-ឧសភា ឆ្នាំ ២០០៩ : ការបណ្តុះបណ្តាលថ្នាក់ខេត្ត
- ខែឧសភា-មិថុនា ឆ្នាំ ២០០៩ : ការបណ្តុះបណ្តាលថ្នាក់ឃុំ

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលថ្នាក់ខេត្ត : ២៧,០៤៥ ដុល្លារ
- ការបណ្តុះបណ្តាលថ្នាក់ឃុំ : ៤០,២៦៤

សរុប : ៦៧,៣០៩ ដុល្លារ

## ២.៤.៩. ការធ្វើផែនការតាមគ្រួសារ

ក). ប្រវត្តិ

ការបណ្តុះបណ្តាលស្តីពី **ការធ្វើផែនការតាមគ្រួសារ** ជាប្រធានបទថ្មីពុំធ្លាប់បានផ្តល់ ការបណ្តុះបណ្តាលដល់អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្រប សម្រួលឃុំទេ។ ផ្អែកតាមលទ្ធផលការសិក្សាពីតម្រូវការបណ្តុះបណ្តាល បានបង្ហាញអោយឃើញថា អ្នកជំនាញការផ្នែកអភិវឌ្ឍ សហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្របសម្រួលឃុំជួបប្រទះការលំបាកក្នុងការចុះប្រមូលព័ត៌មាននៅតាមសហគមន៍។ ដើម្បីជួយដល់អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្របសម្រួលឃុំក្នុងការចុះប្រមូលព័ត៌មាននៅតាមសហគមន៍ គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប នឹងផ្តល់ការបណ្តុះបណ្តាលស្តីពី **ការធ្វើផែនការតាមគ្រួសារ** ។

ខ). **ខ្លឹមសារនៃការបណ្តុះបណ្តាល**

ការបណ្តុះបណ្តាលនឹងផ្តោតលើចំណុចដូចខាងក្រោម :

- វិធីសាស្ត្រប្រមូលទិន្នន័យបែបគុណភាព
- ការកំណត់បញ្ហា តម្រូវការ ដំណោះស្រាយ និងឱកាសរបស់សហគមន៍
- ការកត់ត្រានៅមូលដ្ឋាន ការសរសេររបាយការណ៍ និងការរៀបចំឯកសាររបស់ PRA

គ). **យុទ្ធសាស្ត្របណ្តុះបណ្តាល**

ក្រុមការងារគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាបនៅក្រសួងមហាផ្ទៃនឹងធ្វើការបណ្តុះបណ្តាលដល់អ្នកជំនាញការផ្នែកអភិវឌ្ឍសហគមន៍ ក្រុមសម្របសម្រួលជីវភាពសហគមន៍ និងអ្នកសម្របសម្រួលឃុំនៅតាមបណ្តាខេត្ត ក្រុងនិមួយៗ លើកលែងខេត្តកំពង់ធំ និងខេត្តកំពង់ឆ្នាំងនឹងធ្វើការបណ្តុះបណ្តាលរួមគ្នា ដែលនឹងធ្វើនៅខេត្តកំពង់ឆ្នាំង។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗ មានរយៈពេល៥ថ្ងៃ។**

ឃ). ពេលវេលាសម្រាប់បណ្តុះបណ្តាល

- ខែ មករា ឆ្នាំ ២០០៩ : ការរៀបចំឯកសារបណ្តុះបណ្តាល និងខ្លឹមសារមេរៀន
- ខែ វិច្ឆិការ ឆ្នាំ២០០៩ : បណ្តុះបណ្តាលគ្រូបង្គោល
- ខែ ធ្នូ ឆ្នាំ២០០៩ : បណ្តុះបណ្តាលសាកល្បង
- ខែ ធ្នូ ឆ្នាំ២០០៩ : បណ្តុះបណ្តាលថ្នាក់ខេត្ត

ង). ថវិកាគ្រោងសម្រាប់បណ្តុះបណ្តាល :

- ការបណ្តុះបណ្តាលគ្រូបង្គោល : ៥,៣៣៧ ដុល្លារ
- ការបណ្តុះបណ្តាលថ្នាក់ខេត្ត : ៣៣,៦៣៣

សរុប : ៣៨,៩៧០ ដុល្លារ

## ២.៥. សិក្ខាសាលា ប្រជុំ និងការផ្លាស់ប្តូរបទពិសោធន៍

### ២.៥.១. សិក្ខាសាលាឆ្លុះបញ្ចាំងការអនុវត្តការងាររបស់ក្រុមការងារគណនេយ្យភាព

**ក). ប្រវត្តិ**

ក្រុមការងារគណនេយ្យភាពត្រូវបានបង្កើតឡើង ក្នុងគោលបំណងដើម្បីធានានូវគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាព ក្នុងការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតនៅក្រោមផែនការ សកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.អ.ប និងមូលនិធិឃុំសង្កាត់ ព្រមទាំងរួមចំណែកក្នុងការពង្រឹងការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ស្របតាមគោលការណ៍ច្បាប់។ តាមរយៈសេចក្តីណែនាំថ្មី លេខ ០១២ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ ស្តីការរៀបចំកែសម្រួល និងបង្កើតក្រុមការងារ គណនេយ្យភាពខេត្ត ក្រុង។ គ្រប់ខេត្ត ក្រុងនឹងធ្វើការពិនិត្យឡើងវិញនូវយន្តការក្រុមការងារគណនេយ្យភាពរបស់ខ្លួន។ ទន្ទឹមនឹងនេះ គ.ជ.អ.ប គ្រោងនឹងរៀបចំសិក្ខាសាលាមួយដើម្បីធ្វើការឆ្លុះបញ្ចាំងលើប្រសិទ្ធភាពអនុវត្តការងារ និងបញ្ហាប្រឈម ដើម្បីពង្រឹងអនុវត្តក្រុមការងារគណនេយ្យភាពនេះឱ្យកាន់តែមានប្រសិទ្ធភាព។

**ខ). ខ្លឹមសារសិក្ខាសាលា**

សិក្ខាសាលានេះឆ្លុះបញ្ចាំងដំណើរការអនុវត្តការងាររបស់ក្រុមការងារគណនេយ្យភាព ដែលនឹងត្រូវពិនិត្យមើលយន្តការផ្សព្វផ្សាយព័ត៌មាន នីតិវិធីស៊ើបអង្កេត និងដោះស្រាយពាក្យបណ្តឹង វិធានការណ៍ដាក់វិន័យ និងការរៀបចំរបាយការណ៍។

**គ). យុទ្ធសាស្ត្រនៃសិក្ខាសាលា**

សិក្ខាសាលាជាតិនេះ នឹងត្រូវបានរៀបចំឡើងដោយមានការចូលរួមពីសមាជិកសំខាន់ៗរបស់ក្រុមការងារគណនេយ្យភាពខេត្ត ក្រុងនីមួយៗ ដែលរួមមាន អភិបាលខេត្ត ក្រុង ប្រធានផ្នែកសំខាន់របស់ គ.ប្រ/គ.អ.ជ.ខ និងប្រធានទីប្រឹក្សាកម្មវិធី (៣នាក់/ខេត្ត ក្រុង)។ សិក្ខាសាលានេះមានរយៈពេល០២ថ្ងៃ ដោយមានអ្នកចូលរួមប្រមាណ ៩០នាក់។

**ឃ). ពេលវេលា**

សិក្ខាសាលានឹងគ្រោងរៀបចំនៅខែតុលា ឆ្នាំ២០០៩ ។

**ង). ថវិកាគ្រោងសម្រាប់សិក្ខាសាលា : ៩.២៣៦ ដុល្លារ**

## ២.៥.២. កម្រងបទឧទ្ទេសនាមសម្រាប់មន្ត្រីរាជការ

ក). ប្រវត្តិ

នៅឆ្នាំ ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមដំណើរការកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិតាមរយៈការធ្វើវិមជ្ឈការ ដោយផ្ទេរអំណាច និងមុខងារទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់។ គោលបំណងនៃការធ្វើកំណែទម្រង់របស់រាជរដ្ឋាភិបាល គឺដើម្បីស្ថាបនាលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានតាមរយៈការចូលរួម និងរួមចំណែកនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមដើម្បីឆ្ពោះទៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

កាលពីខែមិថុនា ឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ "ក្របខ័ណ្ឌយុទ្ធសាស្ត្រ សម្រាប់ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ" ដែលពិពណ៌នាអំពីចក្ខុវិស័យ និងគោលបំណងរបស់រដ្ឋាភិបាលសម្រាប់ពង្រីកដំណើរការកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ដោយរួមបញ្ចូលទាំងខេត្ត ក្រុង ស្រុក និងខណ្ឌ។ គោលដៅយុទ្ធសាស្ត្រនេះបានគូសបញ្ជាក់យ៉ាងច្បាស់ថា ដំណើរការនៃកំណែទម្រង់ដែលបានពង្រីកនេះនឹងជះឥទ្ធិពលដល់របៀបធ្វើការបែងចែក រចនាសម្ព័ន្ធខ្សែបណ្តោយក្រសួង និងអនាគតក្រុមប្រឹក្សា និងរដ្ឋបាលនៅថ្នាក់ក្រោមជាតិធ្វើអន្តរកម្មគ្នាទៅវិញទៅមក។ ដូច្នេះ គេអាចរំពឹងទុកថា កំណែទម្រង់នេះនឹងមានផលប៉ះ ពាល់ដល់ការងាររបស់មន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ហេតុនេះហើយទើប គ.ជ.អ.ប សម្រេចបញ្ចូលកម្រងបទឧទ្ទេសនាមស្តីពីក្របខ័ណ្ឌកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសម្រាប់មន្ត្រីរាជការ ទៅក្នុងផែនការកសាងមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

បទឧទ្ទេសនាមផ្តោតលើខ្លឹមសារមួយចំនួនដូចខាងក្រោម :

- ប្រវត្តិអភិបាលកិច្ចមូលដ្ឋាន និងវិមជ្ឈការនៅកម្ពុជា និងទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌច្បាប់
- ទិដ្ឋភាពទូទៅ ទស្សនទាន និងទ្រឹស្តីនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងបរិបទកម្ពុជា និងបទពិសោធន៍នានា
- ក្របខ័ណ្ឌច្បាប់គាំទ្រការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ការបង្ហាញនូវអំណាច និងមុខងាររបស់រាជរដ្ឋាភិបាលកម្ពុជា និងការចែករំលែកអំណាចនឹងមុខងារទៅឱ្យថ្នាក់ក្រោមជាតិ
- គម្រោងសាកល្បង : រដ្ឋបាលស្រុកថ្មី និងការិយាល័យច្រកចេញចូលតែមួយ
- ទិដ្ឋភាពសារពើពន្ធនៃកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ : ទ្រឹស្តីការអនុវត្តរបស់អន្តរជាតិ និងការអនុវត្តនៅកម្ពុជា
- បទពិសោធន៍ជាអន្តរជាតិទាក់ទងនឹងការគ្រប់គ្រងស្ថាប័ន និងធនធានមនុស្សនៅក្នុងបរិបទកំណែទម្រង់អភិបាលកិច្ចថ្នាក់ក្រោមជាតិ

- ការគ្រប់គ្រងមុខងារសាធារណៈនៅកម្ពុជា
- ការរៀបចំមុខងារសាធារណៈនាពេលបច្ចុប្បន្ននៅថ្នាក់ឃុំ សង្កាត់ និងលទ្ធភាពនាពេលអនាគតសម្រាប់ការរៀបចំចាត់តាំងមុខងារសាធារណៈនៅថ្នាក់ក្រោមជាតិ
- ទំនាក់ទំនងអន្តររដ្ឋាភិបាល : ទំនាក់ទំនងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងទំនាក់ទំនងរវាងថ្នាក់ក្រោមជាតិ និងថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន និងលទ្ធភាពនៃទំនាក់ទំនងទាំងនេះនាពេលអនាគត
- បញ្ហាដែលមានលក្ខណៈប្រទាក់ក្រឡា អន្តរវិស័យ (Cross-cutting issue): តួនាទីរបស់សង្គមស៊ីវិល អភិបាលកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រ, ការគិតគូរពិចារណាទៅលើបញ្ហាយេនឌ័រ
- តួនាទីនៃសមាគមរដ្ឋាភិបាលមូលដ្ឋាន : បទពិសោធន៍បានមកពីប្រទេសនានា និងសម្ព័ន្ធជាតិឃុំ សង្កាត់

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

កម្រងបទឧទ្ទេសនាមនឹងត្រូវធ្វើឡើងមួយដងក្នុងមួយខែ ហើយកម្រងបទឧទ្ទេសនាមនេះ អាចធ្វើឡើងចំនួន ២ដងក្នុងមួយខែផងដែរ ប្រសិនបើមានព្រមព្រៀង និងយោគយល់ឱ្យធ្វើការបង្កើនបាន ដោយអាស្រ័យទៅលើធនធាន និងរយៈពេលរៀបចំ។ ការពិនិត្យមើលឡើងវិញទៅលើចំនួនសរុបនៃកម្រងបទឧទ្ទេសនាម អាចនឹងធ្វើទៅបានរហូតដល់ដំណាច់ឆ្នាំ២០០៩។

កាលវិភាគសម្រាប់កម្រងបទឧទ្ទេសនាម នឹងត្រូវរៀបចំទុកជាមុន ដោយមានបញ្ជាក់អំពី ថ្ងៃ ខែ ឆ្នាំ ម៉ោង ប្រធានបទ ទីកន្លែង ហើយនិងវាគ្មិនផងដែរ ប្រសិនបើអាចធ្វើទៅបាន។ ថ្ងៃ ខែ ឆ្នាំ និង ម៉ោង សម្រាប់ការធ្វើបទឧទ្ទេសនាមត្រូវតែកំណត់ឱ្យបានច្បាស់ ជាពិសេសកម្រងបទឧទ្ទេសនាមសម្រាប់មន្ត្រីរាជការ។ ប្រធានបទអាចធ្វើការផ្លាស់ប្តូរបាន ដើម្បីមានលទ្ធភាពសម្របសម្រួលជាមួយមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល/អ្នកជំនាញជាតិ និងអន្តរជាតិដើម្បីធ្វើបទឧទ្ទេសនាម។

បទឧទ្ទេសនាមនីមួយៗមានរយៈពេលបង្រៀនពីរម៉ោង។ បទបង្ហាញ នឹងមានវគ្គសំណួរ និងចម្លើយ និងការពិភាក្សា ដែលមានរយៈពេលមធ្យមចំនួន៤០នាទីផងដែរ។

វាគ្មិន (resource person) ទាំងខ្មែរ និងបរទេសអាចនឹងត្រូវបានអញ្ជើញដើម្បីផ្តល់នូវបទឧទ្ទេសនាម ហើយវាគ្មិនជាតិកម្ពុជាត្រូវបានលើកទឹកចិត្ត ប្រសិនបើអាចស្វែងរកបាន។ ការបកប្រែភាសានឹងត្រូវផ្តល់ក្នុងករណីដែលមានបទឧទ្ទេសនាមក្រៅពីខេមរភាសា។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

បទឧទ្ទេសនាមនឹងធ្វើឡើងក្នុងមួយខែម្តង : ខែមករា - ខែធ្នូ ឆ្នាំ ២០០៩។

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

ប្រហែល ៥០០០ ពាន់ដុល្លារអាមេរិក។

## ២.៥.៣. កម្មវិធីបទឧទ្ទេសនាមសម្រាប់សង្គមស៊ីវិល

### ក). ប្រវត្តិ

កាលពីខែមិថុនា ឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ "ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ" ដែលពិពណ៌នាអំពីចក្ខុវិស័យ និងគោលបំណងរបស់រដ្ឋាភិបាលសម្រាប់ដំណើរការកំណែទម្រង់ និងដើម្បីរៀបចំបែងចែករចនាសម្ព័ន្ធអភិបាលកិច្ចឡើងវិញនៅថ្នាក់ក្រោមជាតិ ។ សេចក្តីពិស្តារអំពីកិច្ចការទាំងនេះ មានចែងលម្អិតក្នុងច្បាប់រៀបចំអង្គការ ដែលទើបបានអនុម័តនាខែឧសភា ឆ្នាំ២០០៨ ។

ដើម្បីកសាងសមត្ថភាព និងពង្រឹងការយល់ដឹងរបស់បណ្តាអង្គការសង្គមស៊ីវិល ក្រុមការងារវិមជ្ឈការតាមរយៈភាពជាដៃគូ (WGPD) នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DoLA) នៃក្រសួងមហាផ្ទៃ ដោយមានការជួយគាំទ្រផ្នែកបច្ចេកទេសពីអង្គការ GTZ តាមរយៈគម្រោងកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (ARDP) បានចូលរួមរៀបចំកម្មវិធីផ្តល់បទឧទ្ទេសនាមលើប្រធានបទសំខាន់ៗមួយចំនួន ដែលកម្មវិធីនេះស្វះស្វែងធ្វើយ៉ាងណាឱ្យអ្នកចូលរួមទទួលបាននូវការយល់ដឹងខាងផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែងលើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ ហេតុដូច្នេះ កម្មវិធីកសាងសមត្ថភាពគឺពិតជាបានរួមចំណែកធ្វើឱ្យយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការមានប្រសិទ្ធភាព និងប្រសិទ្ធផលសម្រាប់រយៈពេលវែងតាមរយៈការផ្តល់សមាជិកសង្គមស៊ីវិលនូវឧបករណ៍ ដើម្បីផ្តល់យោបល់ស្ថាបនាទៅលើការងារ (នៅលើសំណើ) កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏ដូចជាជួយឱ្យបណ្តាអង្គការសង្គមស៊ីវិលអនុវត្តនីកម្មវិធី និងសកម្មភាពរបស់ខ្លួនឱ្យកាន់តែរឹងមាំនៅក្នុងក្របខណ្ឌវិមជ្ឈការ និងវិសហមជ្ឈការដែលមានស្រាប់ ។

### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

បទឧទ្ទេសនាមផ្តោតលើប្រធានបទមួយចំនួនដូចខាងក្រោម :

- ការផ្ទេរមុខងារដល់ថ្នាក់ក្រោមជាតិទៅតាមវិស័យសង្គម (សុខភាព អប់រំ ការអប់រំគ្រប់គ្រងធនធានធម្មជាតិ ការអភិវឌ្ឍជនបទ)
- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងដំណើរការអនុវត្តកម្មវិធីកំណែទម្រង់នេះ
- ថវិកាសរុបដែលត្រូវបានវិភាជន៍ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ
- កិច្ចសហប្រតិបត្តិការអន្តរឃុំ និងសមាគមឃុំ សង្កាត់
- គម្រោងនានារបស់អ្នកផ្តល់ជំនួយ ដែលពាក់ព័ន្ធនឹងវិមជ្ឈការ និង វិសហមជ្ឈការ
- គម្រោងនានារបស់អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដែលពាក់ព័ន្ធនឹងវិមជ្ឈការ និង វិសហមជ្ឈការ
- វិមជ្ឈការ និង វិសហមជ្ឈការ និងបញ្ហាប្រទាក់ក្រឡា (Cross-cutting Issues)
- ការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ

- សកម្មភាពរបស់សង្គមស៊ីវិលនៅក្នុងក្របខណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ
- សង្គមស៊ីវិលក្នុងឋានៈជាភតិសន្យា
- ការបោះឆ្នោតឃុំ សង្កាត់
- ចក្ខុវិស័យរបស់រដ្ឋាភិបាលមូលដ្ឋានទៅលើគម្រោងនានារបស់សង្គមស៊ីវិល

**គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

កម្មវិធីនឹងមានកម្រងបទឧទ្ទេសនាមជាម៉ូឌុលចំរុះ។ បទឧទ្ទេសនាមនឹងបកស្រាយអំពីទស្សនាទានជាមូលដ្ឋានស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ក៏ដូចជារចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ ក្របខណ្ឌច្បាប់ និងគម្រោងដែលគាំទ្រកំណែទម្រង់វិមជ្ឈការ និងឧទាហរណ៍ជាក់ស្តែងនៃការចូលរួមរបស់សង្គមស៊ីវិល។ វិត្ថិន (Resource Persons) នឹងត្រូវបានជ្រើសរើសពីបណ្ឌបណ្ឌិតសភា តំណាងរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អ្នកផ្តល់ជំនួយ ក៏ដូចជាអ្នកជំនាញជាតិ (អន្តរជាតិ)។ បទឧទ្ទេសនាម នឹងត្រូវរៀបចំធ្វើឡើងម្តងក្នុងមួយខែ។

បទឧទ្ទេសនាម នឹងត្រូវធ្វើឡើងជាភាសាខ្មែរ និង/ឬភាសាអង់គ្លេស។ ប្រសិនបើជាភាសាអង់គ្លេសនោះនឹងមានអ្នកបកប្រែភាសា។ បទឧទ្ទេសនាមនឹងត្រូវរៀបចំធ្វើឡើងនៅភ្នំពេញ។

បទឧទ្ទេសនាមនីមួយៗ មានរយៈពេលបង្រៀនពីរម៉ោង ដោយមានបទបង្ហាញ និងមានវគ្គសំណួរ និងចម្លើយ ព្រមទាំងមានការពិភាក្សា ដែលមានរយៈពេលមធ្យមចំនួន៤០នាទីផងដែរ។

វាគ្មិន (resource person) ទាំងខ្មែរ និងបរទេសអាចនឹងត្រូវបានអញ្ជើញដើម្បីផ្តល់នូវបទឧទ្ទេសនាម ហើយវាគ្មិនជាតិកម្ពុជាត្រូវបានលើកទឹកចិត្ត ប្រសិនបើអាចស្វែងរកបាន។ ការបកប្រែភាសានឹងត្រូវផ្តល់ក្នុងករណីដែលមានបទឧទ្ទេសនាមក្រៅពីខេមរភាសា។

**ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល**

បទឧទ្ទេសនាមនឹងធ្វើឡើងក្នុងមួយខែម្តង : ខែមករា - ខែធ្នូ ឆ្នាំ ២០០៩។

**ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល**

ប្រហែល ៥០០០ពាន់ដុល្លារអាមេរិក។

## ២.៥.៤. ការផ្លាស់ប្តូរបទពិសោធន៍រវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាឃុំ សង្កាត់

**ក). ប្រវត្តិ**

បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ នាខែកុម្ភៈ ឆ្នាំ២០០២ ក្រុមប្រឹក្សាឃុំ សង្កាត់ បានទទួលការបណ្តុះបណ្តាល និងអនុវត្តការងារជាច្រើននៅក្នុងឃុំ សង្កាត់ខ្លួន។ លើសពីនេះក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួនក៏បានចូលរួមទស្សនកិច្ចសិក្សា សិក្ខាសាលា និងការប្រជុំនានានៅតាមអង្គភាព និងអង្គការនានានៅក្នុងប្រទេស និងក្រៅប្រទេសផងដែរ។ តាមរយៈការកសាងសមត្ថភាពទាំងអស់នេះ សង្កេតឃើញថា ជារួមសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់មានការកើនឡើងគួរឱ្យកត់សម្គាល់។ ថ្វីត្បិតតែក្រុមប្រឹក្សាឃុំ សង្កាត់ទទួលបាននូវការ

កសាងសមត្ថភាពប្រហាក់ប្រហែលគ្នាក៏ពិតមែន ក៏សមត្ថភាពយល់ដឹង និងការអនុវត្តមានការខុសគ្នាពីឃុំ សង្កាត់មួយទៅឃុំ សង្កាត់មួយ ដែលក្នុងនោះឃុំ សង្កាត់មួយចំនួនបានយល់ដឹងច្រើន និងអនុវត្តការងារបានប្រសើរ ចំណែកឃុំ សង្កាត់មួយចំនួនទៀតអនុវត្តការងារមិនទាន់បានល្អប្រសើរនៅឡើយ។

ចំណេះដឹង និងបទពិសោធន៍ដែលកើតចេញពីការអនុវត្តជាក់ស្តែងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនេះ គឺជាមូលដ្ឋានមួយដ៏ប្រសើរក្នុងការចែករំលែក និងផ្សព្វផ្សាយដល់ក្រុមប្រឹក្សាឃុំ សង្កាត់នានានៅទូទាំងប្រទេស។ ការចែករំលែកបទពិសោធន៍នេះ គឺជាមធ្យោបាយលើកទឹកចិត្តដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យកាន់តែខិតខំប្រឹងប្រែងក្នុងការអនុវត្តការងារថែមទៀត។ ដោយមើលឃើញអំពីសារៈសំខាន់នៃការផ្លាស់ប្តូរបទពិសោធន៍នេះ គ.ជ.អ.ប បានសម្រេចបញ្ចូលសកម្មភាពផ្លាស់ប្តូរបទពិសោធន៍រវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមប្រឹក្សាឃុំ សង្កាត់ទៅក្នុងផែនការកសាងសមត្ថភាពឆ្នាំ២០០៩។

## ខ). ខ្លឹមសារ

គោលបំណងសំខាន់នៃការរៀបចំឱ្យមានការផ្លាស់ប្តូរបទពិសោធន៍នេះ គឺដើម្បីឱ្យក្រុមប្រឹក្សាឃុំ សង្កាត់មានឱកាសដ៏ជាក់លាក់មួយក្នុងការពិភាក្សា និងចែករំលែកបទពិសោធន៍ល្អៗ និងមេរៀនគន្លឹះៗរវាងគ្នានិងគ្នា។

ការផ្លាស់ប្តូរបទពិសោធន៍នេះ នឹងផ្តោតជាសំខាន់ទៅលើការអនុវត្តការងារនានារបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលក្នុងនោះរួមមាន :

- ការងារគ្រប់គ្រងទូទៅរបស់ឃុំ សង្កាត់
- កិច្ចការរដ្ឋបាលឃុំ សង្កាត់
- ការគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- ការកសាងផែនការរបស់ឃុំ សង្កាត់
- ការប្រាស្រ័យទាក់ទងជាមួយស្ថាប័នពាក់ព័ន្ធ
- ការអនុវត្តគម្រោងឃុំ សង្កាត់
- ការលើកកម្ពស់យេនឌ័រ . . . ។ល។

## គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

ការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ នឹងរៀបចំការប្រជុំមួយជាមួយអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង ដើម្បីពិភាក្សាអំពី :

- នីតិវិធីក្នុងការជ្រើសរើសឃុំ សង្កាត់ដែលអនុវត្តការងារបានល្អ និងឃុំ សង្កាត់ដែលអនុវត្តមិនបានល្អ
- របៀបរៀបចំបទបង្ហាញបទពិសោធន៍ និងមេរៀនគន្លឹះៗ
- ការរៀបចំទីតាំងសម្រាប់ធ្វើការបង្ហាញ
- . . . ។ល។

បន្ទាប់មកអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងនីមួយៗជ្រើសរើសឃុំ សង្កាត់ចំនួន២-៦ (ខេត្ត ក្រុងតូច២ មធ្យម៤ និងធំ៦)។ ខេត្ត ក្រុងដែលត្រូវជ្រើសរើសចំនួន :

- ២ឃុំ សង្កាត់ ត្រូវជ្រើសរើសឃុំ សង្កាត់ដែលមានបទពិសោធន៍ល្អចំនួន១ និងឃុំ សង្កាត់ដែលបទពិសោធន៍ មិនល្អចំនួន១
- ៣ឃុំ សង្កាត់ ត្រូវជ្រើសរើសឃុំ សង្កាត់ដែលមានបទពិសោធន៍ល្អចំនួន១ និងឃុំ សង្កាត់ដែលបទពិសោធន៍ មិនល្អចំនួន២
- ៤ឃុំ សង្កាត់ ត្រូវជ្រើសរើសឃុំ សង្កាត់ដែលមានបទពិសោធន៍ល្អចំនួន២ និងឃុំ សង្កាត់ដែលបទពិសោធន៍ មិនល្អចំនួន២
- ៦ឃុំ សង្កាត់ ត្រូវជ្រើសរើសឃុំ សង្កាត់ដែលមានបទពិសោធន៍ល្អចំនួន៣ និងឃុំ សង្កាត់ដែលបទពិសោធន៍ មិនល្អចំនួន៣

បន្ទាប់ពីជ្រើសរើសបានហើយ ខេត្ត ក្រុងនីមួយត្រូវបញ្ជូនឈ្មោះឃុំ សង្កាត់ទាំងនោះ មកការិយាល័យអប់រំ និងកសាងសមត្ថភាពដើម្បីចាត់ចែង និងរៀបចំការផ្លាស់ប្តូរបទពិសោធន៍។

អ្នកចូលរួមនៅក្នុងការផ្លាស់ប្តូរបទពិសោធន៍ រួមមាន :

- មន្ត្រីការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ចំនួន២រូបក្នុងមួយលើកៗ (អ្នកសម្របសម្រួល)
- មន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុងចំនួន០១រូប ក្នុងមួយខេត្ត ក្រុង
- មេឃុំ ចៅសង្កាត់ ស្មៀនឃុំ សង្កាត់ និងក្រុមប្រឹក្សាឃុំ សង្កាត់១នាក់ (៣នាក់ក្នុងមួយឃុំ សង្កាត់)
- ការផ្លាស់ប្តូរបទពិសោធន៍នេះ នឹងរៀបចំនៅក្នុង៦តំបន់ដាច់ដោយឡែកពីគ្នា :
- តំបន់១ : តាកែវ ក្រុងព្រះសីហនុ ក្រុងកែប កំពត និងកោះកុង
- តំបន់២ : កណ្តាល កំពង់ស្ពឺ ភ្នំពេញ និងកំពង់ឆ្នាំង
- តំបន់៣ : កំពង់ចាម ព្រៃវែង និងស្វាយរៀង
- តំបន់៤ : ក្រចេះ ស្ទឹងត្រែង រតនៈគិរី និងមណ្ឌលគិរី
- តំបន់៥ : បាត់ដំបង ប៉ៃលិន ពោធិ៍សាត់ និង បន្ទាយមានជ័យ
- តំបន់៦ : សៀមរាប ព្រះវិហារ ឧត្តរមានជ័យ និងកំពង់ធំ

កម្មវិធីនៅក្នុងការផ្លាស់ប្តូរបទពិសោធន៍នីមួយៗ មានរយៈពេល២ថ្ងៃ :

- ថ្ងៃទី១ : ទស្សនកិច្ចនៅឃុំ សង្កាត់ដែលមានបទពិសោធន៍ល្អ
- ថ្ងៃទី២ : ឆ្លុះបញ្ចាំងលើអ្វីដែលបានរៀនសូត្រ និងការបង្ហាញបទពិសោធន៍ល្អៗរបស់ឃុំ សង្កាត់ ដែលបាន ចូលរួម។

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែសីហា ឆ្នាំ២០០៩ : ប្រជុំពិភាក្សា និងការរៀបចំនានា
- ខែកញ្ញា ឆ្នាំ២០០៩ : ដំណើរការផ្លាស់ប្តូរបទពិសោធន៍ទាំង៦តំបន់

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ប្រជុំពិភាក្សា និងការរៀបចំនានា : ៣.៧៥០ ដុល្លារ
- ការផ្លាស់ប្តូរបទពិសោធន៍ទាំង៦តំបន់ : ២១.៩៩៩ ដុល្លារ

សរុប : ២៥.៧៤៩ ដុល្លារ

## ២.៥.៥. ការវាយតម្លៃសមត្ថភាពស្មៀនឃុំ សង្កាត់

ក). ប្រវត្តិ

ដំណើរការវិមជ្ឈការនៅកម្ពុជាបានចាប់ផ្តើមតាំងពីឆ្នាំ២០០១ តាមរយៈច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ នាខែកុម្ភៈ ឆ្នាំ២០០២ ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី១ ត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋផ្ទាល់ តាមលក្ខណប្រជាធិបតេយ្យ។ នៅក្នុងពេលជាមួយគ្នានោះដែរ រាជរដ្ឋាភិបាលបានរៀបចំឱ្យមានស្មៀននៅឃុំ សង្កាត់ទាំង១.៦២១ ដើម្បីជួយដល់ការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់។

ចាប់តាំងពីជ្រើសរើស និងបំពេញការងារជាស្មៀនឃុំ សង្កាត់មក ស្មៀនឃុំ សង្កាត់ទទួលបានការបណ្តុះបណ្តាលជាច្រើន ដើម្បីឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ច។ ចាប់តាំងពីចូលបម្រើការងារមក ស្មៀនឃុំ សង្កាត់មិនដែលត្រូវបានធ្វើការវាយតម្លៃសមត្ថភាពរបស់ពួកគេទេ។ ការវាយតម្លៃសមត្ថភាពបុគ្គលិក ឬមន្ត្រី គឺជាផ្នែកមួយនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ដែលអង្គភាព ស្ថាប័ននីមួយៗតែងតែអនុវត្តនៅក្នុងអង្គភាព ស្ថាប័នរបស់ខ្លួន។ ដោយមើលឃើញអំពីសារៈសំខាន់នៃការវាយតម្លៃសមត្ថភាពនេះ គ.ជ.អ.ប បានសម្រេចដាក់បញ្ចូលសកម្មភាពវាយតម្លៃសមត្ថភាពស្មៀនឃុំ សង្កាត់ ទៅក្នុងផែនការកសាងសមត្ថភាពឆ្នាំ២០០៩។

ខ). ខ្លឹមសារ

ប្រធានបទសំខាន់ៗដែលស្មៀនឃុំ សង្កាត់បានទទួលការបណ្តុះបណ្តាល នឹងត្រូវបានដាក់ចូលទៅក្នុងបញ្ជីសំណួរសម្រាប់ការវាយតម្លៃ។ ប្រធានបទទាំងនោះ រួមមាន :

- កិច្ចការរដ្ឋបាលឃុំ សង្កាត់
- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- ...។ល។

គ). យុទ្ធសាស្ត្រ

ក្រុមការងារមួយដែលមានសមាសភាពមន្ត្រីមកពីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងនាយកដ្ឋានបុគ្គលិកនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ នឹងត្រូវបង្កើតឡើង។ ក្រុមការងារនេះ ដោយមានជំនួយពីទីប្រឹក្សាបណ្តុះបណ្តាលនៃគម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់ជំហានទី២ (CCDP2) នឹងរៀបចំនីតិវិធី និងបញ្ជីសំណួរសម្រាប់ការវាយតម្លៃស្មៀនឃុំសង្កាត់។ បន្ទាប់ពីរៀបចំរួច ក្រុមការងារនឹងធ្វើតេស្តសាកល្បង។ បន្ទាប់ពីធ្វើតេសសាកល្បងរួច ក្រុមការងារធ្វើការកែសម្រួល ហើយដាក់ជូនទៅ គ.ជ.អ.ប ដើម្បីពិនិត្យ និងសម្រេច។

បន្ទាប់ពីទទួលបានការសម្រេចពី គ.ជ.អ.ប ការិយាល័យអប់រំ និងកសាងសមត្ថភាព នាយកដ្ឋានរដ្ឋបាលមូលដ្ឋានសហការជាមួយក្រុមការងារ នឹងធ្វើការបណ្តុះបណ្តាលដល់មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋានចំនួន៣០នាក់ ចំនួន២ថ្ងៃ។ មន្ត្រីដែលបានទទួលការបណ្តុះបណ្តាល នឹងចុះទៅត្រួតពិនិត្យការវាយតម្លៃសមត្ថភាពស្មៀនឃុំ សង្កាត់ នៅ២៤ខេត្ត ក្រុង។

ឃ). ពេលវេលា

- ខែឧសភា ឆ្នាំ២០០៩ : ការរៀបចំឯកសារ និងធ្វើតេស្តសាកល្បង
- ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ : ការវាយតម្លៃសមត្ថភាពស្មៀនឃុំ សង្កាត់

ង). ថវិកា

- ការរៀបចំឯកសារ និងធ្វើតេស្តសាកល្បង : ៦.៣៤០ ដុល្លារ
- ការវាយតម្លៃសមត្ថភាពស្មៀនឃុំ សង្កាត់ : ១៧.០៤៦ ដុល្លារ

*សរុប* : **២៣.៣៨៦ ដុល្លារ**

## ២.៥.៦. វេទិកាបណ្តាញស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់

ក). ប្រវត្តិ

វេទិកាស្ត្រីក្រុមប្រឹក្សាឃុំបានអនុវត្តដោយអង្គការចំរើនស្ត្រី ដោយមានជំនួយបច្ចេកទេសពីគម្រោងកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ អនុវត្តដោយអង្គការជីធីហ្សេត ក្រោមកិច្ចសហប្រតិបត្តិការគាំទ្រពីក្រសួងមហាផ្ទៃ ពិសេសអគ្គនាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន។ គម្រោងនេះបានអនុវត្តនៅក្នុងខេត្តចំនួន៩ គឺ : ខេត្តកណ្តាល ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តព្រះវិហារ ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តពោធិសាត់។

យុទ្ធសាស្ត្រចេញត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០០៧ រហូតដល់ឆ្នាំ២០០៨។ ឆ្នាំ២០០៨ គឺជាឆ្នាំចុងក្រោយនៃការអនុវត្តយុទ្ធសាស្ត្រ ដោយសារគម្រោងបានចាប់ផ្តើមក្នុងខែមីនា ឆ្នាំ២០០៨ ដូចនេះគម្រោងសម្រាប់ឆ្នាំ២០០៨ ក៏ត្រូវបញ្ចប់វិញនៅក្នុងខែមីនា ឆ្នាំ២០០៩ដែរ។ គម្រោងនេះបានរៀបចំវេទិកាចំនួនបីដងក្នុងមួយឆ្នាំនៅក្នុងខេត្តគោលដៅដោយមានស្ត្រីក្រុមប្រឹក្សាឃុំចំនួន៣៣ នាក់ចូលរួមជាប្រចាំ។

ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

វេទិកាមានគោលដៅលើកកម្ពស់សមត្ថភាពរបស់ស្ត្រីក្រុមប្រឹក្សាឃុំក្នុងតួនាទីជាក្រុមប្រឹក្សាឃុំ សង្កាត់។ ស្ត្រីក្រុមប្រឹក្សាឃុំជាអ្នកសម្របសម្រួល ដឹកនាំវេទិកា ហើយប្រធានបទដែលត្រូវធ្វើការពិភាក្សានៅក្នុងវេទិកា គឺត្រូវកំណត់ដោយស្ត្រីក្រុមប្រឹក្សាខ្លួនឯងផ្ទាល់តាមរយៈការចាត់អាទិភាព ដែលស្ត្រីជាអ្នកចូលរួមឱ្យអាទិភាពខ្ពស់ជាងគេ។

គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

វេទិកាមានវិធីសាស្ត្រផ្ទាល់របស់ខ្លួនដោយ ពង្រឹងសមត្ថភាពក្នុងរៀបចំដោយខ្លួនឯង និងរៀនសូត្រដោយខ្លួនឯង។ មានន័យថាស្ត្រីក្រុមប្រឹក្សាឃុំជាអ្នកដឹកនាំ ចាត់ចែង និងរៀបចំវេទិកាដោយខ្លួនឯង។ ដោយសារវេទិកាមិនទាន់ស្ថិតនៅក្នុងភាពជាម្ចាស់ពេញទីពីសំណាក់ស្ត្រី ក្រុមប្រឹក្សាឃុំ អង្គការចំរើននៅមានតួនាទីសំខាន់ក្នុងការជួយផ្តល់ការបង្វឹក និងណែនាំដល់ស្ត្រីក្រុមប្រឹក្សាឃុំចំពោះការរៀបចំ។ ការរៀបចំវេទិកាគឺមានបីដងក្នុងមួយឆ្នាំនៅក្នុងខេត្តនីមួយៗ។

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

សម្រាប់ឆ្នាំ២០០៩ គម្រោងកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការនៅបន្តការគាំទ្ររហូតដល់ខែមីនា ឆ្នាំ២០០៩។ របៀបក្នុងការគាំទ្របន្ត និងត្រូវកំណត់នៅពេលមានកិច្ចប្រជុំសម្រេចចុងក្រោយក្នុងខែមីនា ឆ្នាំ២០០៩ ជាមួយនឹងអ្នកពាក់ព័ន្ធនៃវេទិកា។

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

ថវិកាដែលបានគាំទ្រចំពោះគម្រោងនេះមាន **២៥.000 ដុល្លា**

## ២.៥.៧. វេទិកាសាធារណៈនៅមូលដ្ឋាន

ក). ប្រវត្តិ

នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ និងគម្រោងអភិវឌ្ឍន៏ក្រុមប្រឹក្សាឃុំ សង្កាត់ដំណាក់កាលទី២ មានគម្រោងចុះកិច្ចសន្យាជាមួយអង្គការ NECFIC ដើម្បីរៀបចំឱ្យមានវេទិកាសាធារណៈនៅមូលដ្ឋាន នៅតាមឃុំ សង្កាត់មួយចំនួនដែលនឹងត្រូវជ្រើសរើស ហើយធ្វើឡើងក្នុងខេត្ត ក្រុងចំនួន១៩ នៅទូទាំងប្រទេស។ វេទិកាសាធារណៈនៅមូលដ្ឋាននេះ គឺជាសកម្មភាពមួយបន្តពីសកម្មភាពនៃគម្រោងអភិវឌ្ឍន៏ក្រុមប្រឹក្សាឃុំ សង្កាត់ដំណាក់កាលទី១ ដែលពេលនោះមានឈ្មោះថា "**ការសម្តែងសិល្បៈ**"។ សកម្មភាពនេះ គឺជាផ្នែកមួយនៅក្នុងយុទ្ធនាការស្តីពីបង្កើនការយល់ដឹងដល់សាធារណជនទៅលើកំណែទម្រង់វិមជ្ឈការ តួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងតួនាទីរបស់ប្រជាពលរដ្ឋនៅក្នុងដំណើរការកំណែទម្រង់នេះ។ គោលបំណងសំខាន់នៃវេទិកាសាធារណៈនេះ គឺដើម្បីឱ្យប្រជាពលរដ្ឋដែលរស់នៅតាមទីជនបទមានឱកាសក្នុងការជជែកវែកញែកជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនលើបញ្ហាសង្គម សន្តិសុខ ការអភិវឌ្ឍ . . . ដែលកើតមាននៅក្នុងមូលដ្ឋានរបស់ខ្លួន។

**ខ). ខ្លឹមសារនៃវេទិកាសាធារណៈនៅមូលដ្ឋាន**

វេទិកាសាធារណៈនៅមូលដ្ឋាន នឹងចាប់ផ្តើមដោយផ្តោតការយកចិត្តទុកដាក់លើការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចនារី និងកុមារឃុំ សង្កាត់ ដែលមានចែងនៅក្នុងសេចក្តីណែនាំលេខ ០៨២ ស.ណ.ន/គ.ជ.អ.ប ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧។ បន្ទាប់មកនឹងបើកឱ្យមានការជជែកលើរបៀបវារៈផ្សេងៗទៀតដែលទាក់ទងនឹងការងាររបស់ឃុំ សង្កាត់។ ការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងអង្គការ NICFEC នឹងរៀបចំក្រុមការងារមួយ ដើម្បីអនុវត្ត តាមដាន និងវាយតម្លៃសកម្មភាពនេះ។

**គ). យុទ្ធសាស្ត្រនៃការរៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន**

វេទិកាសាធារណៈនៅមូលដ្ឋាននីមួយៗ នឹងត្រូវរៀបចំឡើងពេញមួយព្រឹក ប្រហែល៣-៤ម៉ោង ដោយមានការបញ្ចាំងខ្សែភាពយន្ត និងមានការចែកខិតប័ណ្ណផ្សេងៗដែលទាក់ទងនឹងបរិបទខាងលើ។ NICFEC នឹងធ្វើការបណ្តុះបណ្តាលដល់អ្នកសម្របសម្រួលវេទិកាទាំងអស់របស់ខ្លួន មុនពេលពួកគេចេញទៅសម្របសម្រួលនៅតាមវេទិកានីមួយៗ។ អ្នកដែលត្រូវចូលរួមក្នុងវេទិកានេះ រួមមាន ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ និងប្រជាពលរដ្ឋ។ នៅក្នុងឆ្នាំ២០០៨នេះ នឹងមានការរៀបចំវេទិកាចំនួន**២០០លើក** នៅកន្លែងខុសៗគ្នា ហើយវេទិកាចំនួន**២០០លើក**ទៀតនឹងត្រូវធ្វើនៅក្នុងឆ្នាំ២០០៩។ ការកំណត់ទីតាំង ការជាវខ្សែភាពយន្តខ្មែរ ការរៀបចំឆាកដែលអាចបញ្ចាំងពេលថ្ងៃបាន ការអញ្ជើញអ្នកចូលរួមត្រូវតែត្រៀមលក្ខណៈជាមុនដោយ NICFEC។ អង្គការ NICFEC នឹងប្រើប្រាស់ក្រុមបណ្តាញការងារនៅមូលដ្ឋានរបស់ខ្លួន ដើម្បីប្រមែប្រមូលអ្នកចូលរួម។

**ឃ). ពេលវេលានៃការរៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន**

- ខែមករា-មីនា ឆ្នាំ២០០៩ : ការរៀបចំនានា
- ខែមីនា-ឧសភា និងខែកញ្ញា-វិច្ឆិកា ឆ្នាំ២០០៩ : វេទិកាសាធារណៈនៅមូលដ្ឋាន
- ខែមិថុនា និងខែធ្នូ ឆ្នាំ២០០៩ : ការវាយតម្លៃវេទិកាសាធារណៈនៅមូលដ្ឋាន

**ង). ថវិកាគ្រោងសម្រាប់រៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន**

- ការរៀបចំ និងដំណើរការវេទិកាសាធារណៈនៅមូលដ្ឋាន ឆ្នាំ២០០៩ : **១៩០,០០០ដុល្លារ**

## ២.៥.៨. វេទិកាគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

**ក). ប្រវត្តិ**

តាមរយៈលទ្ធផលនៃការសិក្សាវាយតម្លៃឃើញថា វេទិកាដែលរៀបចំកន្លងមកសម្រាប់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់កន្លងមកឃើញថា ការរៀបចំវេទិកានេះមានសារៈសំខាន់ និងចាំបាច់ណាស់ក្នុងការចែករំលែកបទពិសោធន៍រវាងគណៈកម្មាធិការ ក្នុងទិសដៅដើម្បីជំរុញឱ្យការផ្តល់សេវាសង្គមកាន់តែមានគុណភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

ដោយយល់ឃើញពីភាពចាំបាច់ដូចខាងលើ គ.ជ.អ.ប បានសម្រេចបញ្ចូលការរៀបចំវេទិកាគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ទៅក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

**ខ). ខ្លឹមសារ**

វេទិកានឹងផ្តោតលើខ្លឹមសារមួយចំនួនដូចខាងក្រោម :

- សិទ្ធិកុមារ
- កិច្ចការពារកុមារ
- ការអប់រំកុមារ
- ទឹកស្អាត និងអនាម័យ
- អាហាររូបត្ថម្ភ

**គ). យុទ្ធសាស្ត្រ**

វេទិកាចំនួន៤២នឹងត្រូវរៀបចំឡើងសម្រាប់២៥៧គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ដែលនឹងរៀបចំឡើងដោយអង្គការចំរើនស្ត្រី ដោយមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងមហាផ្ទៃ អង្គភាពរដ្ឋបាលមូលដ្ឋាន និងមន្ទីរកិច្ចការនារីខេត្ត។

**ឃ). ពេលវេលា**

- មករា-ធ្នូ : ការរៀបចំ និងអនុវត្តវេទិកា

**ង). ថវិកាគ្រោង**

- ថវិកាគ្រោងសម្រាប់សកម្មភាពនេះមាន **៦០.៥៤៧ដុល្លារ**

## ២.៦. ការបណ្តុះបណ្តាលថ្នាក់ខេត្ត ក្រុងសម្រាប់គាំទ្រឃុំ សង្កាត់

### ២.៦.១. យេនឌ័រនៅក្នុងវិមជ្ឈការ

#### ក). ប្រវត្តិ

ការចូលរួមដោយផ្ទាល់ និងជាតំណាងដោយស្មើភាពគ្នារវាងបុរស និងស្ត្រីនៅក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ គឺជាល័ក្ខខ័ណ្ឌមួយដើម្បីសម្រេចនូវគោលដៅនៃការធ្វើកំណែទម្រង់។ ដើម្បីសម្រេចនូវល័ក្ខខ័ណ្ឌខាងលើនេះ ការកសាងសមត្ថភាពស្តីពីយេនឌ័រនៅក្នុងវិមជ្ឈការដល់អ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ ជាកិច្ចការមួយយ៉ាងសំខាន់។ ហេតុនេះបានជាក្នុងឆ្នាំ២០០៩ គ.ជ.អ.ប នឹងផ្តល់វគ្គបណ្តុះបណ្តាលអំពីយេនឌ័រនៅក្នុងវិមជ្ឈការសម្រាប់មន្ត្រីសម្របសម្រួលថ្នាក់ស្រុកទាំងអស់។ បន្ទាប់ពីទទួលបានការសម្រេចពី គ.ជ.អ.ប ការិយាល័យអប់រំ និងកសាងសមត្ថភាពសហការជាមួយក្រុមការងារយេនឌ័រនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នឹងរៀបចំការបណ្តុះបណ្តាលដល់មន្ត្រីសម្របសម្រួលថ្នាក់ស្រុក ដោយបញ្ចូលប្រធានបទនេះទៅក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.អ.ប ឆ្នាំ២០០៩។

#### ខ). ខ្លឹមសារនៃការបណ្តុះបណ្តាល

ខ្លឹមសារនៃការបណ្តុះបណ្តាលនេះនឹងផ្តោតជាសំខាន់ទៅលើ :

- បញ្ញត្តិយេនឌ័រ
- យេនឌ័រនៅក្នុងគោលនយោបាយជាតិ
- ការវិភាគ និងការបញ្ជ្រាបយេនឌ័រ
- យេនឌ័រ និងវិមជ្ឈការ
- យេនឌ័រនៅក្នុងការងាររបស់អ្នកសម្របសម្រួលខេត្ត ក្រុង ស្រុក ខណ្ឌ
- យេនឌ័រនិងអំពើហឹង្សាក្នុងគ្រួសារ

ក្រុមការងាររៀបចំមេរៀន ដោយមានជំនួយពីអ្នកជំនាញយេនឌ័រ នឹងពិនិត្យមើលឡើងវិញនូវខ្លឹមសារមេរៀនស្តីពីយេនឌ័រនៅក្នុងវិមជ្ឈការដែលបានបណ្តុះបណ្តាលដល់មន្ត្រីសំរបសំរួលថ្នាក់ស្រុក និងបច្ចុប្បន្នភាព ខ្លឹមសារមួយចំនួន រួចដាក់ជូន គ.ជ.អ.ប ដើម្បីពិនិត្យ និងអនុម័ត។

#### គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

បន្ទាប់ពីទទួលបានការឯកភាពពី គ.ជ.អ.ប ការិយាល័យអប់រំ និងកសាងសមត្ថភាពនៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន សហការជាមួយក្រុមការងាររៀបចំមេរៀននេះ នឹងបណ្តុះបណ្តាលដល់មន្ត្រីសំរបសំរួលថ្នាក់ស្រុក ដែលជាមន្ត្រីមកពីខេត្ត ក្រុងទាំង២៤។ ខេត្ត ក្រុងនីមួយៗនឹងចាត់បញ្ជូនមន្ត្រីសំរបសំរួលថ្នាក់ស្រុកទាំងអស់ចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពីយេនឌ័រ និងវិមជ្ឈការ។ ក្រុមគ្រូបង្គោលជាអ្នកបណ្តុះបណ្តាលដល់អ្នកសម្របសម្រួលថ្នាក់ខេត្ត ក្រុង និងថ្នាក់ស្រុក ខណ្ឌទាំងអស់។

**ចំនួនថ្ងៃនៃការបណ្តុះបណ្តាលតាមថ្នាក់នីមួយៗមានដូចខាងក្រោម :**

- ការបណ្តុះបណ្តាលថ្នាក់ខេត្ត : ០៣ថ្ងៃ

ឃ). ពេលវេលាសម្រាប់ការបណ្តុះបណ្តាល

- ខែមករា-កុម្ភៈ ឆ្នាំ២០០៩ : ការបណ្តុះបណ្តាលថ្នាក់ខេត្ត ក្រុង

ង). ថវិកាគ្រោងសម្រាប់ការបណ្តុះបណ្តាល

- ការបណ្តុះបណ្តាលក្រុមអ្នកសម្របសម្រួលខេត្ត ក្រុង ស្រុក ខណ្ឌ : **២៩.០០០ដុល្លារ**

## ២.៦.២. វគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីស៊ើបអង្កេតពាក្យបណ្តឹងតវ៉ា

ក). ប្រវត្តិ

ចាប់តាំងពីចុងឆ្នាំ២០០៥ នៅគ្រប់ខេត្ត ក្រុងទាំងអស់បានបង្កើតក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុងរបស់ខ្លួន ដោយយោងលើសេចក្តីសម្រេចលេខ ០២៨ ស.ស.រ/គ.ឃ.ស ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៥ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ស្តីពីការបង្កើតក្រុមការងារគណនេយ្យភាពមូលនិធិឃុំ សង្កាត់ថ្នាក់ខេត្ត ក្រុង ។

យោងលើអនុសាសន៍ទទួលបានពីការសិក្សាវាយតម្លៃមួយនៅឆ្នាំ ២០០៧ គ.ជ.វ.វ បានចេញសេចក្តីណែនាំថ្មីលេខ ០១២ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨ ស្តីការរៀបចំកែសម្រួល និងបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុង។ ការបង្កើតក្រុមការងារគណនេយ្យភាពខេត្ត ក្រុងនេះ គឺដើម្បីធានានូវគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាព ក្នុងការប្រើប្រាស់ថវិកាគ្រប់ប្រភពទាំងអស់ ដែលអនុវត្តដោយរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថិតនៅក្រោមផែនការ សកម្មភាព និងថវិកាប្រចាំឆ្នាំ ដែលសម្របសម្រួល និងប្រើប្រាស់រចនាសម្ព័ន្ធរបស់ គ.ជ.វ.វ និងមូលនិធិឃុំ សង្កាត់ ព្រមទាំងរួមចំណែកក្នុងការពង្រឹងការអនុវត្តការងាររបស់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ស្របតាមគោលការណ៍ច្បាប់ ។ យោងតាមសម្រេចណែនាំថ្មីនេះ ក្រុមការងារគណនេយ្យភាពខេត្ត ក្រុងនឹងត្រូវបង្កើតក្រុមគាំទ្រដែលមានសមាសភាព ១-៣ រូប ដើម្បីជួយកិច្ចការប្រចាំថ្ងៃ។ ដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តការងារក្រុមគាំទ្រនៅខេត្ត ក្រុងទាំង ៤២ រូបនេះនឹងត្រូវទទួលការណែនាំ និងបណ្តុះបណ្តាល អំពីនីតិវិធីស៊ើបអង្កេតពាក្យបណ្តឹង ។

ខ). ខ្លឹមសារនៃវគ្គបណ្តុះបណ្តាល

ការបណ្តុះបណ្តាលនេះផ្តោតលើប្រធានបទសំខាន់ៗ រួមមានៈ

- គោលការណ៍ចំបងៗក្នុងការដោះស្រាយពាក្យបណ្តឹង
- វិធីសាស្ត្រស៊ើបអង្កេត
- ការវិភាគ និងការរៀបចំរបាយការណ៍
- ការពិនិត្យលើទណ្ឌកម្ម និងវិធានការណ៍ដាក់វិន័យ ។

គ). យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល

ក្រុមគាំទ្រនៅថ្នាក់ជាតិ ដោយមានការគាំទ្រពីទីប្រឹក្សានឹងធ្វើការបណ្តុះបណ្តាលផ្ទាល់ដល់មន្ត្រីគាំទ្រខេត្ត

ក្រុងដែលទទួលបន្ទុកការងារគណនេយ្យភាព។ ការបណ្តុះបណ្តាលនេះនឹងចែកជា ២ វគ្គនៅតាមតំបន់ផ្សេងៗគ្នា ដោយក្នុង១វគ្គៗមានរយៈពេល៣ថ្ងៃ។ សិក្ខាកាមដែល ត្រូវចូលរួមមានចំនួនសរុប២៥ នាក់ក្នុង១វគ្គ។

**ឃ).	ពេលវេលា**

វគ្គបណ្តុះបណ្តាលនឹងគ្រោងរៀបចំនៅខែមីនា ឆ្នាំ២០០៩ ។

**ង).	ថវិកាគ្រោងសម្រាប់សិក្ខាសាលា	: ៦.៨៤៦ ដុល្លារ**

## ២.៦.៣. ប្រព័ន្ធតាមដាន និងរបាយការណ៍

**ក).	ប្រវត្តិ**

នៅឆ្នាំ ២០០៨ ក្រុមការងាររបស់នាយកដ្ឋានបានធ្វើការកែសម្រួលទម្រង់របាយការណ៍ប្រចាំខែ ត្រីមាស និងឆ្នាំ សម្រាប់អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង។ ទម្រង់របាយការណ៍ថ្មីនេះ ត្រូវបានធ្វើការសាកល្បងនៅខេត្តកំពង់ចាម ដោយមានការចូលរួមពីមន្ត្រីសំខាន់ៗមកពីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្តចំនួន២ទៀត ដើម្បីពិនិត្យនិងផ្តល់មតិកែសម្រួលលើខ្លឹមសារនៃសេចក្តីព្រាងដែលបានរៀបចំ។ សេចក្តីព្រាងចុងក្រោយលើខ្លឹមសារនៃប្រព័ន្ធរបាយការណ៍ទាំងនេះត្រូវបានដាក់ជូនអង្គប្រជុំរបស់នាយកដ្ឋាន ដែលមានសមាសភាពមកគ្រប់ការិយាល័យចំណុះឱ្យនាយដ្ឋាន ដើម្បីធ្វើការពិនិត្យ និងផ្តល់យោបល់បន្ថែមឱ្យកាន់តែមានភាពច្បាស់លាស់ និងស្របស្រម។ ម្យ៉ាងវិញទៀត អង្គភាពរដ្ឋបាលមូលដ្ឋានបានប្រើប្រាស់ តារាងតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ (Monitoring Spreadsheet) ក្នុងការកត់ត្រាព័ត៌មានលើផ្នែកបណ្តុះបណ្តាល ហិរញ្ញវត្ថុ ផែនការ និងការដាក់ជូនរបាយការណ៍របស់ឃុំ សង្កាត់ជារៀងរាល់ខែ។ តារាងតាមដានខាងលើនេះ តម្រូវឱ្យធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ និងកែសម្រួលបន្ថែមខ្លឹមសារឱ្យបានគ្រប់ជ្រុងជ្រោយ។ ហេតុដូចនេះ នាយកដ្ឋានគ្រោងនឹងធ្វើការបណ្តុះបណ្តាលលើប្រព័ន្ធរបាយការណ៍និងតារាងតាមដានទាំងនេះ ដល់មន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត ក្រុង។

**ខ).	ខ្លឹមសារនៃការបណ្តុះបណ្តាល**

ការបណ្តុះបណ្តាលនេះផ្តោតលើប្រព័ន្ធរបាយការណ៍របស់អង្គភាពរដ្ឋបាលមូលដ្ឋាន និងការបំពេញតារាងតាមដានគោលនយោបាយវិមជ្ឈការថ្នាក់ឃុំ សង្កាត់។

**គ).	យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល**

ការបណ្តុះបណ្តាលរយៈពេល០២ថ្ងៃនេះនឹងត្រូវធ្វើឡើងនៅ២តំបន់ ដាច់ពីគ្នា។ ក្នុងមួយតំបន់មានអ្នកចូលរួមប្រហែល២៤នាក់ មកពី១២ខេត្ត ក្រុង (២នាក់/ខេត្ត ក្រុង) ដែលជាមន្ត្រីអង្គភាពរដ្ឋបាលមូលដ្ឋាន។

**ឃ).	ពេលវេលា**

ការបណ្តុះបណ្តាលនឹងគ្រោងរៀបចំនៅខែឧសភា ឆ្នាំ២០០៩ ។

**ង).	ថវិកាគ្រោងសម្រាប់បណ្តុះបណ្តាល**

រៀបចំ និងបណ្តុះបណ្តាលដល់ក្រុមគោលដៅ	**: ៦.២៩២ ដុល្លារ**

## ២.៧. ការអប់រំផ្សព្វផ្សាយសាធារណៈសម្រាប់ឃុំ សង្កាត់

### ២.៧.១. កម្មវិធីផ្សព្វផ្សាយតាមទូរទស្សន៍

ក). ប្រវត្តិ

នៅក្នុងឆ្នាំ ២០០៨ ការផលិតស្ប៉ត់លើសារសំខាន់បានបញ្ចប់ ហើយការផ្សព្វផ្សាយនឹងប្រព្រឹត្តិទៅនៅចុងឆ្នាំ ២០០៨ ហើយត្រូវបន្តរហូតដល់ពាក់កណ្តាលឆ្នាំ២០០៩។

នេះជាការបន្ថែមទៅនឹងវេទិកាសាធារណៈ និងការបង្កើតកម្មវិធីផ្សេងៗតាមវិទ្យុរបស់គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់ ដំណាក់កាលទី២ (CCDP-2) ដែលបាននឹងកំពុងបន្តប្រើប្រាស់មធ្យោបាយតាមប្រព័ន្ធព័ត៌មាននានា ដើម្បីបន្ថែមការយល់ដឹងពីអភិបាលកិច្ចមូលដ្ឋាន លិទ្ធិប្រជាធិបតេយ្យ ការអភិវឌ្ឍមូលដ្ឋាន និងគណៈនេយ្យភាព។ មធ្យោបាយមានដែលនឹងត្រូវប្រើប្រាស់បែបស្ប៉ត់ផ្សព្វផ្សាយទូរទស្សន៍នេះ អាចនិយាយបានថា ជាមធ្យោបាយដ៏មានប្រជាប្រិយភាពបំផុតនៅកម្ពុជាក្នុងពេលបច្ចុប្បន្ននេះ។ ផ្អែកតាមលទ្ធផលនៃការប៉ាន់ប្រមាណពីតម្រូវការនៃការបណ្តុះបណ្តាលដែលបានធ្វើឡើងដោយ ការិយាល័យអប់រំ និងកសាងសមត្ថភាពរបស់ DoLA បានបង្ហាញថាការចាក់ស្ប៉ត់តាមទូរទស្សន៍គឺអាចមើលឃើញ និងទាក់ទាញបំផុតពីសំណាក់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋដ៏ច្រើនបំផុតផងដែរ។

ខ). ខ្លឹមសារ

មនុស្សទាំងអស់នឹងទទួលអត្ថប្រយោជន៍ពីយុទ្ធនាការនៃការផ្សព្វផ្សាយព័ត៌មាននេះ។ ខ្លឹមសារសំខាន់បំផុតរបស់ស្ប៉ត់ទាំងទូរទស្សន៍ នឹងគ្របដណ្តប់លើចំនុចសំខាន់ៗដូចខាងក្រោមនេះ :

- ព័ត៌មានទូទៅទាក់ទងនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ :
  - ទំនាក់ទំនងរវាងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរវិស័យ
  - ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
  - ការកសាងផែនការអភិវឌ្ឍន៍ក្នុងក្របខ័ណ្ឌច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
  - ការផ្ទេរមុខងារនៅក្នុងក្របខ័ណ្ឌច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- តួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការផ្តល់សេវាកម្មនៅមូលដ្ឋាន
- លើកទឹកចិត្តឱ្យមានសម្លេងរបស់ប្រជាពលរដ្ឋ និងការចូលរួមរបស់គាត់ក្នុងកិច្ចការអភិវឌ្ឍន៍មូលដ្ឋាន
- ជំរុញ និងលើកទឹកចិត្តឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើផែនការ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន។

គ). យុទ្ធសាស្រ្ត

DoLA បានចុះកិច្ចសន្យារួចហើយជាមួយជាមួយអង្គការ Equal Access Cambodia (EAC) ដែលមានឯកទេសនៅក្នុងការផលិតស្ប៉ត់ទូរទស្សន៍ ស្ប៉ត់វិទ្យុ កម្មវិធីតាមវិទ្យុ ដែលឆ្លងតាមរយៈដំណើរការនៃការដេញថ្លៃ។

EAC នឹងដាក់ស្នើមក DoLA ដើម្បីពិនិត្យ និងសម្រេចលើខ្លឹមសារកម្រងសំណេរស្ប៉ត់លើសារសំខាន់៥ចុងក្រោយ។ សារសំខាន់ទាំង៥ នឹងត្រូវសម្រេចដោយថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ មុនពេលឈានដល់ការផលិត។ ក្រោយការផលិត ក្រសួងមហាផ្ទៃនឹងត្រូវសម្រេចជាចុងក្រោយមុនពេលផ្សព្វផ្សាយស្ប៉ត់តាមស្ថានីយទូរទស្សន៍នានា។ DoLA ក៏បានចុះកិច្ចសន្យាផងដែរជាមួយក្រុមហ៊ុន International Media Services (IMS) ដើម្បីធ្វើការផ្សព្វផ្សាយតាមរលកធាតុអាកាសនូវស្ប៉ត់ដែលផលិតរួចតាមស្ថានីយទូរទស្សន៍សំខាន់បី គឺ CTN បាយ័ន និងទូរទស្សន៍ជាតិកម្ពុជា។

ឃ). ពេលវេលា

- ការចាក់ផ្សាយសម្រាប់សារសំខាន់ ៥ ដំបូង : ធ្នូ ២០០៨ ដល់ ឧសភា ២០០៩
- ការផលិតស្ប៉ត់សម្រាប់សារសំខាន់ ៥ ចុងក្រោយ : មករា ២០០៩ ដល់ មេសា ២០០៩
- ការចាក់ផ្សាយសម្រាប់សារសំខាន់ ៥ ចុងក្រោយ : ឧសភា ២០០៩ ដល់ ធ្នូ ២០០៩

ង). ថវិកា

- ការផលិតស្ប៉ត់ទូរទស្សន៍ទាំង ១០ : ៥៥ 000,00 ដុល្លារ
- ការផ្សាយតាមទូរទស្សន៍ : ១00 000,00 ដុល្លារ

**សរុប : ១៥៥ 000,00 ដុល្លារ**

## ២.៧.២. កម្មវិធីផ្សព្វផ្សាយតាមវិទ្យុ

ក). ប្រវត្តិ

ក្រោយពីការអនុវត្តប្រកបដោយជោគជ័យនូវការអប់រំប្រជាពលរដ្ឋពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការតាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ពិសេសការផលិតកម្មវិធីផ្សេងៗតាមវិទ្យុកន្លងមកនៅក្នុងគម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់ ដំណាក់កាលទី១ (CCDP-1)។ ហេតុនេះហើយ ទើបសកម្មភាពដដែលនេះត្រូវបានយកមកអនុវត្តជាបន្តទៀតនៅក្នុង CCDP-2។ អ្វីដែលប្រែប្រួលនោះគឺខ្លឹមសារនៃសារសំខាន់ ដែលវាត្រូវតែបត់បែនទៅតាមស្ថានភាពជាក់ស្តែង និងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

សំខាន់ជាងនេះទៀត ក្រុមប្រឹក្សាឃុំ សង្កាត់បានស្នើសុំឱ្យប្រព័ន្ធផ្សព្វផ្សាយបន្តតួនាទីរបស់ខ្លួនក្នុងការផ្សព្វផ្សាយព័ត៌មានទៅដល់ប្រជាពលរដ្ឋនៅតាមទីជនបទបន្តទៀត។ នេះបើយោងទៅតាមការសិក្សាពីតម្រូវការនៃការកសាងសមត្ថភាពដែលធ្វើឡើងដោយការិយាល័យអប់រំ និងកសាងសមត្ថភាពថ្មីៗនេះ។

ខ). ខ្លឹមសារ

ខ្លឹមសារសំខាន់បំផុតសម្រាប់ការផលិតកម្មវិធីផ្សព្វផ្សាយតាមវិទ្យុ នឹងគ្របដណ្តប់លើចំនុចសំខាន់ៗដូចខាងក្រោមនេះ :

- ព័ត៌មានទូទៅទាក់ទងនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ:

- ទំនាក់ទំនងរវាងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ទីរវិស័យ
- ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការកសាងផែនការអភិវឌ្ឍរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ការផ្ទេរមុខងារនៅក្នុងក្របខ័ណ្ឌច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- តួនាទីរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការផ្តល់សេវាកម្មនៅមូលដ្ឋាន
- លើកទឹកចិត្តឱ្យមានសម្លេងរបស់ប្រជាពលរដ្ឋ និងការចូលរួមរបស់គាត់ក្នុងកិច្ចការអភិវឌ្ឍន៍មូលដ្ឋាន
- ជំរុញ និងលើកទឹកចិត្តឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើផែនការ និងអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន។

### គ). យុទ្ធសាស្ត្រ

អង្គការ Equal Access Cambodia បានទទួលការងារផលិតកម្មវិធីអប់រំផ្សព្វផ្សាយតាមវិទ្យុបន្ថែមលើការងារផលិតស្ប៉ត់ទូរទស្សន៍ដូចបានលើកឡើងនៅក្នុងចំនុច ២.៧. ខាងលើ។ ការងារដែល EAC ត្រូវធ្វើសំខាន់ៗទាក់ទងនឹងកម្មវិធីផ្សព្វផ្សាយតាមវិទ្យុរួមមាន :

- ការផលិតស្ប៉តវិទ្យុរយៈពេល ១នាទី ចំនួន ១០
- ការផលិតកម្មវិធីវិទ្យុរឿងខ្លីរយៈពេល១ម៉ោង ចំនួន១០ ហៅថា " ជោគជ័យផ្តើមពីនាក់ "
- ការផលិតកម្មវិធីសន្ទនាផ្ទាល់តាមវិទ្យុរយៈពេល៣០នាទី ចំនួន១០ ដែលដំណើរការទន្ទឹមគ្នានឹងរឿងខ្លី
- ការបណ្តុះបណ្តាល ២ លើកឱ្យដល់ស្ថានីយវិទ្យុជាដៃគូរទាំង ៨ លើកម្មវិធី ការសន្ទនាដោយផ្ទាល់។

គ្រប់សកម្មភាពទាំងអស់ខាងលើសុទ្ធតែឆ្លងការចូលរួម និងការពិភាក្សាជាមួយ DoLA ពិសេសការិយាល័យអប់រំ និងកសាងសមត្ថភាពមុននឹងឈានដល់ដំណាក់កាលចុងក្រោយ។

### ឃ). ពេលវេលា

- ខែមករា-កុម្ភៈ ឆ្នាំ២០០៩ : ការផលិតស្ប៉តវិទ្យុរយៈពេល ១នាទី
- ខែមីនា-ធ្នូ ឆ្នាំ២០០៩ : ផ្សព្វផ្សាយ
- ខែមករា-ធ្នូ ឆ្នាំ២០០៩ : កម្មវិធីវិទ្យុរយៈពេល១ម៉ោង ចំនួន១០ហៅថា " ជោគជ័យផ្តើមពីនាក់ "
- ខែមករា-ធ្នូ ឆ្នាំ២០០៩ : ការផលិតកម្មវិធីសន្ទនាផ្ទាល់តាមវិទ្យុរយៈពេល៣០នាទី ដែលដំណើរការទន្ទឹមគ្នានឹងរឿងខ្លី
- ខែ កុម្ភៈ ឆ្នាំ២០០៩ : ការបណ្តុះបណ្តាល ២ លើកឱ្យដល់ស្ថានីយវិទ្យុជាដៃគូរទាំង៨ លើកម្មវិធីការសន្ទនាដោយផ្ទាល់

### ង). ថវិកា

- ការផលិតស្ប៉តវិទ្យុ និងការផ្សព្វផ្សាយតាមវិទ្យុ : **៤២ 000,00 ដុល្លារ**
- កម្មវិធីតាមវិទ្យុរយៈពេលមួយម៉ោង : ១៣ 000,00 ដុល្លារ

**សរុប : ៥៥ 000,00 ដុល្លារ**

# ឧសម្ព័ន្ធ១ : ថវិកាប៉ាន់ស្មានលម្អិត

| លរ | ប្រធានបទ | ការបរិយាយ | ឯកតា | សម្រាប់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត | | | បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ | | | បណ្តុះបណ្តាលឧទ្ទេសនៅថ្នាក់ខេត្ត រាជធានី | | | កំណត់សម្គាល់ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ចំនួនឯកតា | តម្លៃឯកតា | សរុប | ចំនួនឯកតា | តម្លៃឯកតា | សរុប | ចំនួនឯកតា | តម្លៃឯកតា | សរុប | |
| **សម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** | | | | | | | | | | | | | |
| 1 | ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបរិមជ្ឈការ និងវិសហមជ្ឈការ | ប្រាក់បេសកកម្មសិក្ខាកាម | Per/day | 1,944 | 25.00 | 48,600.00 | 248 | 25.00 | 6,200.00 | - | 5.00 | - | 511 participants from capital and provinces will invite to attend 3days orientation at national level(6sessions, which has 100 each session) |
| | | ប្រាក់ធ្វើដំណើរសិក្ខាកាម | Ls | 486 | 18.00 | 8,748.00 | 62 | 18.00 | 1,116.00 | - | 5.00 | - | |
| | | ការរៀបចំឯកសារបណ្តុះបណ្តាល | Course | 1 | 2,500.00 | 2,500.00 | | | - | | | - | |
| | | សម្ភារៈបណ្តុះបណ្តាល | Class | 5 | 60.00 | 300.00 | 2 | 810.00 | 1,620.00 | 24 | 25.00 | 600.00 | 62 participants from all provi and capital will invite to attend 3days national ToT. |
| | | ឯកសារបណ្តុះបណ្តាល | Book | 531 | 1.50 | 796.50 | 80 | 2.00 | 160.00 | 250 | 1.50 | 375.00 | |
| | | ជួលបន្ទប់ និងអាហារសម្រន់ | Per/day | 1,593 | 20.00 | 31,860.00 | 240 | 1.50 | 360.00 | 250 | 1.00 | 250.00 | 250 provincial trainers will be invited to attend 3 days provincial ToT. |
| | | ការចំណាយជាយថាហេតុ | Class | 5 | 50.00 | 250.00 | 2 | 50.00 | 100.00 | 24 | - | - | |
| | | សរុបតាមថ្នាក់ | | | | **93,054.50** | | | **9,556.00** | | | **1,225.00** | |
| | | សរុបរង | | | | | | | | | | **103,835.50** | |
| | | ថវិកាពី **PILAC** | | | | **93,054.50** | | | | | | | **93,054.50** |
| | | ថវិកាពី **CCDP2** | | | | | | | **9,556.00** | | | **1,225.00** | **10,781.00** |
| | | | | សម្រាប់ក្រុមប្រឹក្សា គណៈអភិបាលក្រុង ស្រុក ខណ្ឌ | | | | | | | | | |
| | ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបរិមជ្ឈការ និងវិសហមជ្ឈការ | ប្រាក់បេសកកម្មសិក្ខាកាម | Per/day | | - | - | | | | | | | 3689 of MDK board governor and councilors will be invited to attend 3 days training at M/D/K level. |
| | | ប្រាក់ធ្វើដំណើរសិក្ខាកាម | Ls | | - | - | | | | | | | |
| | | ការរៀបចំឯកសារបណ្តុះបណ្តាល | Course | | | - | | | | | | | |
| | | សម្ភារៈបណ្តុះបណ្តាល | Class | 193 | 25.00 | 4,825.00 | | | | | | | |
| | | ឯកសារបណ្តុះបណ្តាល | Book | 3,689 | 1.50 | 5,533.50 | | | | | | | |
| | | ជួលបន្ទប់ និងអាហារសម្រន់ | Per/day | 11,253 | 1.00 | 11,253.00 | | | | | | | |
| | | ការចំណាយជាយថាហេតុ | Class | 193 | 10.00 | 1,930.00 | | | | | | | |
| | | សរុបតាមថ្នាក់ | | | | **23,541.50** | | | **-** | | | **-** | |
| | | សរុបរង | | | | | | | | | | **23,541.50** | |
| | | ថវិកាពី **CCDP2** | | | | **23,541.50** | | | **-** | | | **-** | **23,541.50** |
| 2 | | | | សម្រាប់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត | | | ភាពអនុវត្តរាជធានី ខេត្ត | | | | | | |
| | ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលរាជធានី ខេត្ត | ប្រាក់បេសកកម្មសិក្ខាកាម | Per/day | 1,944 | 25.00 | 48,600.00 | 288 | 25.00 | 7,200.00 | | | | 511 participants from capital and provinces will invite to attend 3days training at national level(6sessions, which has 100 each session) |
| | | ប្រាក់ធ្វើដំណើរសិក្ខាកាម | Ls | 486 | 18.00 | 8,748.00 | 72 | 18.00 | 1,296.00 | | | | |
| | | ការរៀបចំឯកសារបណ្តុះបណ្តាល | Course | 1 | 2,500.00 | 2,500.00 | | | - | | | | |
| | | សម្ភារៈបណ្តុះបណ្តាល | Class | 5 | 60.00 | 300.00 | 2 | 810.00 | 1,620.00 | | | - | 72 participants from all provi and capital will invite to attend 3days detail t raining. |
| | | ឯកសារបណ្តុះបណ្តាល | Book | 531 | 1.50 | 796.50 | 100 | 1.50 | 150.00 | | | - | |
| | | ជួលបន្ទប់ និងអាហារសម្រន់ | Per/day | 1,593 | 20.00 | 31,860.00 | 300 | 1.50 | 450.00 | | | - | |
| | | ការចំណាយជាយថាហេតុ | Class | 5 | 50.00 | 250.00 | 2 | 50.00 | 100.00 | | | - | |
| | | សរុបតាមថ្នាក់ | | | | **93,054.50** | | | **10,816.00** | | | **-** | |
| | | សរុបរង | | | | | | | | | | **103,870.50** | |
| | | ថវិកាពី **PSDD** | | | | **93,054.50** | | | **10,816.00** | | | | **103,870.50** |
| លរ | ប្រធានបទ | ការបរិយាយ | ឯកតា | បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ | | | បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់រាជធានី ខេត្ត | | | សម្រាប់ក្រុមប្រឹក្សា គណៈអភិបាលក្រុង ស្រុក ខណ្ឌ | | | កំណត់សម្គាល់ផ្សេងៗ |
| | | | | ចំនួនឯកតា | តម្លៃឯកតា | សរុប | ចំនួនឯកតា | តម្លៃឯកតា | សរុប | ចំនួនឯកតា | តម្លៃឯកតា | សរុប | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 3 | ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ | ប្រាក់បេសកកម្មសិក្ខាកាម | Per/day | 312 | 25.00 | 7,800.00 | - | 5.00 | - | - | 5.00 | - | 78 participants from all provi and capital will invite to attend 3days national ToT. |
| | | ប្រាក់ធ្វើដំណើរសិក្ខាកាម | Ls | 78 | 18.00 | 1,404.00 | - | 5.00 | - | - | 5.00 | - | |
| | | ការរៀបចំឯកសារបណ្តុះបណ្តាល | Course | 1 | 330.00 | 330.00 | | | - | | | - | 250 provincial trainers will be invited to attend 3 days provincial ToT. |
| | | ជួលបន្ទប់ និងសម្ភារៈបណ្តុះបណ្តាល | Class | 2 | 810.00 | 1,620.00 | 24 | 25.00 | 600.00 | 193 | 25.00 | 4,825.00 | |
| | | ឯកសារបណ្តុះបណ្តាល | Book | 100 | 2.00 | 200.00 | 250 | 1.50 | 375.00 | 4,075 | 1.50 | 6,112.50 | 4075 board governors, councilors and implementers will be invited to attend 3 days training at MDK level. |
| | | អាហារសម្រន់ | Per/day | 300 | 1.00 | 300.00 | 250 | 1.00 | 250.00 | 12,225 | 1.00 | 12,225.00 | |
| | | ការចំណាយជាយថាហេតុ | Class | 2 | - | - | 24 | - | - | 45 | - | - | |
| | | សរុបតាមថ្នាក់ | | | | 11,654.00 | | | 1,225.00 | | | 23,162.50 | |
| | | សរុបរង | | | | | | | | | | 36,041.50 | |
| | | ថវិកាពី CCDP2 | | | | 11,654.00 | | | 1,225.00 | | | 23,162.50 | 36,041.50 |
| | | | | សម្រាប់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ខេត្ត | | | សម្រាប់អង្គភាពអនុវត្តរាជធានី ខេត្ត | | | | | | |
| 4 | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ | ប្រាក់បេសកកម្មសិក្ខាកាម | Per/day | 1,944 | 25.00 | 48,600.00 | 288 | 25.00 | 7,200.00 | | | | 511 participants from capital and provinces will invite to attend 3days training at national level(6sessions, which has 100 each session) |
| | | ប្រាក់ធ្វើដំណើរសិក្ខាកាម | Ls | 486 | 18.00 | 8,748.00 | 72 | 18.00 | 1,296.00 | | | | |
| | | ការរៀបចំឯកសារបណ្តុះបណ្តាល | Course | 1 | 2,500.00 | 2,500.00 | | | - | | | | |
| | | សម្ភារៈបណ្តុះបណ្តាល | Class | 5 | 60.00 | 300.00 | 2 | 810.00 | 1,620.00 | | | | 72 participants from all provi and capital will invite to attend 3days detail t raining. |
| | | ឯកសារបណ្តុះបណ្តាល | Book | 511 | 1.50 | 766.50 | 100 | 1.50 | 150.00 | | | | |
| | | ជួលបន្ទប់ និងអាហារសម្រន់ | Per/day | 1,593 | 20.00 | 31,860.00 | 300 | 1.50 | 450.00 | | | | |
| | | ការចំណាយជាយថាហេតុ | Class | 5 | 50.00 | 250.00 | 2 | 50.00 | 100.00 | | | | |
| | | សរុបតាមថ្នាក់ | | | | 93,024.50 | | | 10,816.00 | | | - | |
| | | សរុបរង | | | | | | | | | | 103,840.50 | |
| | | ថវិកាពី PSDD | | | | 93,024.50 | | | 10,816.00 | | | | 103,840.50 |
| | | | | បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ | | | បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់រាជធានី ខេត្ត | | | សម្រាប់ក្រុមប្រឹក្សា គណៈអភិបាលក្រុង ស្រុក ខណ្ឌ | | | |
| | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ | ប្រាក់បេសកកម្មសិក្ខាកាម | Per/day | 312 | 25.00 | 7,800.00 | - | 5.00 | - | - | 5.00 | - | 78 participants from capital and provinces will invite to attend 3days national ToT. |
| | | ប្រាក់ធ្វើដំណើរសិក្ខាកាម | Ls | 78 | 18.00 | 1,404.00 | - | 5.00 | - | - | 5.00 | - | |
| | | ការរៀបចំឯកសារបណ្តុះបណ្តាល | Course | 1 | 330.00 | 330.00 | | | - | | | - | |
| | | សម្ភារៈបណ្តុះបណ្តាល | Class | 2 | 810.00 | 1,620.00 | 24 | 25.00 | 600.00 | 193 | 25.00 | 4,825.00 | 250 provincial trainers will be invited to attend 3 days provincial ToT. |
| | | ឯកសារបណ្តុះបណ្តាល | Book | 100 | 2.00 | 200.00 | 250 | 1.50 | 375.00 | 4,075 | 1.50 | 6,112.50 | |
| | | ជួលបន្ទប់ និងអាហារសម្រន់ | Per/day | 300 | 1.00 | 300.00 | 250 | 1.00 | 250.00 | 12,225 | 1.00 | 12,225.00 | |
| | | ការចំណាយជាយថាហេតុ | Class | 2 | - | - | 24 | - | - | 45 | - | - | 4075 board governors, councilors and implementers will be invited to attend 3 days training at MDK level. |
| | | សរុបតាមថ្នាក់ | | | | 11,654.00 | | | 1,225.00 | | | 23,162.50 | |
| | | សរុបរង | | | | | | | | | | 36,041.50 | |
| | | ថវិកាពី CCDP2 | | | | 11,654.00 | | | 1,225.00 | | | 23,162.50 | 36,041.50 |
| 5 | | | | ការបណ្តុះបណ្តាល | | | | | | | | | |
| | ការអនុវត្តគម្រោងថ្នាក់ស្រុក ខណ្ឌ | សរុបសម្រាប់សកម្មភាពនេះ | LS | 1 | 6,950.00 | 6,950.00 | - | - | - | - | - | - | |
| | | សរុបតាមថ្នាក់ | | | | 6,950.00 | | | - | | | - | |
| | | សរុបរង | | | | | | | | | | 6,950.00 | |
| | | ថវិកាពី PSDD/DIP | | | | 6,950.00 | | | - | | | - | 6,950.00 |
| លរ | ប្រធានបទ | ការបរិយាយ | ឯកតា | | | | បណ្តុះបណ្តាល | | | | | | កំណត់សម្គាល់ផ្សេងៗ |
| | | | | ចំនួនឯកតា | តម្លៃឯកតា | សរុប | ចំនួនឯកតា | តម្លៃឯកតា | សរុប | ចំនួនឯកតា | តម្លៃឯកតា | សរុប | |
| 6 | វគ្គបណ្តុះបណ្តាលអង្គភាពគាំទ្រឃុំសង្កាត់នៅថ្នាក់ | ការចំណាយសម្រាប់សកម្មភាពនេះ | Ls | - | - | - | 1 | 54,000 | 54,000.00 | | | - | This budget will cover the any training for supporting district functioning. |
| | | សរុបតាមថ្នាក់ | | | | - | | | 54,000.00 | | | - | |
| | | សរុបរង | | | | | | | | | | 54,000.00 | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ស្រុក ខណ្ឌ | **ថវិកាពី EC-UNDP/DDLG** | | | | **-** | | | **54,000.00** | | | **-** | **54,000.00** |
| | | | | មន្ត្រីជាន់ខ្ពស់ | | | មន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន | | | មន្ត្រីថ្នាក់ក្រោមជាតិ | | | |
| 7 | សិក្ខាសាលាផ្សព្វផ្សាយអំពីច្បាប់អង្គការ | ប្រាក់បេសកកម្មសិក្ខាកាម | Per/day | | - | - | | | | 2,210 | 5.00 | 11,050.00 | 784 participants from all department director, all general directors and one deputy director will be invited. |
| | | ប្រាក់ធ្វើដំណើរសិក្ខាកាម | Ls | | | - | | | | 1,105 | 5.00 | 5,525.00 | |
| | | ការរៀបចំឯកសារបណ្តុះបណ្តាល | Course | | | - | | | | | | - | 100 GDLA offial will be invited to attend workshop. |
| | | សម្ភារៈបណ្តុះបណ្តាល | Class | 7 | 50.00 | 350.00 | 1.00 | 60.00 | 60.00 | 26 | 25.00 | 650.00 | |
| | | ឯកសារបណ្តុះបណ្តាល | Book | 800 | 1.00 | 800.00 | 100.00 | 1.00 | 100.00 | 2,545 | 1.00 | 2,545.00 | 2545 parti at subnational level including provincial staff, director and deputy directors of line department, district governor and vice governors will be invited. |
| | | ជួលបន្ទប់ និងអាហារសម្រន់ | Per/day | 800 | 20.00 | 16,000.00 | 100.00 | 25.00 | 2,500.00 | 2,545 | 1.00 | 2,545.00 | |
| | | ការចំណាយជាយថាហេតុ | Class | 7 | 50.00 | 350.00 | 1.00 | 50.00 | 50.00 | 26 | 10.00 | 260.00 | |
| | | សរុបតាមថ្នាក់ | | | | **17,500.00** | | | **2,710.00** | | | **22,575.00** | |
| | | សរុបរង | | | | | | | | | | **42,785.00** | |
| | | **ថវិកាពី PILAC** | | | | | | | **2,710.00** | | | | **2,710.00** |
| | | **ថវិកាពី PSDD** | | | | **17,500.00** | | | | | | | **17,500.00** |
| | | ថវិកាពី CCDP2 | | | | | | | | | | **22,575.00** | **22,575.00** |
| | | | | សម្រាប់សង្គមស៊ីវិល | | | សមាជិករាជរដ្ឋាភិបាល | | | | | | |
| | សិក្ខាសាលាផ្សព្វផ្សាយអំពីច្បាប់អង្គការ | ប្រាក់បេសកកម្មសិក្ខាកាម | Per/day | | | - | | | - | | | | 30 participants from civil society/NGO will be invited to attend ToT on OL. |
| | | ប្រាក់ធ្វើដំណើរសិក្ខាកាម | Ls | | | - | | | - | | | | |
| | | ការរៀបចំឯកសារបណ្តុះបណ្តាល | Course | | | - | | | - | | | | 446 parti who are RGC members will be invited to attend haft day presentation. |
| | | សម្ភារៈបណ្តុះបណ្តាល | Class | 1 | 50.00 | 50.00 | 2 | 500 | 1,000.00 | | | | |
| | | ឯកសារបណ្តុះបណ្តាល | Book | 30 | 1.00 | 30.00 | 446 | 1 | 446.00 | | | | |
| | | ជួលបន្ទប់ និងអាហារសម្រន់ | Per/day | 60 | 20.00 | 1,200.00 | 446 | 1 | 446.00 | | | | |
| | | ការចំណាយជាយថាហេតុ | Class | 1 | 50.00 | 50.00 | 2 | 1,000 | 2,000.00 | | | | |
| | | សរុបតាមថ្នាក់ | | | | **1,330.00** | | | **3,892.00** | | | **-** | |
| | | សរុបរង | | | | | | | | | | **5,222.00** | |
| | | ថវិកាពី PSDD | | | | | | | **3,892.00** | | | | **3,892.00** |
| | | ថវិកាពី GTZ | | | | **1,330.00** | | | | | | | **1,330.00** |
| 8 | ការបោះពុម្ពសៀវភៅផ្សព្វផ្សាយ | ការរៀបចំឯកសារ និងខ្លឹមសារ | LS | 1 | 500.00 | 500.00 | | | | | | | 28770 booklets will be printed and distributed to all sub national level adm, ministries, senate, assembly, CAR, provincial depart, C/S and civil society. |
| | | ការបោះពុម្ព | LS | 28,770 | 1.00 | 28,770.00 | | | | | | | |
| | | ការចំណាយជាយថាហេតុ | Ls | 1 | 300.00 | 300.00 | | | | | | | |
| | | សរុបតាមថ្នាក់ | | | | **29,570.00** | | | **-** | | | **-** | |
| | | សរុបរង | | | | | | | | | | **29,570.00** | |
| | | **ថវិកាពី PSDD** | | | | **29,570.00** | | | **-** | | | **-** | **29,570.00** |
| 9 | ការបោះពុម្ពផ្ទាំងរូបភាព | ការបោះពុម្ព | Ls | 51,495 | 0.50 | 25,747.50 | | | | | | - | 17165 sheet per topics of poster will be printed and distributed to all sub national and relevance institutions. There are 3 topics of poster will be printed. |
| | | ការចំណាយជាយថាហេតុ | Ls | 3 | 300.00 | 900.00 | | | | | | - | |
| | | សរុបតាមថ្នាក់ | | | | **26,647.50** | | | **-** | | | **-** | |
| | | សរុបរង | | | | | | | | | | **26,647.50** | |
| | | **ថវិកាពី PSDD** | | | | **26,647.50** | | | | | | | **26,647.50** |
| ល.រ | ប្រធានបទ | ការបរិយាយ | ឯកតា | ការបោះពុម្ព | | | | | | | | | កំណត់សម្គាល់ផ្សេងៗ |
| | | | | ចំនួនឯកតា | តម្លៃឯកតា | សរុប | ចំនួនឯកតា | តម្លៃឯកតា | សរុប | ចំនួនឯកតា | តម្លៃឯកតា | សរុប | |
| 10 | ការផ្សព្វផ្សាយតាមវិទ្យុ | ការរៀបចំ ផលិត និងផ្សព្វផ្សាយ | Ls | 1 | 15,000.00 | 15,000.00 | | | | | | - | Produce 5 radio spot, each spot has 3mns and need to broadcate in 2 radio station in PNP and 8 radio stations in P/M. |
| | | ការចំណាយជាយថាហេតុ | Ls | | | - | | | | | | - | |
| | | សរុបតាមថ្នាក់ | | | | **15,000.00** | | | **-** | | | **-** | |
| | | សរុបរង | | | | | | | | | | **15,000.00** | |
| | | **ថវិកាពី PSDD** | | | | **15,000.00** | | | **-** | | | | **15,000.00** |
| | | ការរៀបចំ ផលិត និងផ្សព្វផ្សាយ | Ls | 1 | 30,000.00 | 30,000.00 | | | | | | | |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 11 | ការផ្សព្វផ្សាយតាមទូរទស្សន៍ | ការចំណាយជាយថាហេតុ | Ls | | | - | | | | | | | Produce 3 TV spots, each spot has 1 mn and need to broadcaste in 3 TV station in PNP. |
| | | **សរុបតាមថ្នាក់** | | | | **30,000.00** | | | **-** | | | **-** | |
| | | **សរុបរង** | | | | | | | | | | **30,000.00** | |
| | | **ថវិកាពី PSDD** | | | | **30,000.00** | | | **-** | | | | **30,000.00** |
| 12 | ជំនាញសម្របសម្រួល និងបណ្តុះបណ្តាល | ប្រាក់បេសកកម្មសិក្ខាកាម | Per/day | 50 | 25.00 | 1,250.00 | | | - | | | | 50 Officials from DoLA, PT and under generals department of local administration will attend 5days training. |
| | | ថ្លៃធ្វើដំណើរសិក្ខាកាម | LS | 50 | 18.00 | 900.00 | | | | | | | |
| | | បន្ទប់ និងសម្ភារៈបណ្តុះបណ្តាល | Class | 1 | 1,310.00 | 1,310.00 | | | - | | | | |
| | | ឯកសារបណ្តុះបណ្តាល | Book | 60 | 2.00 | 120.00 | | | - | | | | |
| | | អាហារសម្រន់ | Per/day | 250 | 1.50 | 375.00 | | | - | | | | |
| | | ការចំណាយជាយថាហេតុ | Class | 1 | 100.00 | 100.00 | | | - | | | | |
| | | **សរុបតាមថ្នាក់** | | | | **4,055.00** | | | **-** | | | | |
| | | **សរុបរង** | | | | | | | | | | **4,055.00** | |
| | | **ថវិកាពី CCDP2** | | | | **4,055.00** | | | **-** | | | | **4,055.00** |
